Save Vulnerable Cambodians | POH KAO | HEINRICH BÖLL STIFTUNG CAMBODIA | NTFP | The NGO Forum on Cambodia — Working Together for Positive Change | 3 S River Protection Network

# ការកាប់ឈើ និងបរិបាលកិច្ចៈ
# ការកាប់ឈើខុសច្បាប់ជាប្រព័ន្ធ
# និងការបំផ្លាញព្រៃឈើរដ្ឋ និងតំបន់ការពារ

# នៅខេត្តរតនគីរី និងខេត្តស្ទឹងត្រែង ប្រទេសកម្ពុជា




ខែមិថុនា ឆ្នាំ ២០១៥

# ការកាប់ឈើ និងបរិបាលកិច្ចៈ ការកាប់ឈើខុសច្បាប់ជាប្រព័ន្ធ និងការបំផ្លាញព្រៃឈើរដ្ឋ និងតំបន់ការពារ នៅខេត្តរតនគីរី និងខេត្តស្ទឹងត្រែង ប្រទេសកម្ពុជា

កាលបរិច្ឆេទ៖ ខែមិថុនា ឆ្នាំ២០១៥
បោះពុម្ពផ្សាយដោយ៖ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
កម្មវិធីដីធ្លី និងជីវភាព
គម្រោងសិទ្ធិព្រៃឈើ

គ្រប់រូបភាពនៅក្នុងរបាយការណ៍នេះត្រូវបានផ្តល់ដោយក្រុមអ្នកស៊ើបអង្កេត

**សេចក្តីបញ្ជាក់៖**
ទស្សនៈបង្ហាញក្នុងរបាយកាណ៍នេះសុទ្ធតែជាទស្សនៈរបស់អ្នកនិពន្ធ ហើយមិនបង្ហាញពីទស្សនៈរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាទេ។ នៅពេលខ្លឹមសារនៃរបាយការណ៍នេះត្រូវគេដកស្រង់ ឬផលិតសារជាថ្មី ការទទួលស្គាល់ និងការសុំអនុញ្ញាតសិទ្ធិរបស់អ្នកនិពន្ធ និងអ្នកបោះពុម្ពផ្សាយនឹងត្រូវគេអោយតម្លៃ។

**© វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ខែមិថុនា ឆ្នាំ២០១៥**

# មាតិកា


មាតិកា........................................................................................ i
អក្សរកាត់........................................................................................ iii
សេចក្តីសង្ខេប........................................................................................ v
១.សេចក្តីផ្តើម........................................................................................ ១
២.រចនាសម្ព័ន្ធរបាយការណ៍ ........................................................................ ៤
៣.វិធីសាស្ត្រ........................................................................................ ៥
៤.វិនាសកម្មព្រៃឈើនៅខេត្តរតនគិរី ........................................................ ៦
    ៤.១ មូលហេតុចំបងនៃវិនាសកម្មព្រៃឈើ...................................................... ៦
    ៤.២ មូលហេតុផ្សេងទៀតនៃវិនាសកម្មព្រៃឈើ................................................ ១០
៥.តម្លៃឈើប្រណីត ........................................................................................ ១៤
៦.អាជីវកម្មឈើទ្រង់ទ្រាយធំនៅខេត្តរតនគិរី .................................................. ១៥
    ៦.១ អាជីវកម្មឈើប្រណីត ...................................................................... ១៨
៧.ផលប៉ះពាល់នៃវិនាសកម្មព្រៃឈើ ............................................................ ១៩
    ៧.១ ការបាត់បង់ចំណូល និងនិរន្តរភាព........................................................ ២០
    ៧.២ ការបាត់បង់ភាពម្ចាស់ការលើខ្លួនឯង...................................................... ២៥
    ៧.៣ បម្រែបម្រួលអាកាសធាតុ ................................................................. ២៧
៨.អាជីវកម្មឈើប្រណីតរបស់ក្រុមហ៊ុនទ្រី ភាព គ្រុប ........................................... ២៨
    ៨.១ យុទ្ធសាស្ត្រ និងដំណើការ ................................................................. ២៨
    ៨.២ សិទ្ធិប្រមូល ទិញឈើប្រណីតពីសម្បទានដីសេដ្ឋកិច្ចនៅខេត្តរតនគីរី
    របស់ក្រុមហ៊ុនទ្រី ភាព គ្រុប ............................................................... ៣០
    ៨.៣ ការកាប់ឈើ ការប្រមូលផល ការស្តុក និងការដឹកជញ្ជូនឈើប្រណីត .... ៣០
៩. ការនាំចេញឈើប្រណីតដោយក្រុមហ៊ុនទ្រី ភាព គ្រុប........................................ ៤២
១០. បទវិភាគផ្នែកច្បាប់អំពីអាជីវកម្មឈើប្រណីតរបស់ក្រុមហ៊ុនទ្រីភាពគ្រុប ........... ៤៥
    ១០.១ អ្វីជាភាពខុសគ្នារវាងសកម្មភាពកាប់ឈើស្របច្បាប់ និងខុសច្បាប់? ... ៤៥
    ១០.២ សេចក្តីសន្និដ្ឋានពីការវិភាគផ្នែកច្បាប់លើអាជីវកម្មឈើប្រណីតរបស់
        ទ្រីភាពគ្រុប........................................................................ ៤៦
    ១០.៣ តើអាជ្ញាប័ណ្ណចេញដោយរាជរដ្ឋាភិបាលកម្ពុជាជូនដល់ទ្រីភាពគ្រុប
        អនុញ្ញាតឲ្យទិញឈើកាប់នៅក្នុងខេត្តរតនគីរី ស្របច្បាប់នៅក្រោមច្បាប់
        អន្តរជាតិដែរឬទេ?................................................................ ៤៨
    ១០.៤ តើរាជរដ្ឋាភិបាលកម្ពុជារំលោភច្បាប់ជាតិ និងអន្តរជាតិ ដោយខកខាន
        មិនបានប្រឹក្សាយោបល់ជាសាធារណៈដោយត្រឹមត្រូវមុនពេលផ្តល់

អាជ្ញាប័ណ្ណជូនទ្រីភាពគ្រុបដែរឬទេ?............................................ ៤៩
១១. ពន្យល់ពាក្យបច្ចេកទេសឈើប្រណិត........................................................ ៥០
១២. បទសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធ ........................................................ ៦២
១៣. អនុសាសន៍................................................................................. ៨៤
១៤. ឧបសម្ព័ន្ធ ................................................................................... ៨៧
ឧបសម្ព័ន្ធ១ ៖ ការពន្យល់តម្លៃឈើ .............................................................. ៨៧
ឧបសម្ព័ន្ធ២ ៖ ស្លាកលេខដែលបានរកឃើញដោយអ្នកស្រាវជ្រាវ ........................... ៩០
ឧបសម្ព័ន្ធ៣ ៖ អនុក្រឹត្យស្តីពីការផ្តល់សម្បទានសង្គមកិច្ចមានទំហំ៩៧០៩ហិកតាជូន
ក្រុមហ៊ុនទ្រីភាព នាំចេញ នាំចូល នៅស្រុកតាវែង ក្នុងឧទ្យានជាតិវីរៈជ័យ
ចុះថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ២០១១.............................................................. ៩១
ឧបសម្ព័ន្ធ៤ ៖ អនុក្រឹត្យស្តីពីអនុបយោគតំបន់ប្រើប្រាស់ដោយចីរភាពទំហំ៩១៤៦
ហិកតា ក្នុងឧទ្យានជាតិវីរៈជ័យ ឲ្យទៅជាដីឯកជនរបស់រដ្ឋ ចុះថ្ងៃទី០៩ ខែកុម្ភៈ
ឆ្នាំ២០១១ .................................................................................... ៩៣
ឧបសម្ព័ន្ធ៥ ៖ បញ្ជីលេខកូដមេការ តំណាង ទ្រី ភាព និងថៅកែឈើ ...................... ៩៥
ឧបសម្ព័ន្ធ៦ ៖ លេខកូដឈើរបស់ថៅកែឈើ.................................................... ៩៩
ឧបសម្ព័ន្ធ៧ ៖ តំបន់កាប់ឈើនៅក្នុងឧទ្យានជាតិវីរៈជ័យ ................................... ១០០
ឧបសម្ព័ន្ធ៨ ៖ ផ្ទែកដេប៉ូឈើ និងរោងចក្រអារឈើរបស់ទ្រី ភាពគ្រុប និងអានមាឌី.... ១០៣
ឧបសម្ព័ន្ធ៩ ៖ វិក័យប័ត្រនានាពីក្រុមហ៊ុនទ្រីភាព អាហ័រណា នីហ័រណា ជូនអ្នកបញ្ជា
ទិញនៅទីក្រុងហុងកុង ក្រុមហ៊ុនហុងកុង គិន ជុន ដឹកជញ្ជូន.............................. ១០៥
ឧបសម្ព័ន្ធ១០ ៖លិខិតពីក្រសួងបរិស្ថានស្នើទៅនាយករដ្ឋមន្ត្រីកម្ពុជាសុំការអនុញ្ញាតឲ្យ
ក្រុមហ៊ុនទ្រី ភាព អាហ័រណា នីហ័រណា និងក្រុមហ៊ុនអឹមឌីអេសថ្មដាអេស អ៊ី ហ្សិត
នាំចេញ ១០០ ០០០ ឈើកែច្នៃម៉ែត្រគូប ................................................... ១១៤
ឧបសម្ព័ន្ធ១១ ៖ ការឯកភាពដោយគណៈរដ្ឋមន្ត្រីលើសំណើរបស់ក្រសួងបរិស្ថានក្នុង
ការផ្តល់ការអនុញ្ញាតឲ្យក្រុមហ៊ុនទ្រីភាព អាហ័រណា នីហ័រណា និង អឹមឌីអេសថ្មដា
អេស អ៊ី ហ្សិត នាំចេញឈើកែច្នៃ ១០០ ០០០ មែត្រគូប ............................ ១១៦
ឧបសម្ព័ន្ធ១២ ៖ បញ្ជីឈ្មោះប្រភេទឈើបែងចែកតាមគុណភាពឈើ.......................... ១១៧
ឧបសម្ព័ន្ធ១៣ ៖ កិច្ចសន្យាព្រមព្រៀងជាភាសាខ្មែររវាងថៅកែឈើ ជាមួយមេភូមិ
នៅឃុំកូក ឡាក់ ក្នុងនោះថៅកែឈើយល់ព្រមសាងសង់អគារជាថ្នូរនឹង
ការអនុញ្ញាតឲ្យកាប់ឈើនៅឃុំកូកឡាក់ .................................................... ១២១
ឧបសម្ព័ន្ធ១៤ ៖ លិខិតលេខ ១២៧០ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ របស់អគ្គលេខាធិការ
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជំរាបជូន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុក
ប្រធានរដ្ឋបាលព្រៃឈើអនុញ្ញាតឲ្យក្រុមហ៊ុនទ្រីភាព អ៊ឹមផត អ៊ិចផតប្រមូលទិញឈើ
ពីបណ្តាដីសម្បទាននានាស្ថិតក្នុងខេត្តរតនគីរី.............................................. ១២២

# អក្សរកាត់

| | |
|---|---|
| CAMCONTROL | អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ អាហារ័ណ នីហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) |
| $cm^3$ | ម៉ែត្រគូប |
| CPA | តំបន់ការពាររបស់សហគមន៍ |
| ELC | សម្បទានដីសេដ្ឋកិច្ច |
| FA | រដ្ឋបាលព្រៃឈើ |
| FOB | ការដឹកជញ្ជូនដល់កប៉ាល់ |
| ha | ហិកតា |
| HRC | គណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ |
| ICCA | តំបន់អភិរក្សរបស់សហគមន៍ជនជាតិដើមភាគតិច |
| ICCPR | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធពលរដ្ឋ និងនយោបាយ |
| IUCN | សហព័ន្ធអន្តរជាតិដើម្បីអភិរក្សធម្មជាតិ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MDK | មណ្ឌលគីរី |
| MoE | ក្រសួងបរិស្ថាន |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NTFP | ផល-អនុផលព្រៃឈើ |
| p. | បុគ្គល |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RTK | រតនៈគីរី |
| S4S | ទម្រង់សាច់ឈើឈូសស្មើបួនជ្រុង |
| TPG | ក្រុមហ៊ុនទ្រី ភាព គ្រុប |
| TTR | ការទូទាត់តាមចរន្តអគ្គីសនី |
| VNP | ឧទ្យានជាតិវីរៈជ័យ |
| VSSPCA | តំបន់អភិរក្សវ៉ឺនសៃ សៀមប៉ាង |

# សេចក្តីសង្ខេប

របាយការណ៍នេះ បង្ហាញពីលទ្ធផលនៃការសិក្សាស្រាវជ្រាវស្តីពីការបំផ្លិចបំផ្លាញព្រៃឈើ និងធនធានធម្មជាតិនៅក្នុងខេត្តរតនគិរី និងស្ទឹងត្រែងនៃប្រទេសកម្ពុជា។ អស់រយៈពេលជាច្រើនខែដែលក្រុមអ្នកស្រាវជ្រាវបានប្រមូលភស្តុតាង និងឯកសារច្បាប់នានា ដែលជាញឹកញាប់ពួកគេ ប្រឈមនឹងគ្រោះថ្នាក់ និងការគំរាមកំហែងអាយុជីវិត ដើម្បីកត់ត្រានូវសកម្មភាពជួញដូរឈើប្រណីតទាំងឡាយ។ លទ្ធផលនៃការស្រាវជ្រាវដែលបានបង្ហាញក្នុងរបាយការណ៍នេះ គឺមិនមានបំណងធ្វើការរិះគន់ ឬវាយប្រហាររាជរដ្ឋាភិបាលកម្ពុជា ដើម្បីស្វែងរកការកេងចំណេញផ្នែកហិរញ្ញវត្ថុ ឬ នយោបាយនោះទេ។ ការកាប់ឈើខុសច្បាប់ គឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយនៅកម្ពុជា ដែលរាជរដ្ឋាភិបាលគួរតែពង្រឹងការអនុវត្តន៏ច្បាប់ដែលកំពុងតែមានស្រាប់ ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងការកាប់បំផ្លាញព្រៃឈើនេះ។ម្យ៉ាងទៀតគួរបង្កើតឲ្យមានការស៊ើបអង្កេតលំអិតបន្ថែម ទាក់ទងនឹងបញ្ហានេះ ។

ខេត្តរតនគិរី ជាទឹកដីសម្បូរទៅដោយធនធានធម្មជាតិ និងជាតំបន់ព្រៃលំនៅដ្ឋានរបស់សហគមន៏ជនជាតិដើមភាគតិចនានា។ តាមទំនៀមទំលាប់សហគមន៍ទាំងនេះ បានប្រើប្រាស់ព្រៃឈើបន្ទាប់បន្សំសំរាប់ដំណាំកសិកម្មវិលជុំ និងបានប្រមូលផល-អនុផលព្រៃឈើ ដើម្បីជួយទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគាត់។ ក្នុងរយៈពេល១០ឆ្នាំកន្លងមកនេះ រដ្ឋាភិបាលបានផ្តល់សម្បទានដីសេដ្ឋកិច្ចឲ្យក្រុមហ៊ុននានា ដើម្បីកាប់ឈើក្នុងតំបន់។ ក្រុមហ៊ុនទាំងនោះបានកំពុងកាប់បំផ្លាញព្រៃឈើក៏ដូចជាដីកសិកម្មរបស់សហគមន៏ជនជាតិដើមភាគតិច ដើម្បីឈូសឆាយដីសំរាប់ដំណាំឧស្សាហកម្ម ជាពិសេសដំណាំកៅស៊ូ។

នៅក្នុងខេត្តរតនគីរី យ៉ាងហោចណាស់មានក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន ៣៤ ក្រុមហ៊ុន ដែលកំពុងប្រតិបត្តិការលើផ្ទៃដីទំហំជាង ២៣២ ១៦៨ ហិកតា។ បន្ថែមពីលើនេះក៏មានក្រុមហ៊ុន១១ ដែលបានទទួលសិទ្ធិធ្វើការជីករករ៉ែលើផ្ទៃដីជាង ៥៨៨ ៦៣២ ហិកតា និងមានតំបន់សេដ្ឋកិច្ចពិសេសដ៏ធំមួយកន្លែង នៅស្រុកអូរយ៉ាដាវដែលគ្របដណ្តប់លើផ្ទៃដីទំហំជាង១៣៦ហិកតា។ សរុបជារួមក្រុមហ៊ុនទាំងនោះកំពុងប្រតិបត្តិការលើផ្ទៃដី ៨២០ ៩៣៦ ហិកតា ក្រោមរូបភាពសម្បទាន។

ទោះបីជាយ៉ាងណាក៏ដោយ ការកាប់ឈើនៅតែកំពុងបន្តនៅក្នុងតំបន់ព្រៃឆ្ងាយស្ថិតនៅខាងក្រៅតំបន់សម្បទានដីសេដ្ឋកិច្ចទាំងនេះ។ ក្នុងរយៈពេលបួនឆ្នាំចុងក្រោយនេះចាប់តាំងពីក្រុមហ៊ុនទ្រី ភាពគ្រុប (TPG) និងក្រុមហ៊ុនកាប់ឈើដទៃទៀតបានចូលមក ធនធានធម្មជាតិ ជាពិសេសព្រៃឈើនៅក្នុងតំបន់នេះត្រូវបានវិនាស ហិនហោចដែលការកាប់ឈើគឺមានការកើនឡើងរហូតដល់ចំងាយ ១០ គីឡូម៉ែត្រ ក្នុងមួយខែ។ ដោយយោងទៅលើការគណនាចំនួនរថយន្ត ដឹកឈើ និងចំនួនឈើដែលបានដឹកជញ្ជូនក្នុងមួយរថយន្តគេបានធ្វើការ

ប៉ាន់ប្រមាណថា យ៉ាងហោចណាស់ឈើប្រហែល ៨១ ០០០ ដើម ឬស្មើនឹង២៤៣ ០០០ ម៣ ត្រូវបានគេដឹកចេញពីព្រៃនៃភាគខាងជើងខេត្តរតនគីរី និងស្ទឹងត្រែង នៅក្នុងឆ្នាំ២០១៤។ របាយការណ៍នេះក៏បង្ហាញពីយុទ្ធសាស្រ្តនានារបស់ក្រុមហ៊ុនទ្រី ភាព ក្នុងការប្រមូលឈើប្រណីតពីក្នុងដែនការពារជំរកសត្វព្រៃ ពីតំបន់ព្រៃការពារ និងពីឧទ្យានជាតិផងដែរ។

ចាប់តាំងពីដើមឆ្នាំ២០១៣ ព្រៃឈើមួយភាគធំត្រូវបានបាត់បង់ទាំងស្រុង។ ផ្លូវជាច្រើន ដែលគេបានប្រើប្រាស់សំរាប់ដឹកឈើប្រណីតត្រូវបានរកឃើញនៅក្នុងតំបន់ការពារនៃឧទ្យានជាតិវីរៈជ័យដែលលាតសន្ធឹងរហូតដល់ព្រំដែនប្រទេសឡាវ។ តំបន់ទាំងនេះ ត្រូវបានកាប់បំផ្លាញដោយមេការរបស់ក្រុមហ៊ុនទ្រី ភាពគ្រុប និងថៅកែឈើជាច្រើននាក់ទៀត។ ក្រុមហ៊ុនកាប់ឈើជាច្រើនបានចាកចេញពីតំបន់អភិរក្សសត្វព្រៃលំផាត់ និងតំបន់ព្រៃស្រោងផ្សេងទៀត ដោយសារការផ្គត់ផ្គង់ឈើនាពេលបច្ចុប្បន្នត្រូវបានបញ្ចប់។ បច្ចុប្បន្ននេះព្រៃឈើកាន់តែរិចរិល ហើយសហគមន៍ពុំមានលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ និងការពារព្រៃឈើទាំងនោះ ទៀតឡើយ។ សព្វថ្ងៃនេះ តំបន់នៅស្រុកកូនមុំ លំផាត់ អណ្តូងមាស វ៉ឺនសៃ អូរជុំ និងតំបន់ខ្លះនៅ តាវែង ត្រូវបានគេសង្កេតឃើញថា បានក្លាយជាវាលល្ហឹងល្ហើយអស់ទៅហើយ។ បច្ចុប្បន្ននេះព្រៃឈើដែលនៅសេសសល់ក្នុងខេត្តរតនគិរី បានប្រឈមទៅនឹងការបំផ្លិចបំផ្លាញជារៀងរាល់ថ្ងៃដែលភាគច្រើនស្ថិតក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ ពិសេសតំបន់លើកំពូលភ្នំ ជិតព្រំប្រទល់ប្រទេសឡាវ។

ដើម្បីបំពេញនូវតម្រូវការខ្ពស់នៃឈើប្រណីត ប្រភេទឈើកម្រជាច្រើនត្រូវបានកំពុងកាប់រំលំឬបាត់បង់ដែលក្នុងនោះអាជ្ញាធរមូលដ្ឋាន និងសហគមន៍ ក៏បានចូលរួមចំណែកផងដែរព្រោះពួកគេយល់ថាវាអាចមានលទ្ធភាពរកប្រាក់ចំណូលបានខ្ពស់ និងជួយលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេឲ្យកាន់តែប្រសើរ ប៉ុន្តែអ្វី ដែលគួរឲ្យព្រួយបារម្ភណ៍នោះ គឺសហគមន៍ជនជាតិដើមភាគតិចជាច្រើន កំពុងតែប្រឈមមុខនឹងការបាត់បង់អត្តសញ្ញាណរបស់ខ្លួនដោយសារតែពួកគេជាប់ពាក់ព័ន្ធនឹងការកាប់ឈើ និងជាឈ្មួញរកស៊ីឈើប្រណីត។ សហគមន៍ ព្រៃឈើជាច្រើន បានផ្លាស់ប្តូរផ្នត់គំនិតពីការចង់អភិរក្សព្រៃឈើ ហើយបែរជាទៅសហការណ៍រកស៊ីជាមួយនឹងអ្នកកាប់ឈើ ដើម្បីរកប្រាក់ទៅវិញ។

អត្ថប្រយោជន៏ភ្លាមៗដែលបានមកពីការកាប់ឈើ គឺការកើនឡើងនៃទ្រព្យសម្បត្តិ ប៉ុន្តែផលប៉ះពាល់ទៅថ្ងៃមុខរយៈពេលវែងនោះគឺ សហគមន៍នឹងកាន់តែក្រទៅៗ ដោយសារតែការបាត់បង់ធនធានធម្មជាតិ និងអនុផលព្រៃឈើជាច្រើនត្រូវបានគេបំផ្លិចបំផ្លាញ។ ការបាត់បង់សត្វព្រៃអ្នកទេសចរណ៍លែងមកកំសាន្តក្នុងតំបន់នេះហើយផ្លូវជាច្រើនបានខូចខ្ទេចខ្ទីដោយសារទម្ងន់នៃឡានដឹកឈើរបស់ក្រុមហ៊ុន។ ប្រភេទសត្វព្រៃដ៏កម្រជាច្រើនដូចជាបក្សាបក្សី សណ្តាន សត្វល្មូន វានរសត្វ និងពពួកសត្វស៊ីសាច់ជាអាហារដូចជាខ្លា គោជាដើម ដែលបានបាត់បង់នៅក្នុងប្រទេសជាច្រើន កំពុងទទួលរងនូវការគំរាមកំហែង។ សណ្តានសត្វ

ទាំងនោះ រួមមានសត្វ ទោចប្រភេទថ្មី ប្រចៀវ និងសត្វល្អូន ត្រូវបាន អ្នកវិទ្យាសាស្ត្រកត់ត្រារាប់បញ្ចូលថាជាប្រជាជនមួយនៅក្នុងព្រៃទាំងនេះ។

អាជ្ញាធរមូលដ្ឋាន និងសហគមន៍បានធ្វើការប្តឹងចោទក្រុមហ៊ុនទ្រី ភាពគ្រុបថា សកម្មភាពកាប់ឈើរបស់ក្រុមហ៊ុន បានធ្វើឲ្យអន្តរាយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងបានបំផ្លិចបំផ្លាញធនធានធម្មជាតិ ដោយមិនមានការអភិវឌ្ឍន៍អ្វីទាំងអស់ដល់សហគមន៍។ ពួកគេចោទប្រកាន់ក្រុមហ៊ុនថា បានមកកាប់ប្រមូល និងដឹកជញ្ជូនឈើប្រណីតពីតំបន់ខ្លួនអស់ ហើយបន្ទាប់មកក៏បានផ្លាស់ទីតាំងទៅតំបន់ព្រៃដ៏ទៃទៀតដែលសំបូរឈើប្រណីត ដោយមិនមានសំណង ឬ ជួសជុលការខូចខាត ដែលបានបង្កឡើងទាល់តែសោះ។

របាយការណ៍នេះ បានធ្វើការអង្កេតពីសកម្មភាពនានារបស់ក្រុមហ៊ុនទ្រី ភាពគ្រុប រួមមានរចនាសម្ព័ន្ធ ការចែកចាយ និងដឹកជញ្ជូនឈើប្រណីត ថៅកែឈើ និងមេការនានារបស់ក្រុមហ៊ុន។ របាយការណ៍នេះក៏បង្ហាញពីមូលហេតុនៅពីក្រោយនៃការបាត់បង់ព្រៃឈើ អាជ្ញាប័ណ្ណប្រមូលឈើផ្តាច់មុខ ដំណើការផលិត និងដឹកជញ្ជូនឈើចេញទៅបរទេសដែលរដ្ឋាភិបាលបានលួចផ្តល់ជាសំងាត់ និងបរិមាណឈើដ៏ច្រើនសន្ធឹកសន្ធាប់ដែលបានឆ្លងកាត់តាមកំពង់ផែអន្តរជាតិ តាមច្រកព្រំដែន វ៉ាលី ខេត្តក្រចេះ និងច្រកអន្តរជាតិអូរយ៉ាដាវ ខេត្តរតនគិរី។ របាយការណ៍នេះក៏បានបង្ហាញផងដែរពីភាគផលហិរញ្ញវត្ថុ ឬតម្លៃដឹកជញ្ជូនឈើប្រណីត ដែលអាជ្ញាធរ មូលដ្ឋាន មន្ត្រីរដ្ឋាភិបាល បានធ្វើការកំណត់/ទាររកកំរៃពីការអនុវត្តន៍ច្បាប់ការពារព្រៃឈើ។ មន្ត្រីអភិរក្ស កងកំលាំងប្រដាប់អាវុធ និងសហគមន៍ព្រៃឈើក៏ជាអ្នកជាប់ពាក់ព័ន្ធជាមួយនឹងប្រតិបត្តិការឈើនេះផងដែរ។ យ៉ាងហោចណាស់ ក៏មាន២៥ ស្ថាប័ន ចាប់ពីថ្នាក់មូលដ្ឋាន ទៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ពិសេសអាជ្ញាធរតាមព្រំដែន និងកងកំលាំងប្រដាប់អាវុធនានា ដែលបានដាក់ពង្រាយនៅតាមផ្លូវ ក៏ជាប់ពាក់ព័ន្ធ នឹងការយកប្រាក់ពីអ្នកដឹកជញ្ជូនឈើខុសច្បាប់ផងដែរ។

នៅក្នុងបរិបទនេះ របាយការណ៍បានធ្វើការឆ្លុះបញ្ចាំងផងដែរពីភាពអស់សង្ឃឹមរបស់ក្រុមអ្នកការពារព្រៃឈើទាក់ទងនឹងភាពកង្វះឆន្ទៈ និងភាពបរាជ័យរបស់ស្ថាប័នពាក់ព័ន្ធរដ្ឋក្នុងការចាត់វិធានការការពារព្រៃឈើ និងអនុញ្ញាតិឲ្យមាន ការរកស៊ីកាប់ឈើខុសច្បាប់ និងការទទួលយកនូវសំណូកសូកប៉ាន់នៅគ្រប់ជាន់ថ្នាក់ និងការចូលរួមរបស់សហគមន៍ព្រៃឈើដែលពួកគេបានជឿលើការល្បួងថា វានឹងជួយធ្វើឲ្យជីវភាពរស់នៅរបស់ពួកគេកាន់តែប្រសើរឡើងនោះ។

ការវិភាគមួយទាក់ទងនឹងផ្នែកច្បាប់បានរកឃើញថា សកម្មភាពរបស់ក្រុមហ៊ុនទ្រី ភាពគ្រុប នៅក្នុងខេត្តរតនគីរី និងស្ទឹងត្រែង បានរំលោភលើច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់អន្តរជាតិក្រោមមធ្យោបាយជាច្រើន រួមមានការគិបកេងបន្លំពន្ធលើប្រាក់ចំណូលពីថវិការដ្ឋកង្វះតម្លាភាព និងការប្រឹក្សាយោបល់អំពីការផ្តល់កិច្ច សន្យាកាប់ឈើ ការកាប់ឈើ

រីករាលដាលចូលទៅ ក្នុងតំបន់ការពារ និងការធ្វើឯកសារក្លែងបន្លំ ដូចជាទំនិញពិតប្រាកដ ដែលត្រូវបាននាំចេញនោះគឺ វាខុសពីប្រភេទទំនិញដែលបានចុះបញ្ជី។ ការក្លែងបន្លំឯកសារ នេះ ដោយរាប់បញ្ចូលទាំងទំហំឈើនាំចេញមានកំរាស់ក្រាស់ជាង២៥សមដែលច្បាប់បាន ហាមឃាត់។

បន្ថែមពីលើសេចក្តីព្រួយបារម្មណ៍នាពេលបច្ចុប្បន្ន គឺការព្យាករណ៍មួយដែលតម្រូវ ការឈើ នៅក្នុងឆ្នាំ២០១៨នឹងកើនរហូតដល់៣៥៨ ៩៣៩ម៉ែត្រគូប ច្រើនជាង បណ្តាឆ្នាំមុនៗ ដែល មានត្រឹមតែ ២៦២ ៥១១ ម៉ែត្រគូប នៅឆ្នាំ២០០៨ និងចំនួន៣១៨ ៣៨៣ ម៉ែត្រគូប នៅឆ្នាំ២០១៣ តែប៉ុណ្ណោះ។ តួលេខទាំងនេះត្រូវបានបរិយាយនៅក្នុងបទបង្ហាញដោយ តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅក្នុងមហាសន្និបាតសភាពាណិជ្ជកម្ម កម្ពុជា អឺរ៉ុប (EuroCham Cambodia) កាលពីថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៣ ។ តួលេខទាំងនេះ បង្ហាញឲ្យឃើញថា រដ្ឋាភិបាលមានទំនោរចង់ឲ្យការ កាប់ឈើនៅតែបន្តកើតឡើង ម្យ៉ាងវាប ង្ហាញផងដែរពីភាពកង្វះឆន្ទះដើម្បីកាត់បន្ថយ ឬទប់ស្កាត់វិនាសកម្មនៃការបាត់បង់ព្រៃឈើ។ ព្រៃឈើកាន់តែធ្លាក់ចុះពីមួយថ្ងៃទៅ មួយថ្ងៃ ប៉ុន្តែតម្រូវការឈើកាន់តែកើនឡើងជាលំដាប់។

របាយការណ៍នេះបានផ្តល់អនុសាសន៍ដល់ប្រទេសមួយចំនួនដូចជា៖ ចិន វៀតណាម ឡាវ សហគមន៍អឺរ៉ុប ដែលជាទីផ្សារប្រយោល និងបណ្តាប្រទេសដ៏ទៃទៀត រួមមានសហរដ្ឋ អាមេរិកជាដើម គួរបញ្ឈប់ការទិញឈើប្រណីតដែលមានប្រភពមកពីប្រទេសកម្ពុជា។ ប្រសិន បើគ្មានមនុស្សចង់ទិញឈើ ក៏មិនមានការកាប់ដែរ។ ចំពោះរាជរដ្ឋាភិបាលវិញគួរតែលុបអាជ្ញា ប័ណ្ណរបស់ក្រុមហ៊ុនទ្រីភាពគ្រុប ដែលត្រូវបានគេមើលឃើញថា ជាមូលហេតុចំបងនៃវិនាស កម្មព្រៃឈើនៅកម្ពុជា។ រាជរដ្ឋាភិបាល ត្រូវតែធ្វើកំណែទម្រង់គោលនយោបាយនានាទាក់ ទងព្រៃឈើ ពង្រឹងប្រសិទ្ធភាពនៃកិច្ចការពារព្រៃឈើ និងការអនុវត្តន៍ច្បាប់ ហើយបញ្ឈប់ការ នាំឈើចេញគ្រប់ប្រភេទ ជាពិសេសឈើកែច្នៃគ្រឿងសង្ហារឹមដែលជាមូលហេតុចំបងនៃ វិនាសកម្មព្រៃឈើនេះ។ ធ្វើការផ្សព្វផ្សាយព័ត៌មានឲ្យបានទូលំទូលាយដល់សហគមន៍ព្រៃ ឈើ ជំរុញលើកទឹកចិត្តឲ្យអ្នកជំនាន់ក្រោយក្រោកឈរឡើង ដើម្បីធ្វើការទាមទារនិងការពារ ព្រៃឈើដែលនៅសេសសល់ ឲ្យបានគង់វង្ស ។

# ១. សេចក្តីផ្តើម

ក្នុងរយៈពេល១០ទៅ ១៥ឆ្នាំកន្លងមកនេះ ទេសភាពនៅខេត្តរតនគិរីមានការប្រែប្រួលធ្លាក់ចុះគួរឲ្យបារម្មណ៏ ដោយការបំលែងព្រៃឈើរាប់ម៉ឺនហិកតាជំនួសដោយដើមកៅស៊ូ និងដំណាំកសិឧស្សាហកម្មរាប់ម៉ឺនហិកតាទៅវិញ។ ព្រៃឈើធម្មជាតិដែលធ្លាប់ជាជម្រករបស់ជនជាតិដើមភាគតិចចំនួន ៧ ក្រុមផ្សេងៗគ្នា និងជាប្រភពនៃអនុផលព្រៃឈើសំខាន់សម្រាប់សុវត្ថិភាពជីវភាពរស់នៅ និងប្រភពសេដ្ឋកិច្ចរបស់សហគមន៍ទាំងនោះ។ ប្រព័ន្ធកសិកម្មជឿនលឿនខ្ពស់ និងប្រកបដោយផ្លែផ្កានៅតំបន់ខ្ពង់រាបរបស់សហគមន៍ជនជាតិដើមភាគតិចទាំងនេះ គឺត្រូវបានគេដាក់បញ្ចូលទៅក្នុងព្រៃឈើដែលជាភូមិអាករបស់ពួកគេទាំងអស់។

ជនជាតិដើមភាគតិច បានថែរក្សាព្រៃឈើឲ្យគង់វង្សអស់ជាច្រើនជំនាន់កន្លងមកហើយ។ តំបន់ព្រៃឈើ និងភូមិសាស្ត្រខ្លះទៀត គឺសំខាន់ណាស់សំរាប់ជនជាតិដើមភាគតិចរួមមាន៖ ព្រៃអារក្សព្រៃដូនតា/ព្រៃទីស្មសាននិងព្រៃជំនឿជាមូលដ្ឋានគ្រឹះនៃប្រពៃណី និងជំនឿអ្នកប្រកាន់វិញ្ញាណនិយម ដែលបានថែរក្សាវប្បធម៌ទំនៀមទំលាប់ជនជាតិដើមភាគតិច។ ព្រៃឈើទាំងនេះ ក៏ជាជំរករបស់សត្វព្រៃប្រភេទកំរនានាដែលមានសារៈសំខាន់បំផុតសំរាប់ធ្វើការអភិរក្ស (បញ្ជីក្រហមរបស់សម្ព័ន្ធអង្គការអភិរក្សធម្មជាតិពិភពលោកIUCN)[1]។

ដោយសារតែព្រៃឈើ ភូមិកំណើត និងវាលស្រែចំការរបស់ជនជាតិដើមភាគតិច ត្រូវបានគេដកហូត និងបំផ្លិចបំផ្លាញដោយការអនុវត្តន៍សម្បទានដីសេដ្ឋកិច្ច និងការកាប់ឈើខុសច្បាប់ ដែលជាហេតុបណ្តាលឲ្យជីវភាពរស់នៅសុវត្ថិភាពសេដ្ឋកិច្ច និងវប្បធម៌នានារបស់សហគមន៏ជនជាតិដើមភាគតិចទាំងនេះ កំពុងទទួលរងនូវការបំផ្លិចបំផ្លាញ។ ខណៈដែល "ក្រមសីលធម៌បែប អភិរក្ស " របស់សហគមន៍ជនជាតិដើមភាគតិចជាច្រើននៅតែរក្សាបាននូវភាពរឹងមាំស្រាប់តែមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស និងសម្មើមលើបរិស្ថានធម្មជាតិនៅក្នុងភូមិកំណើតរបស់ពួកគេដែលធ្វើឲ្យភាពអន់ខ្សោយដល់ក្រមសីលធម៌ទាំងនេះ។ ចាស់ទុំម្នាក់របស់សហគមន៍ជនជាតិដើមភាគតិចព្រៅ បានមានប្រសាសន៏ថា៖ "នៅពេលផ្លូវបានសាងសង់រួច អ្នកមកពីក្រៅក៏បានចូលមក។ ពួកគេប្រាប់យើងថា ព្រៃឈើ និងដីរបស់យើងនោះមិនមែនជាកម្មសិទ្ធិរបស់យើងទេ។ រដ្ឋាភិបាល បានផ្តល់ព្រៃឈើរបស់យើងឲ្យទៅក្រុមហ៊ុនអស់ ដូច្នេះ យើងមិនអាចប្រើប្រាស់ព្រៃឈើ ឬដាំដុះនៅលើដីរបស់យើងបានតទៅទៀតទេ។ អ្នកភូមិឃើញអ្នកមកពីក្រៅមាន និងជាមនុស្សមានអំណាច ហើយមានប៉ូលីសមកជាមួយផងដែរ។ អ្នកភូមិឃើញអ្នកមកពីក្រៅកាប់រំលំដើមឈើ យកទៅលក់ដើម្បីប្រាក់។ តើយើងអាចធ្វើអ្វីបានខ្លះ? សហគមន៍បាត់បង់សាមគ្គីភាពរបស់ខ្លួន និងការគោរពចំពោះ

[1] បញ្ជីក្រហមចំពោះប្រភេទដែលទទួលរងការគម្រាមកំហែងរបស់អង្គការសហភាពអន្តរជាតិ ដើម្បីការអភិរក្សធម្មជាតិ (IUCN) គឺជាបញ្ជីបញ្ជាក់ពីស្ថានភាពប្រភេទជីវសាស្រ្តអភិរក្សជាសកលរបស់ពិភពលោកដែលមានលក្ខណៈទូលំទូលាយបំផុត។សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់ http://www.iucn.org/

ចាស់ទុំ។ ពួកគេឃើញអ្នកមកពីក្រៅបានក្លាយជាអ្នកមានដោយសារតែឈើរបស់យើង ដូច្នេះ អ្នកភូមិមួយចំនួនក៏បានកាប់ឈើយកទៅលក់ដែរ យ៉ាងហោចណាស់យើងអាចបានប្រាក់ខ្លះ មុនពេលដែលព្រៃឈើទាំងអស់របស់យើងត្រូវបានបាត់បង់ទាំងស្រុង”។

ខេត្តរតនគិរី មានផ្ទៃដីសរុបទំហំ ១០៧ ៨២០០ ហិកតា ក្នុងនោះគម្របព្រៃឈើ មានទំហំ ១០០ ២៥៦០ហិកតា ស្មើនឹង៨៥%នៃផ្ទៃដីទាំងមូល[2]។

គិតមកដល់ឆ្នាំ២០១៤ យ៉ាងហោចណាស់មានក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន ៣៤ កំពុងប្រតិបត្តិការនៅក្នុងខេត្តរតនគិរី ដែលគ្របដណ្តប់លើផ្ទៃដីទំហំជាង ២៣២ ១៦៨ ហិកតា និងមានក្រុមហ៊ុនចំនួន១១ដែលទួលបានសិទ្ធិ ឬសម្បទាន ដើម្បីជីករករ៉ែ លើផ្ទៃដី ទំហំ ជាង៥៨៨ ៦៣២ហិកតា និងមានតំបន់សេដ្ឋកិច្ចពិសេស ធំមួយកន្លែង មានទីតាំងក្នុង ស្រុកអូរយ៉ាដាវ ដែលគ្របដណ្តប់លើផ្ទៃដីទំហំ ១៣៦ ហិកតា។ ផ្ទៃដីសរុបក្រោមរូបភាព សម្បទានមាន ទំហំ ៨២០ ៩៣៦ ហិកតា ។

តំបន់ព្រៃដែលកំពុងនៅសល់(១៨១ ៦២៤ ហិកតា) មិនបានរងផលប៉ះពាល់ពីសម្បទាន ភាគច្រើនស្ថិតក្នុងឧទ្យានជាតិវីរៈជ័យ និងតំបន់ការពារដែលបានការអនុម័តនិងចុះបញ្ជីដោយ រដ្ឋាភិបាល[3]។ តំបន់ការពារទាំងនេះរួមមាន៖

១. ឧទ្យានជាតិវីរៈជ័យ មានទំហំជាង ៣៣២ ៥០០ ហិកតា ស្ថិតក្នុងខេត្តរតនគិរី និង នៅជាប់នឹងខេត្តស្ទឹងត្រែង ដែលបានការពារដោយព្រះរាជក្រឹត្យក្នុងឆ្នាំ១៩៩៣។

២. ដែនជម្រកសត្វព្រៃលំផាត់ មានទំហំជាង ២៥០ ០០០ ហិកតា ដែលមានទីតាំងស្ថិត នៅក្នុងខេត្តរតនគិរី និងនៅជិតខេត្តមណ្ឌលគិរី ដែលបានការពារដោយព្រះរាជក្រឹត្យ ឆ្នាំ១៩៩៣។

៣. តំបន់អភិរក្សវ៉ឺនសៃ សៀមប៉ាង មានទំហំជាង៥៥ ០០០ ហិកតា។

៤. តំបន់ការពារសហគមន៍(CPA) រួមមានសហគមន៍អូរចាយផ្ទៃដី ២៨០១ ហិកតា សហគមន៍អូរទុង ផ្ទៃដីទំហំ ៩ ៨៦២ ហិកតា សហគមន៍អូរតាបូក ផ្ទៃដី២ ៨០០ ហិកតា សហគមន៍អូរកំផាក ផ្ទៃដី២ ៣៨៣ហិកតា និងសហគមន៍មណ្ឌលយ៉ន ផ្ទៃដី៥៥០ ហិកតា[4] និងនៅមានព្រៃសហគមន៍ជាច្រើនៗជាងនេះថែមទៀត។ តំបន់ការពារសហគមន៍ដែលបានរៀបរាប់ទាំងនេះស្ថិតនៅ ភាគខាងត្បូង និងភាគ ខាងលិចនៃឧទ្យានជាតិវីរៈជ័យ។

---

[2] ទិន្នន័យពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០០២

[3] ការគណនាទិន្នន័យសម្បទានដីសេដ្ឋកិច្ច និងសម្បទានរ៉ែ ប្រភពពីលីកាដូ និងទិន្នន័យពីការអភិវឌ្ឍ (ODC)

[4] ប្រកាសរបស់ក្រសួងបរិស្ថានលេខ ១៦០/១៦១/១៦២/១៦៣/១៦៤ ចុះថ្ងៃទី ២១ ខែកក្កដា ២០០៦

នៅក្នុងឧទ្យានជាតិវីរៈជ័យ យ៉ាងហោចណាស់មាន៨ ក្រុមហ៊ុន ដែលបានទទួលដីសម្បទានសេដ្ឋកិច្ចដែលគ្របដណ្តប់លើផ្ទៃដីទំហំ ៦៥ ១៤៩ហិកតា។ ក្រុមហ៊ុនទាំងនោះបានកាប់ឈើ ដករំលើងដើមឈើទាំងឫសនិងដាំដើមកៅស៊ូជំនួស។ ក្រុមហ៊ុនទាំងនេះមានរាយឈ្មោះដូចខាងក្រោមៈ

១. ក្រុមហ៊ុន ស្រ៊ុន សុវណ្ណភូមិ (Srun Suvanaphum Co., Ltd., ស្ថិតនៅក្នុងតំបន់កន្ទុយនាគនៃឧទ្យានជាតិវីរៈជ័យ មានទំហំ១០ ៦២៤ ហិកតា

២. ក្រុមហ៊ុនទ្រីភាព អ៊ឹមឌីអេស អ៊ីមផត អ៊ិចផត (Try Pheap MDS Import Export Co., Ltd.) និងក្រុមហ៊ុនទ្រីភាពអ៊ីមផត អ៊ិចផត (Try Pheap Group Import Export Co., Ltd.) មានទំហំ ១៨ ៧៣៥ ហិកតា ទោះជាយ៉ាងណាក្រសួងបរិស្ថានបានប្រកាសកាលពីថ្ងៃទី៦ ខែមករាឆ្នាំ២០១៥ ថាក្រុមហ៊ុនទ្រីភាពបានស្ម័គ្រចិត្តផ្តល់សម្បទានទាំងពីរត្រលប់មកវិញ។ ប៉ុន្តែវា ត្រូវបានគេធ្វើការកត់សំគាល់ឃើញថា ការផ្តល់សម្បទានទាំងនេះ ត្រលប់មកវិញធ្វើឡើងបន្ទាប់មកមានការកាប់ឈើប្រណីតអស់នៅតំបន់នោះ។

៣. ក្រុមហ៊ុនហុង អាញអណ្តូងមាស (Hong An Andong Meas Co., Ltd) មានទំហំ ៩ ៧៧៥ ហិកតា

៤. ក្រុមហ៊ុនវិនិយោគនូភាព សុភី (Noupheap Sophy Investment Co., Ltd.) មានទំហំ ៩ ០០០ ហិកតា

៥. ក្រុមហ៊ុនហ្វូសេងហៃ (Fu Sheng Hai Co., Ltd.,) មានទំហំ៧ ០៧៩ ហិកតា <u>(ដកហូតសិទ្ធិវិនិយោគដោយក្រសួងបរិស្ថាន នៅខែមករាឆ្នាំ២០១៥)</u>

៦. ក្រុមហ៊ុនជីងហ្សុងទាន (Jing Zhoung Tian Co., Ltd.,) មានទំហំ៩ ៩៣៦ ហិកតា <u>(ដកហូតសិទ្ធិវិនិយោគដោយក្រសួងបរិស្ថាន នៅខែមករាឆ្នាំ២០១៥)</u>

លើសពីនេះ ក៏មានក្រុមហ៊ុនអ៊ីនឌូឆៃណារីហ្សូស (Indochine Resources Co., Ltd.) ទទួលបានសម្បទានរ៉ែមួយកំពុងរុករកធនធានរ៉ែគ្របដណ្តប់លើផ្ទៃដីទំហំ ២៩០ ០០០ ហិកតា នៅក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ និងតំបន់អភិរក្សវ៉ឺនសៃសៀមប៉ាង ផងដែរ។

# ២. សេចក្តីសង្ខេបរបាយការណ៍

របាយការណ៍នេះ បង្ហាញពីលទ្ធផលនៃការស៊ើបអង្កេត និងស្រាវជ្រាវទៅលើការកាប់បំផ្លាញព្រៃឈើ និងធនធានធម្មជាតិនៅខេត្តរតនគិរី និងស្ទឹងត្រែងនៃប្រទេសកម្ពុជា។ តាមគោលគំនិតទូទៅដែលបានបង្ហាញខាងលើ គឺរកឃើញថាបរិបទនៃការកាប់ឈើនៅខេត្តរតនគិរីជាមូលហេតុបណ្តាលឲ្យមានវិនាសកម្មព្រៃឈើនៅក្នុងតំបន់នេះ។ មូលហេតុចំបងដែលបានរកឃើញនោះគឺតំរូវការប្រភេទឈើប្រណីតពិសេសពីប្រទេសចិន និងវៀតណាម ។ ការផ្តល់សម្បទានដីសេដ្ឋកិច្ចដោយរដ្ឋាភិបាល កង្វះខាតការអនុវត្តន៍ច្បាប់ត្រួតពិនិត្យការកាប់ឈើដែលមានស្រាប់ព្រម ទាំងអសមត្ថភាពរបស់សហគមន៍ក្នុងការការពារព្រៃឈើ ដែលប្រឈមមុខនឹងការ គាបសង្កត់ពីខាងក្រៅ។ បន្ទាប់មករបាយការណ៍នេះ ស៊ើបអង្កេតទៅលើអាជីវកម្មឈើប្រណីតរួមបញ្ចូលទាំងតម្លៃឈើនៅទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ ព្រមទាំងប្រតិបត្តិការនានារបស់ក្រុមហ៊ុនរកស៊ីឈើ ជាពិសេស ទ្រី ភាព គ្រុប(TPG)។ របាយការណ៍បានពិនិត្យមើលពីផលប៉ះពាល់នៃវិនាសកម្មព្រៃឈើក្នុងតំបន់នេះ រាប់បញ្ចូលការបាត់បង់ប្រាក់ចំណូល និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលពឹងផ្អែក លើការប្រើប្រាស់ព្រៃឈើ រួមមានចំណូលមកពីវិស័យទេសចរណ៍ធម្មជាតិ ការបាត់បង់មច្ឆាជាតិ និងសត្វព្រៃ ការបាត់បង់ប្រព័ន្ធជំនឿជាមូលដ្ឋានដែលជាគុណតម្លៃក្នុងកិច្ចការពារថែរក្សាព្រៃឈើក្នុងស្រុក ព្រមទាំងការបាត់បង់ជាបណ្តើរៗនូវកំលាំងចិត្ត ឬការលើកទឹកចិត្តនៅក្នុងសហគមន៍ ដើម្បីការពារធនធានព្រៃឈើរបស់ពួកគេ។ របាយការណ៍ក៏បានផ្តោតលំអិតផងដែរ ទៅលើប្រតិបត្តិការរបស់ក្រុមហ៊ុនទ្រី ភាពគ្រុប នៅក្នុងខេត្តរតនគីរី និងស្ទឹងត្រែង មានដូចជា៖ សិទ្ធផ្តាច់មុខដែលត្រូវបានផ្តល់ឲ្យក្រុមហ៊ុនមួយនេះ ក្នុងការទិញឈើពីដីសម្បទាននានាពីដេប៉ូឈើ និងពីតំបន់កាប់ឈើនានាដែលក្រុមហ៊ុននេះកំពុងប្រតិបត្តិការ។ រូបភាពជាច្រើនត្រូវបានបង្ហាញពីប្រតិបត្តិការកាប់ឈើ ដែលភាគច្រើនកើតមាននៅក្នុងឧទ្យានជាតិវីរៈជ័យ។ ស្តែងចេញពីសកម្មភាពនេះការនាំឈើប្រណីតចេញត្រូវបានរកឃើញថា មានចំណងពាក់ព័ន្ធធំជាមួយនឹងប្រទេសចិន។ បន្ទាប់មកទៀត យើងបង្ហាញអំពីបទវិភាគផ្អែកច្បាប់មួយ ដែលទាក់ទងការកាប់ព្រៃឈើខុសច្បាប់ដោយផ្អែកលើទស្សនៈច្បាប់នៅ កម្ពុជា និងច្បាប់អន្តរជាតិ។ យើងរកឃើញថា ប្រតិបត្តិការកាប់ឈើរបស់ក្រុមហ៊ុនទ្រី ភាពគ្រុប បានរំលោភទៅលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិនានាតាមរូបភាពជាច្រើន។ ចុងក្រោយនៃរបាយការណ៍នេះ យើងបង្ហាញអំពីការពិភាក្សាផ្អែកបច្ចេកទេស ស្តីពីការធ្វើអាជីវកម្មឈើប្រណីត រួមមានប្រភេទឈើដែលស្ថិតក្នុងតម្រូវការទីផ្សារ តម្លៃឈើនៅ និងឈើកែច្នៃ តួនាទីផ្សេងៗ របស់កម្មករក្នុងដំណាក់កាល ដំណើការកាប់ឈើ ព្រមទាំងតួនាទី និងមុខងាររបស់ក្រុមល្បាតមើលការកាប់ឈើ។ យើងបានធ្វើសេចក្តីសន្និដ្ឋានរបាយការណ៍នេះ ដោយផ្អែកលើទស្សនៈយោបល់របស់សាក្សីជាច្រើន ដែលបានសម្ភាសន៍ក្នុងដំណើរនៃការស្រាវជ្រាវ រួមទាំងអនុសាសន៍នានារបស់ក្រុមអ្នកស្រាវជ្រាវដើម្បីដោះស្រាយបញ្ហាដែលបានកំណត់។ ឧបសម្ព័ន្ធជាច្រើនបង្ហាញពីឯកសារបន្ថែមនានារួមមាន៖ តម្លៃឈើ

នៅដំណាក់កាលផ្សេងៗតាមតម្លៃជាសង្វាក់ អនុក្រឹត្យផ្តល់សម្បទានដីសេដ្ឋកិច្ចនៅក្នុងឧទ្យានជាតិវីរៈជ័យ បញ្ជីលេខកូដមេការរបស់ក្រុមហ៊ុន ទ្រី ភាព និងអ្នកដទៃផ្សេងទៀតដែលពាក់ព័ន្ធនឹងការកាប់ឈើ ចំណុចទីតាំងGPSបង្ហាញពីតំបន់សកម្មភាពកាប់ឈើ និងរោងចក្រអារឈើនៅក្នុងឧទ្យានជាតិវីរៈជ័យ ឯកសារនានារួមមានអាជ្ញាប័ណ្ណកាប់ និងទិញឈើដែលផ្តល់ជូនក្រុមហ៊ុនទ្រី ភាពគ្រុប ព្រមទាំងឯកសារនាំចេញ ដែលបង្ហាញពីការនាំចេញឈើប្រណីតទៅក្រៅប្រទេស។ ឧបសម្ព័ន្ធបញ្ចូលទាំងបញ្ជីប្រភេទឈើដែលជាគោលដៅ និងអាចជាមុខសញ្ញានៅពេលអនាគត ហើយជាឧទាហរណ៍មួយនៃកិច្ចសន្យារវាងសហគមន៍មូលដ្ឋាន និងថៅកែឈើ។ នៅពេលកិច្ចពិភាក្សានេះបានផ្តោតសំខាន់ទៅលើខេត្តរតនគិរី និងការកាប់ឈើនៅក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ (VNP) យើងក៏បានរកឃើញដែរថា ការកាប់ឈើ ក៏កំពុងកើតឡើងផងដែរក្នុងខេត្តស្ទឹងត្រែងនិងនៅក្រៅឧទ្យានជាតិវីរៈជ័យ។

# ៣.វិធីសាស្ត្រស្រាវជ្រាវ

អស់រយៈពេលជាច្រើនខែនៅក្នុងឆ្នាំ២០១៤ អ្នកស្រាវជ្រាវបានប្រមូលភស្តុតាង និងឯកសារច្បាប់ដែលជារឿយៗ ការងារនេះមានលក្ខណៈប្រថុយប្រថាន និងប្រឈមមុខនឹងគ្រោះថ្នាក់ដល់អាយុជីវិត ដើម្បីកត់ត្រាពីសកម្មភាពនានាទាក់ទងអាជីវកម្មឈើប្រណីត។

ក្រុមអ្នកស្រាវជ្រាវ បានប្រើវិធីសាស្ត្រអង្កេតអ្នកចូលរួមដោយសម្ងាត់។ ពួកគេបានអង្កេត និងចងក្រងសកម្មភាពទាក់ទងការកាប់ឈើ អារឈើ និងដំណើរការដឹកជញ្ជូនឈើដោយបានថតរូបភាពជាច្រើន និងការកត់ត្រាអំពីទីតាំងចំណុចGPS។ ពួកគេក៏បានសំភាសន៍ជាមួយ អ្នកភូមិមូលដ្ឋាន អ្នកដឹកនាំ អាជ្ញាធរ និងជាមួយអ្នកដែលបានចូលរួមក្នុងសកម្មភាពកាប់ឈើ អារឈើ និងដឹកជញ្ជូនជាដើម។ ម៉្យាងទៀត យើងបានធ្វើការស្រាវជ្រាវដោយអានឯកសារឬរបាយការណ៏នានាទាក់ទងសម្បទានដី នៅខេត្តរតនគិរី និងឯកសារដែលអនុញ្ញាតឲ្យកាប់ឈើ ដែលជាផ្នែកមួយនៃការ អនុវត្តន៍សម្បទានទាំងនេះ។ នៅចន្លោះឆ្នាំ២០១៤ និង ២០១៥ ទិន្នន័យដែលប្រមូលបានត្រូវបានបញ្ជាក់បន្ថែមយ៉ាងច្បាស់លាស់ ហើយក៏ត្រូវបានយកមកប្រើប្រាស់ ដោយក្រុមផ្សេងទៀត ដើម្បីធ្វើការពិនិត្យផ្ទៀងផ្ទាត់ពីភាពជាក់លាក់នៃព័ត៌មាន ដូចជាកំឡុងពេលពិនិត្យទៅលើរបាយការណ៏ពង្រាង និងការបកប្រែឯកសារនេះជាដើម។ គួរកំណត់សំគាល់ថា ឈ្មោះសហគមន៏ដែលបានចូលរួមផ្តល់ព័ត៌មានត្រូវបានផ្លាស់ប្តូរដើម្បីការពារអត្តសញ្ញាណរបស់ពួកគេ។

រូបិយវត្ថុ ដែលបានប្រើនៅក្នុងរបាយការណ៍នេះ គឺជាប្រាក់ដុល្លារ ឬប្រាក់រៀល ដែលអាត្រាប្តូរប្រាក់ក្នុងមួយដុល្លា ស្មើនឹង ៤ ១០០ រៀល។

# ៤. វិនាសកម្មព្រៃឈើនៅក្នុងខេត្តរតនគីរី

ដើម្បីជាផ្នែកមួយនៃការអនុវត្តន៍គោលនយោបាយសំរាប់ អភិវឌ្ឍន៍សេដ្ឋកិច្ចនៅខេត្តរតនគីរី ពិសេសការផ្តល់សម្បទានដីសេដ្ឋកិច្ចក្នុងតំបន់នេះ រដ្ឋាភិបាលបានផ្ទេរការងារក្នុងការប្រមូលឈើពីសម្បទានទាំងនេះ ហើយនាំចេញនូវឈើប្រភេទប្រណីតផ្តល់ឲ្យក្រុមហ៊ុនទ្រីភាពគ្រុប។ រដ្ឋាភិបាលបានអះអាងថាការកាប់ឈើបានអត្ថប្រយោជន៍ដល់កំណើនសេដ្ឋកិច្ចជាតិ ទោះជាយ៉ាងណាក៏ដោយការស្រាវជ្រាវនៅក្នុងរបាយការណ៍នេះបានបង្ហាញថា រដ្ឋាភិបាលថ្នាក់កណ្តាល និងអាជ្ញាធរមូលដ្ឋានបរាជ័យក្នុងការការពារទប់ស្កាត់ និងថែរក្សាព្រៃឈើហើយទឹកប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់មិនត្រូវបានចូលទៅក្នុងសេដ្ឋកិច្ចជាតិនោះទេ ផ្ទុយទៅវិញទឹកប្រាក់ទាំងនោះបានធ្លាក់ក្នុងដៃមនុស្សតែពីរបីនាក់ប៉ុណ្ណោះ។

ក្នុងបរិបទនេះ មូលហេតុចំបងនៃការបាត់បង់ព្រៃឈើនៅក្នុងតំបន់នេះ បណ្តាលមកពីតំរូវការឈើ បើទោះជាមានប្រទេសមួយចំនួន បានបញ្ឈប់ការនាំចូលឈើពីកម្ពុជា ក៏ដោយក៏ការជួញដូរឈើតាមព្រំដែនហាក់ដូចជាមិនទាន់ឈប់នៅឡើយទេ។ ទឹកប្រាក់ដែលបានមកពីទីផ្សារងងឹតតាមបណ្តាព្រំដែន ដែលជាហេតុមួយបណ្តាលឲ្យមានការកាប់ឈើខុសច្បាប់។ ការស្រាវជ្រាវផ្សេងទៀតអំពីការកាប់ឈើខុសច្បាប់ និងការជួញដូរឈើតាមព្រំដែនក្នុងតំបន់នេះ ត្រូវបានអះអាងថាតាមព្រំដែនកម្ពុជា ឡាវ ជាតួយ៉ាងមួយនៃព្រំដែនដាច់ស្រយាលដែលជាតំបន់គ្មានច្បាប់នៅក្រៅសង្គម និងនៅដាច់ឆ្ងាយពីអាជ្ញាធរថ្នាក់កណ្តាល[5]។ ទាំងអស់នេះហើយដែលជាមូលហេតុបណ្តាលឲ្យមានវិនាសកម្មព្រៃឈើនៅក្នុងតំបន់នេះ។

## ៤.១ មូលហេតុចំបងនៃវិនាសកម្មព្រៃឈើនៅកម្ពុជា

### សម្បទានដីសេដ្ឋកិច្ចផ្តល់ដោយរដ្ឋាភិបាល

ផ្តើមចេញពីការស៊ើបអង្កេតនេះ មូលហេតុចម្បងនៃវិនាសកម្មព្រៃឈើគឺ គោលនយោបាយអភិវឌ្ឍន៍ និងវិនិយោគរបស់រដ្ឋាភិបាល ដែលបានផ្តល់ដីសម្បទានសេដ្ឋកិច្ចយ៉ាងមហិមាឲ្យក្រុមហ៊ុនឯកជនសំរាប់ដាំដំណាំកសិ-ឧស្សាហកម្ម។ ក្រុមហ៊ុនទាំងនោះបានដករំលើងដើមឈើ និងឫស ដើម្បីយកដីដាំដំណាំកសិ-ឧស្សាហកម្ម ដោយជួលមានរយៈពេលយូរឆ្នាំយ៉ាងហោចណាស់ចន្លោះពី៧០ឆ្នាំ និង៩៩ឆ្នាំដែរ។ ឧទាហរណ៍ដូចជា ក្រុមហ៊ុនម៉ានយ៉ាងក្រុមហ៊ុនហុងអាញហ្គែឡាយ ក្រុមហ៊ុនទ្រី ភាពគ្រុប ក្រុមហ៊ុនជាំងលី និងក្រុមហ៊ុនអានម៉ារឌីគ្រុបជាដើម បានកាប់ផ្តួលរំលំដើមឈើខ្នាតយក្ស និងដករំលើងទាំងឫសគរទុកចោលនៅក្នុងតំបន់សម្បទានរបស់ខ្លួន។ ម៉ាស៊ីនអារឈើខ្នាតយក្ស និងម៉ាស៊ីនរ៉ៃធំៗ ត្រូវបានគេប្រទះឃើញ

---

[5] របាយការណ៍អត្ថាធិប្បាយ និងការអនុវត្តៈ ការកាប់ឈើឆ្លងដែនខុសច្បាប់នាភាគខាងជើងប្រទេសកម្ពុជា Sarinda Singh, Ethnography (2014) Vol. 15(2) page 136

អារឈើនៅក្នុងតំបន់សម្បទាននោះ ដោយសំងាត់ និងមានការយាមកាមដោយកងកំលាំងប្រដាប់អាវុធ។ សរុបមក នៅក្នុងខេត្តរតនគិរី រដ្ឋាភិបាលបានផ្តល់ដីសម្បទានសេដ្ឋកិច្ចទំហំ ២៣២ ១៦៨ ហិកតា ដែលធ្វើឲ្យដើមឈើទាំងអស់ត្រូវបានឈូសឆាយកំទេចដោយដាំកៅស៊ូជំនួសវិញ។



*រូបភាព១៖ ព្រៃឈើត្រូវបានឈូសកំទេចដោយសម្បទានិកសំរាប់ធ្វើចំការដំណាំកសិ ឧស្សាហកម្ម*



*រូបភាព២៖ប្រជាពលរដ្ឋបាតុកម្មប្រឆាំងនឹងក្រុមហ៊ុនម៉ានយ៉ាងឈូសឆាយព្រៃឈើនៅស្រុកវ៉ឺនសៃឆ្នាំ២០១៤*



*រូបភាព៣៖ សម្ភារទានិក(អានម៉ាឌី ដែលជាប់ពាក់ព័ន្ធទៅនឹងក្រុមហ៊ុនទូភាពសុភីវិនិយោគ ឈូសឆាយព្រៃឈើក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ*

### តម្រូវការឈើដោយរដ្ឋាភិបាល ដើម្បីផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងបរទេស

ក្រុមហ៊ុនទ្រី ភាពគ្រុប កំពុងកាប់ប្រមូល ដឹកជញ្ជូន និងនាំចេញឈើដោយមានអាជ្ញាប័ណ្ណពីរដ្ឋាភិបាល។ សព្វថ្ងៃនេះក្រុមហ៊ុនទ្រី ភាពគ្រុប កំពុងបំផ្លាញព្រៃឈើជាច្រើន ដោយបើកចំហរ និងជាផ្លូវការ។ មេការរបស់ក្រុមហ៊ុនទ្រីភាពគ្រុប ត្រូវបានដាក់ពង្រាយនៅក្នុងតំបន់ព្រៃការពារ(ឧទ្យានជាតិ ដែនជម្រកសត្វព្រៃ) និងតំបន់ព្រៃនានាដែលសហគមន៍ប្រើប្រាស់ និងការពារដើម្បីធ្វើការត្រួសត្រាយកាប់ព្រៃធ្វើ ផ្លូវចូលដឹកឈើប្រណីត។ តំបន់ដែលកំពុងតែកាប់ឈើឥឡូវនេះ បានឈានរហូតដល់ព្រំដែនឡាវ និងវៀតណាម។ បុគ្គលិកក្រុមហ៊ុន តំណាងអាជ្ញាធរមូលដ្ឋាន និងសហគមន៍ព្រៃឈើបានធ្វើការកត់ចំណាំថា ជារៀងរាល់ខែ ចម្ងាយព្រៃប្រមាណ ១០ គីឡូម៉ែត្រ ដែលសម្បូរទៅដោយឈើប្រណីតនោះត្រូវបានគេជ្រើសរើស។ ការស៊ើបអង្កេតរបស់យើងបានបង្ហាញថាការគណនាចំនួនឈើដែលត្រូវបានគេកាប់រំលំ និង ចំនួនឈើដែលត្រូវដឹកជញ្ជូនក្នុងមួយរថយន្ត គឺមានប្រមាណ ៨១ ០០០ដើម ឬស្មើនឹង២៤៣ ០០០ម៣ ដែលបានកាប់ក្នុងព្រៃប៉ែកខាងជើងខេត្តរតនគីរី និងស្ទឹងត្រែង ក្នុងកំឡុងឆ្នាំ២០១៤។

ដូចបានរៀបរាប់ពីខាងលើនេះ ការកាប់ឈើ គឺបណ្តាលមកពីសេចក្តីតម្រូវការដែលអ្នកទិញ គឺប្រទេសចិន វៀតណាម និងឡាវ។ កំឡុងពេលដែលជំលោះដែនកោះរវាងប្រទេស

ចិន និងវៀតណាមនាឆ្នាំ២០១៤ អាជីវកម្មឈើប្រណិត ត្រូវបានផ្អាកមួយរយៈការងារកាប់ឈើក៏ត្រូវបានពន្យារពេល ហើយអ្នកកាប់ឈើបានផ្លាស់ប្តូរកស៊ិរបរផ្សេង។ ប្រសិនបើអ្នកទិញត្រូវបានទប់ស្កាត់ពីការទិញឈើប្រណិតនោះឈើប្រភេទផ្សេងៗទៀត ត្រូវបានគេកាប់បំផ្លាញ។ ប្រទេសឡាវ វៀតណាម និងចិន ក៏បានចាប់ផ្តើមទិញឈើប្រភេទសុក្រម ធ្នឹក និងធ្នង់ផងដែរ។ បើយោងទៅលើបទបង្ហាញជាផ្លូវការរបស់តំណាងក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ (MAFF) នៅក្នុងមហាសន្និសីទប្រចាំឆ្នាំក្នុងសភាពាណិជ្ជកម្មអឺរ៉ុប-កម្ពុជា (Euro Cham-Cambodia) កាលពីថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៣ បង្ហាញឲ្យឃើញថាតម្រូវការឈើនៅឆ្នាំ២០១៨ មានរហូតដល់ ៣៥៨ ៩៣៩ម៉ែត្រគូប ដែលចំនួននេះច្រើនជាងតម្រូវការឆ្នាំមុនៗដែលមានត្រឹមតែ ២៦២ ៥១១ ម៉ែត្រគូប ក្នុងឆ្នាំ២០០៨ និងចំនួន ៣១៨ ៣៨៣ម៉ែត្រគូប ក្នុងឆ្នាំ២០១៣។ តួលេខទាំងនេះ បង្ហាញឲ្យឃើញថា រដ្ឋាភិបាលចង់ឲ្យការកាប់ឈើនៅតែបន្ត ហើយក៏វាបានបង្ហាញផងដែរពីភាពកង្វះឆន្ទៈក្នុងកាត់បន្ថយ ឬការបង្កាការកាប់បំផ្លាញព្រៃឈើ។




*រូបភាព៤៖ ការដកស្រង់ពីបទបង្ហាញរបស់មន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនាសន្និសីទពាណិជ្ជកម្ម កម្ពុជា អឺរ៉ុប*

## ការកាប់បង្ហិនបង្ហោចឈើមិនប្រណិតដោយកម្មករកាប់ឈើ

ដើម្បីឈានទៅដល់ការកាប់ឈើប្រណិតក្នុងតំបន់ព្រៃស្រោង ឈើមិនប្រណិតជាច្រើនត្រូវបានគេកាប់ផ្តួលរំលំដែលវាកាន់តែបំផ្លាញព្រៃឈើបន្ថែមទៀត។ នៅពេលដែលអ្នកកាប់ឈើចង់ចូលទៅយកដើមធ្នង់ នាងនួន បេង ឬ ក្រញូងមួយដើម ពួកគេត្រូវត្រួសត្រាយព្រៃដែលនៅជុំវិញ ដើម្បីបើកផ្លូវឲ្យរថយន្តដឹកឈើចូលទៅ។ អ្នកកាប់ឈើបានបញ្ជាក់ថា យ៉ាងហោចណាស់ដើមឈើប្រមាណ ៥០ដើម ត្រូវបានគេអារំលំ ដើម្បីចូលទៅយកឈើប្រណិតមួយដើម។ ពួកគេក៏បាននិយាយផងដែរថា នៅពេលដឹកជញ្ជូនឈើធ្ងន់ៗឡើង និងចុះភ្នំជ្រៅៗ ពួកគេត្រូវការដើមឈើធំៗធ្វើជាស្ពាន ដើម្បីឆ្លងទន្លេ ឬស្ទឹង ដូច្នេះយ៉ាងហោចណាស់មានដើមឈើធំៗប្រមាណ ៥០ ដើម ត្រូវបានកាប់រំលំសំរាប់ការដឹកជញ្ជូនមួយជើង។ មានន័យថា យ៉ាងហោចណាស់ដើមឈើមិនប្រណិតចំនួន ១០០ដើម ត្រូវបានគេកាប់ផ្តួលរំលំ ក្នុងមួយជើងៗ។ លើសពីនេះទៀតកម្មករបានកាប់ដើមឈើនានា ដើម្បីធ្វើជាជំរុំស្នាក់នៅថែមទៀតផង[6] ។

[6] ព័ត៌មានប្រមូលបានពីកម្មករកាប់ឈើ



*រូបភាព៥៖ ឈើប្រភេទប្រណីតនៅក្នុងឧទ្យានជាតិវីរៈជ័យ ស្រុកតាវែង*

## ៤.២ មូលហេតុផ្សេងទៀតនៃវិនាសកម្មព្រៃឈើនៅកម្ពុជា

### អាជ្ញាធរមិនអនុវត្តច្បាប់

ដោយសារការកាប់ឈើត្រូវបានគាំទ្រដោយរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋានបានធ្វើការអនុវត្តន៍ច្បាប់ ការពារព្រៃឈើតិចតួចណាស់។ ប៉ូលីស ទាហាន ប៉េអឹម មន្ត្រីបរិស្ថាន ទាហានការពារព្រំដែន អាជ្ញាធរមូលដ្ឋាន និងសហគមន៍ព្រៃឈើមួយចំនួន ក៏បានចូលរួមពាក់ព័ន្ធនៅតាមដំណាក់កាលជាច្រើននៅក្នុងខ្សែសង្វាក់រកស៊ីកាប់ឈើ។

ទោះបីជា អ្នកទាំងនោះ បានដឹងថារបររកស៊ីកាប់ឈើនេះ ខុសច្បាប់ក៏ដោយ ក៏ពួកគេនៅតែចូលរួមមុខរបរនេះ ដោយបើកចំហរ ដោយទទួលយកផលប្រយោជន៍ជាទ្រព្យសម្បត្តិ និងទទួលយក ការចំណាយផ្សេងៗ ដើម្បីធានាថា ការដឹកជញ្ជូនឈើប្រណីត ដំណើរការទៅដោយរលូន[7]។



*រូបភាព៦៖ អ្នកដឹកជញ្ជូនឈើបង់ប្រាក់នៅប៉ុស្តិ៍ប៉ូលីស ប៉ាកាឡាន់ដើម្បីឆ្លងកាត់*

[7] ប្រភពពីអាជ្ញាធរមូលដ្ឋាន និងអ្នកកាប់ឈើ

ការខកខានមិនបានអនុវត្តន៍ច្បាប់ដោយរដ្ឋបាលព្រៃឈើ មន្ត្រីបរិស្ថាន ឬអ្នកអភិរក្ស ធ្វើឲ្យការកាប់បំផ្លាញព្រៃឈើមានសន្ទុះកាន់តែលឿនឡើងៗ។ មន្ត្រីបរិស្ថាន រុក្ខាប្រម៉ាញ់ ឬមន្ត្រីប៉ូលីសមួយចំនួនបានបោះទីតាំងនៅក្នុងព្រៃជិតតំបន់កាប់ឈើដើម្បីងាយស្រួលទារប្រាក់ពីអ្នកកាប់ឈើ។ ប្រសិនបើអ្នកដឹកឈើមិនបង់ប្រាក់នៅតាមប៉ុស្តិ៍ត្រួតពិនិត្យទេនោះកងកំលាំងប្រដាប់អាវុធនឹងចាប់រឹបអូសដកហូតឈើ ហើយយកទៅកាន់ដេប៉ូទ្រីភាព[7]។

## ជនជាតិដើមភាគតិចបានក្លាយជាអ្នកជាប់ពាក់ព័ន្ធនឹងការកាប់ឈើ

សហគមន៍ជនជាតិដើមភាគតិចដែលរស់នៅក្បែរតំបន់ព្រៃ និងអាស្រ័យផលលើការដាំដុះដោយដំណាំវិលជុំ ឬការបរបាញ់សត្វសំរាប់ទ្រទ្រង់ជីវភាពរស់នៅបានប្រឈមនឹងបញ្ហាលំបាកជាច្រើន។ ពួកគេកំរមានលទ្ធភាពដើម្បីរំដោះខ្លួនចេញពីភាពក្រីក្រ ហេតុដូចនេះហើយបានជាអ្នកភូមិជាច្រើនបានផ្លាស់ប្តូរឥរិយាបទពីការលះបង់ខ្លួន ដើម្បីអភិរក្សព្រៃឈើក្លាយទៅជាអ្នកចូលរួមនៅក្នុងឧស្សាហកម្មកាប់ឈើនេះទៅវិញ។ វត្តមានរបស់ក្រុមចំណូលថ្មីមកពីខាងក្រៅតំបន់នោះ បានជះឥទ្ធិពលដល់របៀបរស់នៅ និងវប្បធម៌របស់ជនជាតិដើមភាគតិច។ មេដឹកនាំ (មេកន្ទ្រាញ)ជនជាតិដើមភាគតិច និងមេភូមិមួយចំនួនក៏បានផ្លាស់ប្តូរគំនិតយោបល់ជាមួយក្រុម អ្នកចំណូលថ្មីទាំងនេះ ហើយពួកគាត់ធ្លាក់ទៅក្នុងការអូសទាញដោយរំពឹងថានឹងមានជីវភាពរីកចម្រើនពីរបរកាប់ឈើនេះ។ អ្នកដឹកនាំសហគមន៍ខ្លះបាននិយាយថាការប្រឡូកខ្លួនចូលរួមនិងរកប្រាក់បានពីការកាប់ឈើនេះ គឺវាប្រសើរជាងការឈរមើលដើមឈើដែលត្រូវគេយកពីគាត់អស់រលីងដោយគ្មានបានអ្វីសោះទាល់តែសោះ។

*"ប្រសិនបើយើងមិនកាប់ឈើទេ តើយើងអាចចិញ្ចឹមជីវិតគ្រួសារយើងដោយរបៀបណានៅពេលដែលឃុំនេះត្រូវបានទឹកជន់លិចទាំងស្រុងទៅហើយម្យ៉ាងបើយើងមិនកាប់ទេ ក៏ក្រុមហ៊ុននៅតែកាប់ដដែលហ្នឹង។ កាប់ឈើដើម្បីបានប្រាក់ប្រសើរជាង បាត់បង់អ្វីៗគ្រប់បែបយ៉ាង[8]។" បទសម្ភាសន៍ជាមួយមេឃុំ។*

មេឃុំមួយចំនួននៅក្នុងភូមិដែលជនជាតិការ៉េត និងឡាវរស់នៅដែលពួកគាត់មិនដឹងថាតើគួរធ្វើដូចម្តេច ដើម្បីឲ្យសហគមន៍បានប្រសើរនោះ បែរជាណែនាំ និងជំរុញអ្នកភូមិកាប់ដើមឈើលក់ឲ្យក្រុមហ៊ុនទ្រីភាព។ កាលពីឆ្នាំ២០១៣ ប្រជាជន បានរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារទឹកជំនន់ ដូច្នេះពួកគាត់បានទៅកាប់ឈើ ដើម្បីទ្រទ្រង់ជីវភាពរស់នៅឲ្យកាន់តែប្រសើរឡើង។ អ្នកខ្លះបានថ្លែងអំណរគុណចំពោះក្រុមហ៊ុនទ្រីភាពដែលបានចូលមកតំបន់នេះ ហើយធ្វើឲ្យពួកគេមានភាពធូរធារជាងមុន។ បន្ទាប់ពីបានកាប់ឈើ អ្នកភូមិមួយចំនួនមានលទ្ធភាពទិញរថយន្ត និងគ្រឿងអលង្ការមាស ហើយមានលទ្ធភាពបញ្ជូនកូនទៅសាលារៀន។ តែទោះបីយ៉ាងណាក៏ដោយ នៅពេលដែលព្រៃឈើត្រូវបានកាប់អស់ហើយ

[8] សហគមន៍ជាច្រើនរស់នៅតាមបណ្តោយទន្លេសេសានពិបាកនឹងប្រឆាំងនឹងគ្រោះទឹកជំនន់

អ្នកកាប់ឈើផ្លាស់ប្តូរទៅក្នុងតំបន់ថ្មី អ្នកភូមិទាំងនេះ មិនមានមុខរបរអ្វីនៅសេសសល់ទៀតទេ ហើយឥឡូវនេះ មេសហគមន៍មានការព្រួយបារម្ភអំពីអនាគតរបស់ប្រជាជននៅទីនោះ។

ដោយសារតែព្រៃឈើបាត់បង់ទៅហើយ ឥឡូវនេះគ្មានសត្វព្រៃ គ្មានរមណីយដ្ឋាន និងទេសចរណ៍ធម្មជាតិតទៅទៀតនោះដែរ។ យុវជនមួយចំនួនធំដែលធ្លាប់ធ្វើជាមគ្គុទ្ទេសនាំភ្ញៀវឲ្យក្រុមហ៊ុនទេសចរណ៍ធម្មជាតិ បច្ចុប្បន្ននេះបានផ្លាស់ប្តូរមុខរបរទៅធ្វើការងារសំណង់ បុគ្គលិកសណ្ឋាគារ ឬជាអ្នកជំរះស្មៅតាមចម្ការឯកជនជាដើម។

អ្នកដឹកនាំសហគមន៍មួយចំនួន មានការសោកស្តាយចំពោះការជំរុញឲ្យប្រជាពលរដ្ឋពាក់ព័ន្ធនឹងការកាប់ឈើ ហើយមានអារម្មណ៍ថាខ្លួនត្រូវបានក្រុមហ៊ុនបោកបញ្ឆោត។ ពួកគេត្រូវបានគេធ្វើការសន្យាថានឹងអភិវឌ្ឍន៍តំបន់នេះ ជាថ្នូរនឹងការអនុញ្ញាតឲ្យអ្នកកាប់ឈើបានចូល ផ្ទុយទៅវិញការអភិវឌ្ឍន៍មានតិចតួច ឬគ្មានការអភិវឌ្ឍន៍ទាល់តែសោះ។ អ្នកដឹកនាំសហគមន៍ខ្លះព្យាយាមការពារព្រៃឈើដោយបានដាក់ពាក្យបណ្តឹងទៅរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ រហូតដល់នាយករដ្ឋមន្ត្រី ប៉ុន្តែមិនមានការឆ្លើយតបជាវិជ្ជមានណាមួយនៅឡើយ ផ្ទុយទៅវិញបែរជាមានកងកំលាំងប្រដាប់អាវុធ ត្រូវបានគេបញ្ជូនមកជួយការពារក្រុមហ៊ុនកាប់ឈើទៅវិញ។ អ្នកដឹកនាំសហគមន៍មិនដឹងថាគួរធ្វើអ្វីខ្លះ ហើយក៏គ្មាននរណាអាចដោះស្រាយស្ថានភាពនេះបានដែរ[9]។



*រូបភាព៧៖ អ្នកភូមិអំពាវនាវឲ្យបញ្ឈប់ការកាប់ឈើ និង ឈូសឆាយដីនៅតាវែង*

[9] ប្រភពពីមេឃុំ និងមេសហគមន៍

## ភាពអស់សង្ឃឹមរបស់សហគមន៍ក្នុងការព្យាយាមការពារព្រៃឈើ

សហគមន៍ជនជាតិដើមភាគតិចជាច្រើនបានប្តេជ្ញាការពារ និងអភិរក្សធនធានធម្មជាតិ។ ពួកគាត់ទាមទារ តវ៉ា រារាំងក្រុមហ៊ុនមិនឲ្យកាប់ឈើ ហើយបានដាក់ញត្តិម្តងហើយម្តងទៀតទៅរដ្ឋាភិបាល។ ប៉ុន្តែទីបំផុត ពួកគាត់នៅតែមិនអាចការពារព្រៃឈើទាំងនោះបាន។ ពួកគាត់ត្រូវបានគេរាយការណ៍ថាបានទទួលរងនូវការវាយដំ និងគំរាមកំហែងពីសំណាក់កងកំលាំងប្រដាប់អាវុធដែលការពារក្រុមហ៊ុនកាប់ឈើទាំងនោះ។

*"តើយើងអាចប្តឹងរដ្ឋាភិបាល និងក្រុមហ៊ុនដោយរបៀបណានៅពេលដែលរដ្ឋាភិបាលបានគាំទ្រ និងរកស៊ីជាមួយក្រុមហ៊ុន?"* បានលើកឡើងដោយសកម្មជនម្នាក់នៅក្នុងសហគមន៍។

សកម្មជនការពារព្រៃឈើ ដ៏ឆ្នើមម្នាក់នៅភូមិផាវ ដែលត្រូវបានពិន័យដោយមេឃុំ បន្ទាប់ពីគាត់បានដឹកនាំអ្នកភូមិធ្វើការតវ៉ាប្រឆាំងនឹងក្រុមហ៊ុន។ ត្រង់ចំណុចនេះហើយ ដែលធ្វើប្រជាជនមានការព្រួយបារម្មណ៏ និងស្រងាកចិត្តចំពោះរដ្ឋាភិបាល ដែលខ្វះការគាំទ្រដល់ពួកគាត់ ដូច្នេះសមាជិកសហគមន៍ព្រៃឈើជាច្រើន បានចូលរួមកាប់ឈើ និងមានភាពអន្ទះសារក្នុងការរកប្រាក់ពីសកម្មភាពកាប់ឈើដែលកំពុងតែកើតមានឡើង ទោះបីជាពួកគាត់ចូលរួម ឬមិនចូលរួមក៏ដោយ។

## ការពង្រីកផ្ទៃដីធ្វើចំការរបស់អ្នកភូមិ

កិច្ចប្រឹងប្រែងរបស់សហគមន៍ គឺខិតខំការពារព្រៃឈើដោយក្នុងនោះពួកគាត់បានដើរយាមល្បាត ការពារតំបន់ព្រៃក្រាស់ដែលមានឈើប្រណីតច្រើន។ នៅពេលដែលក្រុមហ៊ុនកាប់ឈើបានចាកចេញពីតំបន់នោះ សហគមន៍ផ្សេងទៀត បានសំរុកចូលទៅត្រួសត្រាយរុករានដីធ្វើចំការ។ សកម្មភាព នេះបាន ធ្វើឲ្យព្រៃឈើបាត់បង់[10]កាន់តែមានសន្ទុះលឿន ។

---

[10] របាយការណ៏ដែលរកឃើញដោយក្រុមស្រាវជ្រាវ



*រូបភាព៨៖ ចំការរានថ្មីរបស់ជនជាតិការ៉េតនៅតាវ៉េង*

## ៥. តម្លៃឈើប្រណីត

តម្លៃឈើប្រណីតមានផ្សេងៗគ្នាទៅតាមតំបន់ទៅតាមប្រភេទឈើ តាមទំរង់ រូបរាង តាមលក្ខណៈ និងតាមគុណភាពរបស់ឈើ (តម្លៃរបស់ឈើ និងប្រភេទឈើមានពន្យល់នៅក្នុងឧបសម្ព័ន្ធ១ ភ្ជាប់មកជាមួយស្រាប់)។ អាជីវកម្មឈើដ៏សកម្មបំផុត គឺប្រភេទឈើក្រញូង ធ្នង់ នាងនួន ដែលកំពុងតែមានតម្រូវការខ្ពស់នៅលើទីផ្សារអន្តរជាតិ បន្ទាប់គឺប្រភេទឈើសុក្រម។ ចំពោះតម្លៃ ឈើប្រណីត ត្រូវបានកំណត់ទៅតាមប្រភេទឈើ រូបរាង និងមុខកាត់របស់វាសំរាប់ឈើនាងនួនមានតម្លៃទ្វេរដងច្រើនជាងឈើធ្នង់។

ប្រភេទឈើក្រញូង ត្រូវបានគេគិតក្នុងតម្លៃ៥ទៅ១០ដុល្លារក្នុងមួយគីឡូ មានន័យថា ឈើក្រញូងក្នុងមួយម៉ែត្រគូបមានតម្លៃស្មើនឹង ៥ម៉ឺនទៅ១០ម៉ឺនដុល្លារ នៅលើទីផ្សារខេត្តរតនគិរី។ ចំពោះធឿក្រញូងវិញមានតម្លៃចាប់ពី១០ម៉ឺនទៅ២០ម៉ឺនដុល្លារ (ដែលកម្ររកបានអ្នកទិញណាស់ព្រោះការនាំចេញ គឺខុសច្បាប់ហើយមានតែអ្នកកាប់ឈើដែលមានឥទ្ធិពល ឬអំណាចខ្លាំងប៉ុណ្ណោះដែលអាចហ៊ានកាប់ ហើយឈើប្រភេទក្រញូងសៀម មានតម្លៃចាប់ពី១លានប្រាំសែនដុល្លារ និងអាចឡើងដល់ ២លានដុល្លារក្នុង១ម៣ នេះបើតាមតម្លៃទីផ្សារនៅប្រទេសចិន។ ក្រញូងជាប្រភេទឈើហាមឃាត់ ដូច្នេះអ្នកកាប់ឈើភាគច្រើនបានកប់វាលាក់ទុកក្នុងដី ហើយត្រូវចំណាយ ១៥០០ដុល្លារក្នុងមួយខែ ដើម្បីកុំឲ្យមនុស្សនាំគ្នានិយាយខ្ចរខ្ចាយ[11]។

---

[11] របាយការណ៍ស្រាវជ្រាវរបស់អង្គការភ្នាក់ងារអង្កេតបរិស្ថាន

ទិន្នន័យដែលបានមកពីគេហទំព័រអាលីបាបា (Alibaba) បានបង្ហាញថាឈើគ្រញូង គឺជាប្រភេទឈើដែលមានតម្លៃជាងគេបំផុតរហូតដល់ ១លានដុល្លារ សំរាប់ទំហំឈើកំរាស់ មុខកាត់៨០សម x ២២០ x ១០សម ។

# ៦. អាជីវកម្មឈើទ្រង់ទ្រាយធំនៅខេត្តរតនគិរី[12]

ឧទ្យានជាតិវីរៈជ័យ មានទីតាំងនៅភាគខាងជើង ខេត្តរតគិរី និងស្ទឹងត្រែង។ ក្រុមហ៊ុនជាច្រើនបានធ្វើការកាប់ឈើជុំវិញ ឬនៅក្នុងតំបន់នេះ ដែលរួមមានក្រុមហ៊ុនអានម៉ាឌីគ្រុប ក្រុមហ៊ុនឧកញ៉ា ឧកញ៉ាគិត ម៉េងគ្រុប ក្រុមហ៊ុនឧកញ៉ាលឹម ប៊ុណ្ណា ក្រុមហ៊ុនម៉ុងឬទ្ធី ក្រុមហ៊ុនវៀតណាមហ័ងអាញយ៉ាឡាយ ក្រុមហ៊ុនជាំងលី និង ក្រុមហ៊ុន ម៉ែនសារុនជាដើម។ ការកាប់ឈើបានចាប់ផ្តើមនៅក្នុងឆ្នាំ២០០៦ និងបន្តរហូតដល់ឆ្នាំ២០១៣។ ការកាប់ឈើនេះគឺផ្តោតយកតែឈើប្រណីតមានតម្លៃដូចជា ក្រញូង បេង នាងនួន ដើម្បីបំពេញតាមតម្រូវការទីផ្សាររបស់ប្រទេសចិន វៀតណាមនិងឡាវ។ ចាប់តាំងពីដើមឆ្នាំ២០១៣ ក្រុមហ៊ុនទាំងនោះ ក៏បានដកខ្លួនដោយមានក្រុមហ៊ុនទ្រីភាព គ្រុប មកជំនួសក្នុងការបន្តកាប់ប្រមូលទិញស្តុកទុក និងដឹកជញ្ជូនឈើប្រណីតជាចំហរ និងផ្តាច់មុខនៅក្នុងតំបន់នេះ និងនៅទូទាំងប្រទេសកម្ពុជាទាំងមូល។

នៅឆ្នាំ២០១៣ មេការរបស់ក្រុមហ៊ុនទ្រី ភាព បានធ្វើការចរចារជាមួយសហគមន៍ព្រៃឈើ និងអាជ្ញាធរមូលដ្ឋានឲ្យលក់ដើមឈើ។ ក្រុមហ៊ុនបានប្រាប់ដល់ប្រជាជនថាខ្លួនទទួលបានសិទ្ធិ និងអាជ្ញាប័ណ្ណពីរដ្ឋាភិបាល ព្រមទាំងមានសិទ្ធិប្រមូលឈើពីតំបន់សម្បទានទាំងអស់។ បើទោះបីជាសហគមន៍ ឬអាជ្ញាធរមូលដ្ឋានមិនយល់ព្រមឲ្យកាប់ឈើក៏ដោយនៅក្នុងតំបន់ខ្លះក្រុមហ៊ុនបានពង្រាយកំលាំងកម្មករចូលទៅកាប់ឈើក្នុងតំបន់ព្រៃដែលសហគមន៍បានប្រើប្រាស់ និងនៅក្នុងឧទ្យានជាតិផងដែរ។ អ្នកកាប់ឈើត្រូវបានការពារដោយកងកំលាំងប្រដាប់អាវុធមាន ទាហាន ប៉េអឹម និងមន្ត្រីបរិស្ថាន ជាដើម។ អ្នកភូមិបានដឹងថា គ្មានចំណុចណាមួយដែលត្រូវប្តឹងទេ ដោយសារតែក្រុមហ៊ុនកាប់ឈើនេះ មានការគាំទ្រពីរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់។ ព្រៃឈើនៅក្នុងតំបន់ការពារត្រូវបានកាប់បំផ្លាញ កម្មករត្រូវបានផ្តល់ជូននូវរណាយន្ត និងប្រេងសាំង ហើយថៅកែឈើភាគច្រើនជាកងកំលាំងប្រដាប់អាវុធ ប្រមូលឈើ និងដឹកជញ្ជូនទៅដេប៉ូឈើ[13]។ មេភូមិ មេឃុំ បានបញ្ចុះបញ្ចូលប្រជាពលរដ្ឋកាប់ឈើលក់ឲ្យក្រុមហ៊ុន មេភូមិ មេឃុំទាំងនោះបានប្រាប់អ្នកភូមិថាក្រុមហ៊ុនទិញឈើធ្នង់ នាងនួន និងក្រញូងគ្រប់ប្រភេទ។

[12] សំភាសន៍ជាមួយអ្នកកាប់ឈើ អាជ្ញាធរ និង កម្មករ

[13] សំភាសន៍នៅក្នុងឃុំកូកឡាក់ ស្រុកវ៉ឺនសៃ និងឃុំតាវែងក្រោម ស្រុកតាវែង



*រូបភាព៩៖ អ្នកកាប់ឈើសំលៀងរណារយន្តរៀបចំកាប់ឈើនៅក្នុងឧទ្យានជាតិវីរៈជ័យ*

ការស៊ើបអង្កេតរបស់យើងបានរកឃើញថា អ្នកភូមិជឿជាក់ថាក្រុមហ៊ុននេះបានបោកប្រាស់សហគមន៍ជនជាតិដើមភាគតិច ដោយកសាងទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងការជឿទុកចិត្តជាមួយប្រជាជន។ ឧទាហរណ៍អ្នកភូមិមួយចំនួនបាននិយាយថា មេការបានរៀបចំពិធីសាសនា និងជប់លៀងមុនពេលចុះកិច្ចព្រមព្រៀង។ ពួកគេបានកាប់គោ និងក្របីធ្វើម្ហូប ផឹកស្រាបៀរ ABC ជាមួយប្រធានសហគមន៍ និងអាជ្ញាធរមូលដ្ឋាន។ អ្នកភូមិចោទប្រកាន់ថា នៅពេលដែលប្រធានសហគមន៍បានស្ររឹង មន្ត្រីក្រុមហ៊ុនបានឲ្យគាត់ចុះហត្ថលេខាលើកិច្ចព្រមព្រៀង។ មេការបានផ្តល់សំភារៈសំណង់ និងការគាំទ្រផ្នែកហិរញ្ញវត្ថុ ដូចជាម៉ូតូសម្រាប់មេភូមិ និងប្រធានសហគមន៍។ ពួកគេក៏បានផ្តល់ហិរញ្ញប្បទានមួយចំនួននៃការសាងសង់សាលនៅក្នុងភូមិ និងស្ពានតូចមួយកន្លែង(សូមមើលក្នុងឧបសម្ព័ន្ធ១៥)។ មេឃុំខ្លះត្រូវបានគេផ្តល់ឲ្យពី ១០០០ ទៅ ៣០០០ដុល្លារ នៅពេលចាប់ដើមនៃពិធី ខណៈពេលដែលប្រធានភូមិមួយចំនួនបានពី ៣០០ ទៅ ៦០០ដុល្លារ។ ប្រធានសហគមន៍ត្រូវបានគេបង់ប្រាក់ឲ្យសរុបទាំងអស់ ២៥០០ដុល្លារ ប៉ុន្តែបង់ជា៣ដំណាក់កាល និងម៉ូតូមួយគ្រឿងផងដែរ ជាថ្នូរនឹងការយល់ព្រមឲ្យកាប់ឈើនៅក្នុងតំបន់ព្រៃសហគមន៍[14]។

លើសពីនេះសមាជិកសហគមន៍ និងអាជ្ញាធរមូលដ្ឋានបានទទួលលុយពីឡានដែលបានដឹកឈើឆ្លងកាត់ប៉ុស្តិ៍ត្រួតពិនិត្យ ឬឆ្លងកាត់ភូមិអាស្រ័យលើឋានៈ និងតួនាទីរបស់ពួកគេ។ មេភូមិនេះត្រូវបានគេបង់ប្រាក់រវាង ៣ម៉ឺនរៀល និង ៥ម៉ឺនរៀល ខណៈពេលដែលមេឃុំ និងមេដឹកនាំសហគមន៍បានក្នុងម្នាក់ៗចំនួន ១០ម៉ឺនរៀល ។ ប៉ូលីស ប៉េអឹម មន្ត្រីបរិស្ថាន និងមន្ត្រីអភិរក្សត្រូវបានបង់ក្នុងចន្លោះពី២០ម៉ឺនរៀល និង ៤០ម៉ឺនរៀល។

[14] ប្រភពមកពីសកម្មជនព្រៃឈើ

ឃុំខ្លះទទួលបានប្រាក់ច្រើនជាងឃុំដទៃទៀត វាអាស្រ័យលើទំហំព្រៃឈើនៅក្នុងឃុំនោះ ឧទាហរណ៍ដូចជានៅឃុំតាវែងក្រោម ត្រូវបានគេឲ្យ៣០០ដុល្លារ ក្នុងមួយភូមិ ហើយមួយជើងៗ ទទួលបាន១០ម៉ឺនរៀលពីឡានដឹកឈើដែលបានបន្តអស់រយៈពេលជាច្រើនខែ។ ប៉ុន្តែនៅពេលព្រៃឈើអស់ មិនមានការកាប់ឈើបន្តទៅទៀតទេ ហើយការឧបត្ថម្ភថវិកាក៏ត្រូវចប់ជាស្ថាពរ។

ក្រុមហ៊ុនទ្រីភាពគ្រុប ត្រូវបានចោទប្រកាន់ថាបោកប្រាស់អ្នកភូមិ។ អ្នកភូមិអះអាងថាក្រុមហ៊ុននេះបានចូលមក និងកាប់យកឈើប្រណីតអស់ ប៉ុន្តែមិនបាន ផ្តល់ការអភិវឌ្ឍន៍អ្វីទាំងអស់។ សូម្បីតែផ្លូវដែលបានខូចខាតដោយសារឡានដឹកឈើ ក៏ក្រុមហ៊ុនមិនបានជួសជុលឲ្យវិញដែរ។ ធនធានធម្មជាតិត្រូវបានបាត់បង់ព្រៃឈើក៏ត្រូវបានបំផ្លាញទាំងស្រុង ហើយជីវភាពរស់នៅកាន់តែការលំបាកជាងមុនឆ្ងាយណាស់។ តំបន់ផ្សេងទៀត ចំណូលដែលបានមកពីផលអនុផលព្រៃឈើ ឬទេសចរណ៍ធម្មជាតិ ត្រូវខ្សោះអស់រលីង។

កិច្ចសន្យារវាងមេភូមិ និងមេដឹកនាំសហគមន៍ចំនួន៤ រួមមានភូមិរ៉ុក ឡាមួយ ឡាទ្បែ និងត្រាក់ស្ថិតក្នុងឃុំកូកឡាក់ ស្រុកវ៉ឺនសៃ ជាមួយនឹងមេការរបស់ក្រុមហ៊ុន ទ្រីភាព ម្នាក់ឈ្មោះ ហូម ហាយ បានសរសេរថាៈ អ្នកភូមិបានអនុញ្ញាតិឲ្យក្រុមហ៊ុនទ្រី ភាពគ្រុប ធ្វើការកាប់ឈើនៅក្នុងព្រៃដែលសហគមន៍ទាំងនេះ ប្រើប្រាស់ចាប់ពី ខែកញ្ញា ឆ្នាំ២០១៣ រហូតដល់ខែកក្កដា ឆ្នាំ២០១៤។ ជាថ្នូរដោះដូរក្រុមហ៊ុន នឹងសង់អគារ ៤ និងស្ពានមួយ (មើលឧបសម្ព័ន្ធ ១៥)។ គិតត្រឹមខែមិថុនា ឆ្នាំ២០១៤ ក្រុមហ៊ុនបានកាប់ឈើប្រណីតលាតសន្ធឹងដល់ប្រទេសឡាវក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ។យោងតាមសកម្មជនព្រៃឈើជាច្រើនអ្នកកាប់ឈើប្រណីតក្នុងអត្រាចំងាយ១០ គីឡូម៉ែត្រក្នុងមួយខែ។ ភូមិដទៃទៀតក៏បានស្ថិតក្រោមសម្ពាធនៃការកាប់ឈើនេះដែររួមមានភូមិកាពីន(គីរីវង្សាក្រោម) ភូមិតាទ្បែ(គីរីបាស់ក្រោមឈ្មោះក្នុងផែនទីរដ្ឋបាល) ភូមិបាក់កែ ភូមិចាម ភូមិស្រម៉រ ភូមិអូរខ្លាង ភូមិអូរចង ភូមិអ៊ីទុប និងភូមិកង់ណាក។

ក្រៅពីការទិញឈើពីតំបន់ព្រៃសហគមន៍ មេការ ជំនួយការ ឬថៅកែឈើ ក៏បានឲ្យអ្នកភូមិមួយចំនួនឲ្យកាប់ឈើនៅក្នុងឧទ្យានជាតិ ពេលខ្លះពួកគេបានទិញឈើឈរពីជនជាតិដើមភាគតិច ឬពីជនជាតិដើមភាគតិចឡាវ ដែលជាម្ចាស់ដើមឈើ ឬអ្នកដែលបានរកឃើញដើមឈើនៅក្នុងព្រៃ។ ដើមធ្នង់ឈរមួយដើមមានអង្កត់ផ្ចិត ៣០សមមានតំលៃ២០០ដុល្លារ។ អ្នកលក់ ទទួលបន្ទុកបាញ់ថ្នាំធ្វើសញ្ញាសំគាល់ថា ដើមឈើមួយណាដែលត្រូវកាប់រំលំ។ សហគមន៍ និងអាជ្ញាធរមូលដ្ឋានខ្លះបានចោទប្រកាន់មន្ត្រីរុក្ខាប្រម៉ាញ់ និងអ្នកល្បាតព្រៃមួយចំនួនដែលបានគាំទ្រដោយអង្គការអភិរក្សអន្តរជាតិថា បានលក់ដើមឈើធ្នង់ឲ្យថៅកែឈើដែលបានដឹកជញ្ជូនឈើពីតំបន់អភិរក្សវ៉ឺនសៃសៀមប៉ាង នៅអូរកាស៊ីបទៅឲ្យដេប៉ូមួយចំនួនដើម្បីធ្វើការនាំចេញ។ ការកាប់ឈើនៅក្នុងតំបន់អភិរក្សនេះបានកើតមានឡើង នៅពេលដែល

បុគ្គលិកជាន់ខ្ពស់របស់អង្គការអភិរក្សអន្តរជាតិ បានចេញទៅទីក្រុងដូចជាភ្នំពេញ ឬនៅថ្ងៃឈប់សម្រាកជាដើម[15]។




*រូបភាព១០ និង១២៖ ការសំគាល់ដើមឈើ និងការប្រមូលចំនុចកូអរដោណេសំគាល់ការកាប់ឈើដោយទ្រីភាពគ្រុបនៅ ភ្នំក្រាយ និងសៀមប៉ាង*

## ៦.១ អាជីវកម្មឈើប្រណិត

អ្នកកាប់ឈើទាំងអស់ត្រូវតែលក់ឈើរបស់ពួកគេទៅឲ្យក្រុមហ៊ុនទ្រីភាពគ្រុប។ អ្នកកាប់ឈើបាននិយាយថា ប្រសិនបើឈើត្រូវបានដឹកចេញពីព្រៃ ហើយមិនលក់ នៅឯដេប៉ូទ្រីភាពនោះទេ នោះវានឹងត្រូវបានគេរឹបអូស ហើយនាំយកទៅដេប៉ូ។ ទោះជាយ៉ាងណាក៏ដោយ អ្នកកាប់ឈើជាច្រើនបានព្យាយាមក្នុងការលក់ដោយផ្ទាល់ទៅទីផ្សារសេរី ដើម្បីទទួលបានតម្លៃខ្ពស់ជាង។ ការកាប់ឈើបាននឹងកំពុងបន្តនៅក្នុងតំបន់នេះតាំងពីឆ្នាំ២០០៤ នៅពេលដែលក្រុមឈ្មួញចាប់ផ្តើមទិញក្រញូង និងបេង។ ក្រោយមកទៀតក្រុមឈ្មួញ បានចាប់ផ្តើមទិញ នាននួន និងធ្នង់ ហើយនៅក្នុងឆ្នាំ ២០១៤ ពួកគេបានចាប់ផ្តើមទិញឈើសុក្រមបន្ទៀត។ នៅក្នុងភូមិជាច្រើន អ្នកភូមិមួយចំនួន បានកាប់ឈើប្រណីតលាក់គរទុកនៅក្រោយផ្ទះរបស់ពួកគេរង់ចាំថៅកែ ឈើមកទិញ។ យូរៗម្តងពួកគេយកឈើទាំងនោះទៅលក់នៅឯដេប៉ូនៅឯខេត្ត ឬក៏ដឹកជញ្ជូនដោយផ្ទាល់ទៅកាន់ព្រំដែនវៀតណាម ឬព្រំដែនឡាវ ដែលជាកន្លែងអាច ទទួលបាននូវតម្លៃខ្ពស់ជាងនៅតាមទីផ្សារក្នុងស្រុក ឬតម្លៃនៅតាមដេប៉ូ។ ឈ្មួញភាគច្រើនមិនចង់លក់ឈើដោយផ្ទាល់ទៅក្រុមហ៊ុន ព្រោះក្រុមហ៊ុនឲ្យតម្លៃត្រឹមតែពាក់កណ្តាលនៃតម្លៃនៅលើទីផ្សារសេរី។ ឈ្មួញកាប់ឈើខ្លះ បានលក់ដោយផ្ទាល់នៅឯផ្សារតាមព្រំដែនដែលមានទីតាំងស្ថិតនៅចន្លោះរវាងព្រំដែនកម្ពុជា-វៀតណាម និងកម្ពុជា ឡាវ ឬតាមច្រករបៀងនានាជាដើម ។

---
[15] សំភាសន៍ជាមួយអ្នកភូមិអ៊ីទូប

ឈ្មួញឈើឯកជន ត្រូវតែបង់ឲ្យកំលាំងប្រដាប់អាវុធ ប្រសិនបើពួកគេមានបំណង ចង់គេចពីទ្រឹភាពគ្រប។ ប្រសិនបើពួកគេមិនបានបង់ប្រាក់ទេ ឈើប្រណីតរបស់ពួកគេត្រូវ បានរឹបអូស ហើយប្រគល់ទៅឲ្យក្រុមហ៊ុនទ្រីភាព ដោយសារតែកងកម្លាំងប្រដាប់អាវុធបាន ដឹងថា ក្រុមហ៊ុនទ្រីភាពមានសិទ្ធិផ្តាច់មុខលើព្រៃឈើ។ ប្រសិនបើឈើត្រូវបានដឹកតាមម៉ូតូ ត្រូវបង់ប្រាក់ឲ្យអាជ្ញាធរ នៅតាមផ្លូវពីចន្លោះ៥ទៅ ១០ដុល្លារ។ ប្រសិនបើការដឹកជញ្ជូនតាម រ៉ឺម៉កម៉ូតូ សោហ៊ុយត្រូវបង់ពីចន្លោះ២០ទៅ២៥ដុល្លារហើយប្រសិនបើដឹកតាមរថយន្ត(២តោន) គឺបង់ចន្លោះ៥០ទៅ១០០ដុល្លារ។ ដើម្បីដឹកជញ្ជូនឈើប្រណីតដែលមានបរិមាណច្រើន អ្នក លក់ត្រូវតែដាក់ពាក្យសុំការអនុញ្ញាតិជាចាំបាច់។ ពួកគេត្រូវតែមានលិខិតអនុញ្ញាតិផ្ទេរឈ្មោះ (PC/B) និងលិខិតផ្តល់អាជ្ញាប័ណ្ណ (LP/B) ដែលចេញដោយរដ្ឋបាលព្រៃឈើដើម្បីដឹកជញ្ជូន នៅក្នុងប្រទេស និងអាជ្ញាប័ណ្ណពីរដ្ឋាភិបាលក្នុងការនាំចេញឈើទៅក្រៅប្រទេសដោយស្រប តាមនីតិវិធីរដ្ឋបាលព្រៃឈើ។ អាជីវកម្មឯកជនអាចទិញឈើពីដេប៉ូទ្រីភាពបាន ប៉ុន្តែវាថ្លៃជាង តម្លៃទីផ្សារ។ វាត្រូវបានគេធ្វើការអះអាងបញ្ជាក់ថា ក្រុម ហ៊ុននេះបានជួយសំរបសំរួល និង ផ្តល់នូវអាជ្ញាប័ណ្ណសម្រាប់ការដឹកជញ្ជូនចេញ ដោយមិនចាំបាច់ត្រួតពិនិត្យឆែកឆេរល្អិតល្អន់ អ្វីឡើយ[16]។

# ៧. ផលប៉ះពាល់នៃវិនាសកម្មព្រៃឈើ

ការបាត់បង់ព្រៃឈើ បានផ្តល់ផលប៉ះពាល់ជាច្រើនដល់ជីវភាពរស់នៅរបស់ប្រជា ពលរដ្ឋ។ ប្រភេទសត្វ និងជីវៈចម្រុះត្រូវបានបាត់បង់ ហើយប្រភេទសត្វ និងរុក្ខជាតិកម្រគឺ ប្រឈមមុខនឹងការផុតពូជដោយសារតែការឈូសឆាយព្រៃឈើ។ ហើយបញ្ហានេះ ជាកត្តា ដែលបណ្តាលឲ្យទេសចរណ៍ធម្មជាតិមានការសាបសូន្យ និងផលប៉ះពាល់ដោយសារតែការ បម្រែបម្រួលអាកាសធាតុមានការកើនឡើង។ ជនជាតិដើមភាគតិចដែលអាស្រ័យផលលើ ព្រៃឈើតាមបែបប្រពៃណី បានបាត់បង់ជំនឿ និងសេចក្តីទុកចិត្តហើយត្រូវបានគេមើលឃើញ ថាការអនុវត្តទំនៀមទំលាប់ វប្បធម៌ ប្រពៃណីតាមក៏ត្រូវចុះខ្សោយ/អន់ថយ។ លើសពីនោះ បាត់បង់មរតកព្រៃឈើសំរាប់មនុស្សជំនាន់ ក្រោយ។ ទោះបីជាសហគមន៍ រួមទាំងរដ្ឋាភិបាល បានដឹងច្បាស់ពីផលប៉ះពាល់នៃការបាត់បង់ព្រៃឈើក៏ដោយ ក៏ពួកគេនៅតែបន្តការកាប់វា ដោយសារ ការអូសទាញនៃភាពសម្បូរណ៍សប្បាយ បានដោយសារអាជីវកម្ម ឈើដោយមិន ខ្វល់ ថាវាបានត្រឹមតែរយៈពេលខ្លីក៏ដោយ។

[16] ប្រភពៈ អ្នកកាប់ឈើ និងមន្ត្រីរដ្ឋបាលព្រៃឈើ



*រូបភាព ១៣៖ ការិយាល័យទ្រីភាព និងរថយន្តមានបង្ហាញស្លាកសញ្ញាទ្រីភាព បានលុង រតនគីរី*




*រូបភាព១៤៖ ទាហានតថ្លៃតម្លៃឈើតាមទូរស័ព្ទដែលមានមុខកាត់៥០សម ត្រើយខាងលិច ទន្លេសេសាន វ៉ឺនសៃ*

## ៧.១ ការបាត់បង់ចំណូល និងនិរន្តរភាព [17]

ប្រជាពលរដ្ឋនៅខេត្តរតនគិរី ដឹងថាពួកគេអាចរកប្រាក់បានពីការកាប់ឈើ ហើយក៏ដឹងផងដែរថាមុខរបរនេះ គឺវាខុសច្បាប់ ប្រថុយប្រថាននឹងការចាប់ខ្លួននៅ ថ្ងៃណាមួយជាមិនខានឡើយ។ ទោះបីជាយ៉ាងណាខណៈដែលអ្នកកាប់ឈើមានចំនួនតិច ប៉ុន្តែចំនួនអ្នកប្រមូលផលព្រៃឈើ និងអនុផលព្រៃឈើ និងអ្នកដែលរស់នៅអាស្រ័យទៅលើជីវៈចម្រុះ និងព្រៃឈើ

[17] ប្រភពមកពីអាជ្ញាធរមូលដ្ឋាន និងមេដឹកនាំសហគមន៍

គឺមានចំនួនច្រើន។ អ្នកកាប់ឈើនៅកំរិតសហគមន៍ខ្លះបានត្អូញត្អែរថាប្រាក់ដែលពួកគេរកបានពីការកាប់ឈើ គឺគ្រប់គ្រាន់សំរាប់តែការចំណាយលើជីវភាពប្រចាំថ្ងៃរបស់ពួកគេតែប៉ុណ្ណោះ វាមិនអាចធ្វើឲ្យជីវភាពរស់នៅរបស់ពួកគេមានភាពរីកចំរើនដោយសារតែកាប់ឈើនោះឡើយ។ ពួកគេបាននិយាយថាប្រាក់ចំណេញពិតប្រាកដគឺធ្លាក់ទៅលើដៃរបស់ថៅកែឈើ និងក្រុមហ៊ុនដែលបានកេងប្រវ័ញ្ចកំលាំងកម្មករ និងអ្នកភូមិ។

អ្នកដឹកនាំសហគមន៍មួយចំនួននៅក្នុងស្រុកកូនមុំ លំផាត់ អូរជុំ អូរយ៉ាដាវ អណ្តូងមាស វើនសៃ តាវែង និងសៀមប៉ាង មានការសោកស្តាយយ៉ាងខ្លាំងចំពោះភាពបរាជ័យរបស់ខ្លួនក្នុងការពារព្រៃឈើ ហើយក៏បានបន្ទោសរដ្ឋាភិបាល និងក្រុមហ៊ុននានា សំរាប់ការបាត់បង់ដីព្រៃជាច្រើន នៅខេត្តរតនគីរី និងស្ទឹងត្រែង។



*រូបភាព១៥៖ មេភូមិដែលមិនពាក់ព័ន្ធនឹងការកាប់ឈើនិយាយអំពីការសោកស្តាយបាត់បង់ព្រៃឈើ*

## ការបាត់បង់ត្រី សត្វព្រៃ និងប្រភេទសត្វផ្សេងៗទៀត

កាលពីប្រាំឆ្នាំមុន ក្រុមពួកអ្នកជីវសាស្ត្របានរកឃើញពពួកសត្វព្រៃជាច្រើន (សត្វចតុបាទ) ដែលស្ទើរតែផុតពូជនៅតំបន់អាស៊ីអាគ្នេយ៍ នៅក្នុងតំបន់វីរៈជ័យ និង ជុំវិញតំបន់ក្តៅគគុកនៃជីវៈចំរុះពិភពលោក។ សត្វស្លាបមាន១៣០ប្រភេទ ថនិកសត្វ មាន៥៩ ប្រភេទ និងសត្វល្មូន ៦០ ប្រភេទនៅក្នុងតំបន់ព្រៃការពារ។ សព្វថ្ងៃសត្វទាំងនោះ បានទទួលរងផលប៉ះពាល់ដោយសារកាប់ការឈើខុសច្បាប់ និងបាត់បង់ទីជម្រក។ ប្រសិនបើគ្មានការអនុវត្ត

ន៏ច្បាប់ឲ្យមានប្រសិទ្ធភាព និងការពារទីជម្រកពពួកសត្វព្រៃដ៏កំរទាំង២៤ប្រភេទ ដែលមាននៅឧទ្យានវីរៈជ័យនិងតំបន់ជុំវិញនឹង ប្រឈមការបាត់បង់ផុតពូជ៏ពីកម្ពុជា។

ត្រីនៅតាមដងស្ទឹងក្នុងព្រៃ បានផ្តល់ម្ហូបអាហារដល់អ្នកកាប់ឈើ ដែលបានប្រើឧបករណ៍ឆក់ឬដាក់គ្រឿងផ្ទុះដើម្បីចាប់វា ដោយគ្មានអាជ្ញាធរចុះធ្វើអន្តរាគមន៍។ វាត្រូវបានគេធ្វើការរាយការណ៍ផងដែរថា សត្វព្រៃមកពីវាលធំ និងវាលអណ្តែងក្នុងតំបន់ឧទ្យានវីរៈជ័យត្រូវបានគេចាប់ និងលក់នៅផ្សារជារៀងរាល់ថ្ងៃ ហើយការបរបាញ់ប្រម៉ាញ់កើតឡើងនៅក្នុងតំបន់ព្រៃជាច្រើន។ សត្វស្វាមួយក្បាលអាចលក់បាន៥០០ដុល្លារ រីឯខ្លាឃ្មុំជំទើរមួយក្បាល ឬក៏កូនខ្លាឃ្មុំពីរក្បាល អាចលក់បាន១០០០ដុល្លារ នៅលើទីផ្សារក្នុងស្រុក។ សមត្ថកិច្ចបានដឹងអំពីព័ត៌មាននេះ ប៉ុន្តែពួកគេមិនបានធ្វើសកម្មភាពអ្វីទាំងអស់ ព្រោះវាជាប់ពាក់ព័ន្ធនឹងសកម្មភាព









*រូបភាព១៦-១៩៖ បញ្ជីក្រហមប្រភេទសត្វរបស់អង្គការ IUCN CITESកំពុងប្រឈមមុខនឹងការផុត ពូជ (បណ្តាលមកពីការបាត់បង់ជំរក និងការបរបាញ់សត្វ) ពីតំបន់វាលទំនាប (ពីឆ្វេងទីស្តាំ) ខ្លារខិន សត្វទោចមុខតូចនៅភាគខាងជើង សត្វស្វានបានរកឃើញនៅ VSSPCAសត្វក្ងយក្សត្រូវបានសង្គ្រោះនៅនឹងកន្លែង ក្រពើភ្នំត្រូវបានចាប់នៅវីរៈជ័យ។*

កាប់ឈើខុសច្បាប់របស់ពួកគេ។ តាមការបញ្ជាក់របស់អ្នកគ្រប់គ្រងរបស់អង្គការអភិរក្សអន្តរជាតិម្នាក់ដែលប្រចាំការនៅអូរកាសៀប ក្នុងតំបន់អភិរក្សវីនសៃ សៀមប៉ាង បាន និយាយថា គ្មានឈើមានតម្លៃនិង សត្វព្រៃនៅតំបន់នោះទៀតទេ។ គាត់បាននិយាយ ថាគាត់មិនមានសមត្ថកិច្ចការពារថែរក្សាតែម្នាក់ឯងបានទេ ព្រោះក្រុមឧក្រិដ្ឋជន ឬ អ្នកប្រព្រឹត្តិបទល្មើសសុទ្ធតែអ្នកមានអំណាច។ គាត់បានព្យាយាមធ្វើការរាយការណ៍ករណីបរបាញ់ប្រម៉ាញ់សត្វព្រៃនេះទៅរដ្ឋាភិបាល តែមិនមានចំណាត់ការទាល់តែ សោះ[18]។

## ការបាត់បង់ទេសចរណ៍ធម្មជាតិ

ទេសចរណ៍ធម្មជាតិ បានទទួលរងការប៉ះពាល់យ៉ាងខ្លាំងពីការកាប់ឈើ។ អ្នកទេសចរណ៍បរទេសចង់ឃើញវប្បធម៌របស់ជនជាតិដើមភាគតិច ហើយចង់សិក្សាស្វែងយល់ពីប្រពៃណី សាសនា និងជំនឿរបស់សហគមន៍ព្រៃឈើ។ ទោះជាយ៉ាង ណាក៏ដោយចំនួនអ្នកទេសចរណ៍មានការបានធ្លាក់ចុះ។ កន្លែងដែលជាដែនជម្រកដ៏ស្ងាត់ជ្រងំរបស់សត្វព្រៃ និងសហគមន៍ជនជាតិដើមភាគតិច ឥឡូវនេះពោរពេញទៅដោយសំឡេងម៉ាស៊ីនរណាយន្តពេញព្រៃទឹកក៏ល្អក់ ហើយផ្លូវក៏ត្រូវខូចខាតដោយ សារតែទម្ងន់របស់រថយន្តធ្ងន់ៗ ដែលជាហេតុបណ្តាលឲ្យអ្នកទេសចរណ៍លែងមកតំបន់នេះទៀត។



*រូបភាព២០៖អ្នកទេសចរណ៍រន្ធត់នឹងការកាប់ឈើនៅក្នុងតំបន់ការពារវីនសៃ*

---
[18] ការស្វែងរកការពិតដោយក្រុមអ្នកស្រាវជ្រាវ

យោងតាមមន្ទីរទេសចរណ៍ និងមន្ទីរបរិស្ថាន តួលេខទេសចរណ៍បានធ្លាក់ចុះយ៉ាងខ្លាំងនៅក្នុងឆ្នាំ២០១៤។ ខាងក្រោមនេះគឺជាឧទាហរណ៍ខ្លះៗ ដែលអ្នកទេស ចរណ៍ អាចរំពឹងទុកកាលពីមុនៈ

**មគ្គុទ្ទេសក៍ ដើរកំសាន្ត និងការដើរថ្មើរជើងតាមព្រៃ៖**[19]

១. ដំណើរកំសាន្តព្រៃភ្នំវាលធំ រយៈពេលធ្វើដំណើរ៖ ៧ថ្ងៃ/៦យប់ ឬ៨ថ្ងៃ/៧យប់ ការស្នាក់នៅតាមផ្ទះអ្នកភូមិ ការដើរ កំសាន្តក្នុងព្រៃរហូតទៅដល់ភ្នំវាលស្មៅធម្មជាតិជាមួយ មគ្គុទ្ទេសក៍ជាអ្នកល្បាតព្រៃ និងជាជនជាតិដើមភាគតិច

១នាក់. $ ២០៧,៥០
២នាក់. $ ៣៥០
៣នាក់. $ ៥៥៧.៥០
៤នាក់. $ ៧០០
៥នាក់. $៨៩០

២. ដំណើរកំសាន្តភ្នំស័ក្តិសិទ្ធិកាឡាង ឈូយ រយៈពេលធ្វើដំណើរ៖ ២ថ្ងៃ/១យប់ ឬ ៣ថ្ងៃ/២យប់ ការធ្វើដំណើរកាត់ភូមិ និងឧទ្យានជាតិ ដោយបោះតង់ដេកក្នុងព្រៃក្បែរទឹកធ្លាក់នៅយប់ទី១ និងយប់ទី២ដេកនៅជ្រលងទឹកហូរ ជួរព្រះ

១នាក់ $ ៦៤,
២នាក់ $ ១១៨,
៣នាក់ $ ១៧២.៥០
៤នាក់ $ ២២៦,
៥នាក់ $ ២៩០,

៣. ដំណើរកំសាន្តអូរឡាពឹង រយៈពេលធ្វើដំណើរ៖ ៣ថ្ងៃ/២យប់ ឬ៤ថ្ងៃ/៣យប់ការស្នាក់នៅតាមផ្ទះអ្នកភូមិ បោះជំរុំសំរាកក្នុងព្រៃ ដើរកំសាន្តរហូតដល់ផ្លូវលំហូជីមិញ ហើយត្រឡប់មកវិញដោយជិះក្បូនអណ្តែតតាមទឹក

---

19 ទិន្នន័យបានមកពីមគ្គុទ្ទេសក៍ទេសចរសហគមន៍

១នាក់ . $១៦០
២នាក់. $២៣០
៣នាក់. $៣៧៥
៤នាក់. $៤៤៥

**ផលិតផល និងសេវាកម្មទេសចរណ៍សហគមន៍មូលដ្ឋាន**

ផលិតផល និងសេវាកម្មទេសចរណ៍សហគមន៍មូលដ្ឋានរួមមានផ្ទះស្នាក់ចំនួន៥ និងមានតង់ស្នាក់នៅក្នុងឧទ្យានជាតិជាច្រើន ដែលផ្តល់ឱកាសដល់អ្នកទេសចរណ៍បោះជំរុំនៅពេលយប់នៅក្នុងព្រៃ។ ឧទ្យានជាតិវីរៈជ័យ មានមគ្គុទ្ទេសក៍ជាអ្នកល្បាតព្រៃ៤នាក់ ដែលនិយាយភាសាអង់គ្លេស និងមគ្គុទ្ទេសក៍ជាសហគមន៍ ១១ នាក់(និយាយភាសាខ្មែរ)។ សិប្បកម្មនានាដែលកែច្នៃដោយដៃអាចទិញពីប្រជាជនមូលដ្ឋានបាន។ យោងតាមកិច្ចសម្ភាសន៍មួយជាមួយអ្នកដឹកនាំសហគមន៍កុកឡាក់សហគមន៍បានបាត់បង់ចំណូលយ៉ាងហោចណាស់១ម៉ឺនដុល្លារក្នុងមួយឆ្នាំពីវិស័យទេសចរណ៍ធម្មជាតិនៅក្នុងឆ្នាំ២០១៣និង២០១៤ ព្រោះអ្នកទេសចរណ៍បរទេសឈប់មកកំសាន្តលេងដោយសារសត្វព្រៃត្រូវបានបាត់បង់។ អ្នកមគ្គុទ្ទេសភ្ញៀវទេសរណ៍ ខ្លះបានក្លាយខ្លួនទៅជាស៊ីឈ្នួលកាប់ឈើ ឬ បរបាញ់សត្វ ឬធ្វើជាអ្នកបំរើនៅតាមភោជនីយដ្ឋាន។

## ៧.២ ការបាត់បង់ភាពម្ចាស់ការលើខ្លួនឯង

បន្ទាប់ពីក្រុមហ៊ុន បានចូលកាន់កាប់ព្រៃនៅឆ្នាំ ២០១៣ រួចមកអ្នកភូមិគេលែងអនុញ្ញាតិឲ្យចូលតំបន់ទាំងនោះ។ សន្តិសុខមួយចំនួនរបស់មន្ទីរបរិស្ថានដែលបានប្រចាំការនៅតាមច្រកចូលឧទ្យានជាតិវីរៈជ័យ បានធ្វើការរាំង សមាជិកសហគមន៍ អ្នកកាសែត ឬអ្នកដ៏ទៃមិនឲ្យចូលទៅក្នុងព្រៃ។ សូម្បីតែអ្នកភូមិធ្វើដំណើរឆ្លងកាត់ជិតស្នាក់ការក្រុមហ៊ុនក៏គេមិនបានដែរ ហើយអ្នកភូមិ ក៏មិនត្រូវបានគេអនុញ្ញាតិឲ្យធ្វើការជាមួយក្រុមហ៊ុនដែរ។ កម្មករមកពីខេត្តផ្សេងដូចជាពោធិ៍សាត់ កោះកុង ព្រៃវែង កំពង់ធំ ព្រះវិហារ តាកែវ ក្រចេះ ស្ទឹងត្រែង ឬមកពីវៀតណាម ត្រូវបាននាំ យកមកឲ្យធ្វើការជាមួយ។ អ្នកភូមិបានប្រាប់ថាពួកគាត់អាចប្រមូលកំទេចកំទី ឬបំណែកឈើតូចៗ ដែលកម្មករក្រុមហ៊ុនបោះចោលតែប៉ុណ្ណោះ។ ព្រៃត្រូវបានគេបែងចែកជាផ្នែកៗ និងត្រួតពិនិត្យដោយមេការក្រុមហ៊ុនដែលពីមុនព្រៃទាំងនោះធ្លាប់កាន់កាប់ និងយាមកាមដោយសហគមន៏តាំងពីបុរាណ។ ការកាន់កាប់ព្រៃឈើគឺស្ថិតនៅក្រោម តាលាង តាគ្រី តាហាយ យាយ អឿន តាជាតិ អានម៉ាឌី និងឧកញ៉ាខ្នាជាដើម។

## ការបាត់បង់ជំនឿ ទាពស័ក្តិសិទ្ធិ ការប្រតិបត្តិវប្បធម៌ និងទំនៀមទំលាប់ប្រពៃណី

ការប្រតិបត្តិជំនឿ ទំនៀមទំលាប់ ប្រពៃណី និងវប្បធម៌ដែលចាត់ទុកថាមានភាពអច្ឆរិយៈសក្តិសិទ្ធិបំផុតបានចាប់ផ្តើមសាបរលាប ឬរលាយបន្ទាប់ពីអ្នកក្រៅបានចូលមកដល់។ ឧទាហរណ៍ ដូចជាមនុស្សប្លែកមុខចូលក្នុងភូមិជនជាតិជាលើកដំបូង ត្រូវបានអ្នកភូមិចាប់ផាកពិន័យឲ្យសែនថ្វាយជាគោ ក្របី ទៅតាមបទបញ្ញាផ្ទៃក្នុងនៃភូមិនីមួយៗ ដើម្បីកុំឲ្យមានភាពចង្រៃឧបទ្រព្យ ឬជំងឺឈឺថ្កាត់ដល់សមាជិកភូមិ។ អ្នកភូមិធ្លាប់មានជំនឿថាអារក្សអ្នកតាវិញ្ញាណសក្តិសិទ្ធិតែងតែនៅជួយថែរក្សា និងការពារព្រៃព្រឹក្សា ហើយនាំមកនូវសេចក្តីសុខសាន្ត និងសុវត្ថិភាព។ ឥឡូវនេះពួកគេ មានជំនឿថា បន្ទាប់ពីមានឧស្សាហកម្មកាប់ឈើ និងមនុស្សចំណូលថ្មី បានចូលមកដល់តំបន់នេះវាបានធ្វើឲ្យវិញ្ញាណអ្នកតាចេញទៅបាត់អស់។ តំបន់ ព្រៃការពារ និង តំបន់ព្រៃអារក្សមួយចំនួនដែលសម្បូរណ៍ទៅដោយឈើប្រណីត និងជាតំបន់ពូកែសក្តិសិទ្ធិ។ មេកន្ទ្រាញជនជាតិដើមភាគតិចជាច្រើន បាននិយាយថាពួកគាត់បានចាញ់បោកការលួងលោមរបស់ក្រុមហ៊ុន ដោយធ្វើពីធីបួងសួងសុំកាប់ឈើនៅក្នុងតំបន់នោះ។ តំបន់សក្តិសិទ្ធិរបស់សហគមន៍ ដែលបានក្លាយជាតំបន់គោលដៅកាប់ឈើដ៏សម្បើមមួយ (សូមមើលរូបភាព២២ ផែនទីព្រំប្រទល់ តំបន់សក្តិសិទ្ធិនៅតំបន់ អភិរក្សវ៉ឺនសៃ សៀមប៉ាង)។



*រូបភាព២១៖ ផ្លូវកាប់ឈើសង់ដោយកម្មករទ្រើភាពដើម្បីដឹកឈើនៅក្នុងតំបន់សក្តិសិទ្ធិ VSSPCA*




*រូបភាព២២៖ទីតាំងតំបន់សក្តិសិទ្ធិ៣កន្លែងនៅក្នុងVSSPCA ត្រូវបានបំផ្លិចបំផ្លាញខ្ទេចខ្ទីអស់ដោយសារកាប់ឈើ*

## ការបាត់បង់មរតកសំរាប់មនុស្សជំនាន់ក្រោយ

ព្រៃឈើទាំងនេះ មានអាយុរាប់រយឆ្នាំណាស់មកហើយ ដែលត្រូវបានថែរក្សាយ៉ាងយកចិត្តទុកដាក់ដោយមនុស្សជំនាន់មុន។ ឥឡូវព្រៃឈើទាំងនេះ ត្រូវបានបំផ្លិចបំផ្លាញអស់រលីង ហើយទេសភាពបានប្រែប្រួលអស់ទៅហើយ។ សហគមន៍មូលដ្ឋានជឿជាក់ថានៅក្នុងប្រវត្តិសាស្ត្រ អ្នកជំនាន់ក្រោយនឹងស្តីបន្ទោសដល់មនុស្សជំនាន់នេះ ដែលមិនបានការពារព្រៃឈើ ហើយបានធ្វើឲ្យព្រៃឈើវិនាសសាបសូន្យតែម្តង។

## ៧.៣ ការបម្រែបម្រួលធាតុអាកាស

ប្រជាពលរដ្ឋកម្ពុជាជាច្រើនយល់ថា ការបាត់បង់ព្រៃឈើបណ្តាលឲ្យមានការប្រែប្រួលអាកាសធាតុ។ ក្រសួងបរិស្ថានក៏បានថ្លែងដែរថា ឧស្ម័នផ្ទះបៃតង និងសីតុណ្ហភាពកើនឡើងគឺបណ្តាលមកពីវិនាសកម្មព្រៃឈើ។ ប៉ុន្តែគោលនយោបាយបម្រែបម្រួលអាកាសធាតុមិនបានធ្វើការផ្តោតជាសំខាន់លើបញ្ហានេះទេ ផ្ទុយទៅវិញបែរជាផ្តោតការយកចិត្តទុកដាក់តែទៅលើអាជីវកម្មឈើប្រណីតតែប៉ុណ្ណោះ ដើម្បីឆ្លើយតបទៅនឹងទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ។ អ្នកភូមិអះអាងថាការប្រែប្រួលអាកាសធាតុនេះ ហើយធ្វើឲ្យទឹកភ្លៀងធ្លាក់មិនទៀងទាត់ ខ្វះទឹក ហើយតំបន់ខ្លះ កំពុងប្រឈមមុខទៅនឹងភាពរាំងស្ងួត និងតំបន់ខ្លះទៀតធ្លាប់ត្រូវបានជន់លិចលង់ និងភ្លៀងធ្លាក់ខ្លាំង ។

# ៨. អាជីវកម្មឈើប្រណីតរបស់ទ្រី ភាពគ្រុប

## ៨.១ យុទ្ធសាស្ត្រ និងដំណើរការ

ក្រុមហ៊ុន ទ្រី ភាព មានស្លាកសញ្ញាដែលឃើញជាប់ជញ្ជាំងទ្វារ ស្ថានីយ ដេប៉ូ នៅកណ្តាលមានរូបភាពភ្នំទឹកកក និងមានសញ្ញាសំគាល់លេខ១១៦៨ ដែលលេខនេះមានហុងស៊ុយល្អតាមវប្បធម៌ចិន។ រថយន្តដឹកឈើខ្លះប្រើប្រាស់ស្លាកសញ្ញានេះដើម្បីដឹកឈើមានលេខ១៦៨ និងមានសរសេរអក្សរខ្មែរថាក្រុមហ៊ុនទ្រីភាពគ្រុបនៅពីលើ។ ជាទូទៅឡានត្រាក់ដឹកឈើមានលាបពណ៌ខៀវ។ នៅខេត្តរតនគិរីក៏មានរថយន្តជាច្រើនមានស្លាកសញ្ញាសំគាល់ទ្រីភាពគ្រុប ឬ អ៊ីមឌីអេស អ៊ីមផត អេចផត។ រថយន្តកុងតឺន័រមាននិមិត្តសញ្ញាពណ៌បៃតងដោយមានស្លាកសរសេរក្រុមហ៊ុនទ្រីភាព គ្រុបៈ១១៦៨ នៅលើទ្វារឡានទាំងសងខាង។ នៅក្បាលឡាន មិនមានលិខិតបង់ពន្ធផ្លូវទេ តែប៉ូលីសមិនហ៊ានចាប់ឆែកឆេរអ្វីឡើយនេះបង្ហាញឲ្យឃើញថា ក្រុមហ៊ុននេះមិនគោរពច្បាប់ទាល់តែសោះ។

រថយន្តទំនើបៗជាច្រើន បានចតនៅមុខការិយាល័យកណ្តាលនៅភ្នំពេញទល់មុខមន្ទីរពេទ្យព្រះអង្គឌួងក្នុងរាជធានីភ្នំពេញ។ ក្នុងចំណោមរថយន្តថ្មីៗទាំងនោះមានរថយន្តម៉ាក Land cruiser Vigo ពណ៌ខ្មៅ រថយន្តម៉ាក Discovery, Tundra និង Range Rover ជាដើម។ ស្លាកលេខឡានដែលបំពាក់លេខ១៦៨ ត្រូវបានឃើញនៅជាប់រថយន្តនានាដែលបានបង្ហាញពីទំនាក់ទំនងរបស់ក្រុមហ៊ុនទ្រី ភាពគ្រុប (សូមមើលតារាងឧបសម្ព័ន្ធ២)។

កងកំលាំងប្រដាប់អាវុធមកពីយោធា ប៉េអឹម ប៉ូលីស និងមន្ត្រីជាន់ខ្ពស់ក្នុងជួររដ្ឋាភិបាលបានបំរើការងារឲ្យទ្រីភាព (សូមមើលឧបសម្ព័ន្ធ៥ៈបញ្ជីមេការទ្រីភាព)។ បន្ទាប់ពីកិច្ចសន្យាព្រមព្រៀងបានចុះហត្ថលេខាពីប្រធានសហគមន៍ រួចមកថៅកែឈើត្រូវបានចាត់តាំង និងពង្រាយឲ្យចុះធ្វើការកាប់ឈើស្តុកទុក និងដឹកជញ្ជូនទៅកាន់ដេប៉ូ។ ថៅកែឈើត្រូវមានប្រាក់គ្រប់គ្រាន់ ដើម្បីទិញឈើប្រណីត មានរថយន្ត សំរាប់ដឹកជញ្ជូន និងកម្មករផងដែរ។ ក្រុមហ៊ុនទ្រីភាពគ្រុប បានធ្វើកិច្ចព្រមព្រៀងជាមួយថៅកែឈើ ដោយមិនឲ្យទិញឈើពីអ្នកផ្គត់ផ្គង់ឈើដ៏ទៃទៀតបានឡើយ។ ក្រុមហ៊ុនក៏បានបង់ប្រាក់ប្រចាំឆ្នាំទៅឲ្យមន្ត្រីរុក្ខាប្រម៉ាញ់ អ្នកឃ្លាំមើលបរិស្ថាន អាជ្ញាធរខេត្ត អាជ្ញាធរមូលដ្ឋាន និងមន្ត្រីតាមកុងត្រូលនានា ដើម្បីធានាថា ការដឹកជញ្ជូនឈើប្រព្រឹត្តទៅដោយរលូន។

នៅដំណាក់កាលដំបូង មេការបានជួលកម្មករកាប់ឆ្ការព្រៃឈើ និងត្រួសត្រាយផ្លូវដែលងាយស្រួលឲ្យរថយន្តចូលទៅក្នុងព្រៃក្រាស់ៗបាន។ ថៅកែអាចទិញឈើឈរពីសហគមន៍ ឬម្ចាស់ដើមឈើតាមចំការនៅក្នុងព្រៃនោះ ឬទិញតាមផ្ទះអ្នកភូមិ ដោយតម្លៃខ្ពស់។

នៅពេលផ្លូវត្រូវបានគេត្រួសត្រាយស្អាតរួចរាល់ ហើយថៅកែបានជួលអ្នកកាប់ និងបានផ្តល់រណារយន្ត ប្រេងសាំង ព្រមទាំងបង់ប្រាក់ឲ្យកម្មករ១០ដុល្លារ ក្នុងមួយម៉ែត្រគូប ដើម្បីកាប់រំលំដើមឈើ។ បន្ទាប់មក ឈើត្រូវបានគេអារផែតាមទម្រង់នៃការចង់បានរបស់ថៅកែ។ អ្នកកាប់ឈើ និងអ្នកជំនួយការ(ព្រូឡាន) ត្រូវបានជួលដោយថៅកែ ប៉ុន្តែពួកគេមិនមែនជាកម្មករអចិន្ត្រៃយ៍ទេ។

អ្នកបើកឡាន ព្រូឡាន និងអ្នករត់ការ ត្រូវបានគេជួល ចន្លោះពី១៨០ ទៅ២០០ ដុល្លារក្នុងមួយខែ។ ថៅកែឈើបានជួលមនុស្សម្នាក់ជាអ្នករត់ការផ្លូវ និងបង់ប្រាក់ជាមុនទៅឲ្យអាជ្ញាធរតាមកុងត្រូលត្រួតពិនិត្យទាំងអស់ ជាពិសេសអ្នកសារពត៌មាន។ អ្នករត់ការផ្លូវទទួលបានប្រាក់ខែពីថៅកែ ប៉ុន្តែអាចធ្វើការចរចារតម្លៃសំរាប់ការដឹក ជញ្ជូន។ ប្រសិនបើគ្មានអ្នករត់ការផ្លូវនោះទេ អ្នកបើកឡានដឹកឈើក៏មិនអាចបើករថយន្តឆ្លងកាត់កុងត្រូលបានដែរ។ ថៅកែបានបង់ប្រាក់ ២.៥ដុល្លារក្នុងមួយម៉ែត្រគូប សំរាប់ការដឹកជញ្ជូនឈើឆ្លងកាត់ទន្លេ ហើយកម្មករទូករអាចរកប្រាក់ចំណូលបានប្រមាណ២៥០ដុល្លារ ក្នុងមួយថ្ងៃ។

ឈើដែលបានកាប់រួចរាល់ ត្រូវបានគេដឹកជញ្ជូនយកទៅថ្លឹងនៅដេប៉ូ ហើយមេការដេប៉ូធ្វើការទូទាត់លុយឲ្យថៅកែឈើនៅនឹងកន្លែងតែម្តង។ ចំពោះដេប៉ូនៅខេត្ត មេការតាមស្រុកបានធ្វើការថ្លឹងឈើម្តងទៀត និងធ្វើការជ្រើសរើស ប្រភេទ និងគុណភាពឈើ។ បន្ទាប់មកឈើទាំងនោះត្រូវបានគេយកទៅរោងចក្រសម្រាប់សម្ងួត ដើម្បីជៀសវាងការប្រេះស្រាំមុនពេលដឹកជញ្ជូនទៅកាន់ដេប៉ូកុងតឺន័រនៅអូរយ៉ាដាវ។ ឈើមួយចំនួនត្រូវបានគេដឹកផ្ទាល់ទៅកំពង់ផែគូញ៉ើង នៅប្រទេសវៀតណាម ដោយឆ្លងកាត់ព្រំប្រទល់ អូរយ៉ាដាវ និងមួយចំនួនទៀតត្រូវបានបញ្ជូនទៅកាន់ដេប៉ូ កុងតឺន័រ ធំនៅឧត្តុង្គ ខេត្តកំពង់ស្ពឺ និងចុងបញ្ចប់គឺ ដឹកទៅប្រទេសចិន។ ក្រុមហ៊ុនបានធ្វើការទូទាត់ចំណាយ ជាស៊ី/គយ និងពន្ធអាករនៅដេប៉ូកុងតឺន័រនៅឧត្តុង្គឬនៅអូរយ៉ាដាវ ដែលបានរៀបចំរួចជាស្រេចពីភ្នំពេញ។

តួនាទីរបស់មេការ/អ្នកគ្រប់គ្រង គឺមើលការគ្រប់គ្រងការងារទូទៅរបស់ក្រុមហ៊ុន កសាងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរ និងសហគមន៍មូលដ្ឋាន និងត្រួសត្រាយផ្លូវនៅក្នុងព្រៃ។ មេការក៏មានភារកិច្ចធ្វើការបញ្ចុះបញ្ចូល ឬចរចាជាមួយសហគមន៍ព្រៃឈើ និងអាជ្ញាធរមូលដ្ឋាន ដើម្បីទទួលបានការព្រមព្រៀងកាប់ឈើក្នុងតំបន់ព្រៃដែលបានប្រើប្រាស់ដោយសហគមន៍។ ទោះជាយ៉ាងណាការកាប់ឈើនៅតែបន្តទៅមុខ ទោះជាមាន ឬមិនមានការព្រមព្រៀងពីអាជ្ញាធរមូលដ្ឋាន និងពីសហគមន៍ក៏ដោយ។

## ៨.២ សិទ្ធិរបស់ទ្រីភាពគ្រុប ក្នុងការប្រមូល និងទិញឈើពីតំបន់សម្បទានដី

សេដ្ឋកិច្ចនៅខេត្តរតនគិរីក្រុមហ៊ុនទ្រីភាពគ្រុប ទទួលបានសិទ្ធិប្រមូលឈើពីតំបន់សម្បទានដីសេដ្ឋកិច្ចនៅក្នុងខេត្តរតនគិរី តាមលិខិតអនុញ្ញាតលេខៈ១២៧0 ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ដែលចុះហត្ថលេខាដោយលោក ឡោ រស្មី អគ្គលេខាធិការក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ រដ្ឋាភិបាលបានអនុម័តផ្តល់សិទ្ធិប្រមូលឈើគ្រប់ប្រភេទតាមលិខិតលេខៈ៨៥៤ ស ជ ណ ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៤ ចុះហត្ថលេខាដោយឯកឧត្តម ប៊ុន អ៊ុយ ក្នុងនាមទីស្តីការគណៈរដ្ឋមន្ត្រីតាមសំណើរបស់ក្រុមហ៊ុនទ្រីភាព អ៊ីមផត អ៊ិចផត និងអ៊ីមឌីអេស ថ្មដា អេសអ៊ីហ្សិត (Try Pheap Import Export Co., Ltd និង MDS THMORDA SEZ Co., Ltd) តាមរយៈក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងរដ្ឋបាលព្រៃឈើ[20]។

## ៨.៣ ការកាប់ឈើ ការប្រមូល ការស្តុកទុក និងការដឹកជញ្ជូនឈើប្រណីត

ក្រុមហ៊ុនទ្រីភាពគ្រុបបានចំណាយ ១០ដុល្លា ក្នុងឈើមួយម៉ែត្រគូប ទៅឲ្យកម្មករ និងអ្នកក្រឡឹងឈើ ហើយមេការបានផ្គត់ផ្គង់រណាយន្ត សាំង និងអាហារដល់ពួកគេជារៀងរាល់ថ្ងៃ។ គិតមកដល់ខែមិថុនា ឆ្នាំ២០១៤ យ៉ាងហោចណាស់មានដេប៉ូធំៗរបស់ក្រុមហ៊ុនទ្រីភាពចំនួន១៤ ដែលបានកំពុងស្តុកឈើមកពីភាគខាងជើងនៃខេត្តរតនគីរី និងស្ទឹងត្រែង រួមបញ្ចូលឧទ្យានជាតិវីរៈជ័យ ដែលដេប៉ូទាំងនោះមានឈ្មោះដូចខាងក្រោមៈ

១ .ដេប៉ូនៅកាចូនខាងក្រោយការិយាល័យរដ្ឋបាលព្រៃឈើស្រុកវ៉ឺនសៃ

២ .ដេប៉ូស្នូចឈើនៅភូមិហ្វាំង ឃុំប៉ុង ស្រុកវ៉ឺនសៃ

៣ .ដេប៉ូនៅស្រុកតាវែង

៤ .ដេប៉ូនៅស្រុកអូរជុំ

៥ .ដេប៉ូនៅស្រុកអណ្តូងមាស

៦ .រោងម៉ាស៊ីនអារឈើនៅអណ្តូងមាស

៧ .ដេប៉ូកុងតឺន័រនៅអូរយ៉ាដាវ

[20] លិខិតលេខៈ៨៥៤ ស ជ ណ ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៤ និងលិខិតលេខៈ ១០៤៩ សជណ ចុះថ្ងៃទី ២៤ កក្កដា ២០១៤ចេញដោយទីស្តីការគណៈរដ្ឋមន្ត្រី និងលិខិតលេខៈ៤៨៧៣ ចុះថ្ងៃទី២៥ កក្កដា ២០១៤ ចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផ្តល់សិទ្ធិឲ្យទ្រីភាពគ្រុបប្រមូលឈើពីរដ្ឋបាលព្រៃឈើ

៨ .ដេប៉ូនៅវាលវង់ សៀមប៉ាង

៩ .ដេប៉ូនៅកោះឃ្លាំង សៀមប៉ាង

១០ .ដេប៉ូនៅបានលុង ខេត្តរតនគីរី

១១ .ដេប៉ូស្តុកឈើនៅជិតរោងចក្រតៃវ៉ាន់ នៅបានលុង

១២ .រោងចក្រសំរាប់សម្ងួតឈើនៅបានលុង (ដេប៉ូថ្មីត្រូវបានគេសាងសង់នៅបាងលុង ជិតបឹងកន្សែង)

១៣ .ដេប៉ូនិងរោងចក្រអារឈើនៅក្នុងក្រុមហ៊ុនអ៊ឹមឌីអេសអ៊ឹមផត អ៊ិចផត

១៤ .ដេប៉ូនិងរោងចក្រអារឈើនៅក្នុងក្រុមហ៊ុនទ្រីភាពអ៊ឹមផត អ៊ិចផត

ក្រុមហ៊ុនទ្រីភាព បានពង្រាយមេការ និងកម្មករចូលទៅស្ទើរតែគ្រប់តំបន់ព្រៃការពារនានា ដូចជា៖ បាក់កែ កាពីន តាឡៃ ស្រម៉ ចាន់ទូក ភូមិចាម កោះចាន់ អូរទីប កោះពាក ផាបាំង អូរស្រ ម៉ អូរស្នេង អូរថ្មរលួយ អូរកំផាក អូរទង់ អូរច្រាំង ជំរុំជលផាត (អូរខ្សាច់) អូរតាពើ (ព្រំដែនឡាវ) វាលអណ្តែង វាលធំ អូរតាបូក អូរចង អូរចាយ អូរគ្រាល អូរប្រា អូរមឿងទើស អូរមឿងហាយ អូរ ឡាឡៃ អូរតាឡាវ អូរកាតាល់ អូរគំនាប់ អូរក្រូច ភ្នំតាង៉ូវ ចំណ ង បោ រ ហុង ដាក់ឡេច ប៉ុកប៉ា ត់ អូរ អំបិល ដាក់បើក ដាក់ឡាក់ អូរឡឺ អូរកាផា អូរជាងហ៊ាង អូរក្រញូង អូរខ្នាង យាក់ខៀវ អូរចិន អូរ ហុង អូរកូន ខាន់ម៉ាក់វ៉ែន អូរកាសៀប អូរឆាយជ្រី អូរប្រា វាលកញ្ចាញ់ហេង វាលចាក់យ៉ត អណ្តូង សាវ៉ានបាវ ព្រៃចង វាលរំកិន អូរតាម៉ល អូរចាអ៊ីន អូរកាទ្រីល អូរភួយ បឹងធិនកាង កាឈូក ពោង ពាយ តាបាក់ អូរ ឡង់ ខាំជារៀង ភ្នំដែកកេះ ភ្នំវាលធំ ភ្នំលង់ ភ្នំក្រោយ ភ្នំរលក ភ្នំយ៉ាកខាំ ភ្នំហាឡាន ភ្នំ អៀ លចេង ភ្នំ ហា ន់ជ្រី ភ្នំអូរជានឿង ភ្នំត្រាវទុក ភ្នំជន្ទួចច្រេង ភ្នំអូរដយ ភ្នំពង្រៀ ភ្នំស្រម៉ ភ្នំសង្កូវ ភ្នំវល្លិ៍អង្គិញ ភ្នំស្រម៉ និង ភ្នំកាតាំ។

(សូមមើលឧបសម្ព័ន្ធ ៧ សំរាប់បញ្ជីទីតាំងនៃតំបន់ទាំងនេះ)




*រូបភាព២៣៖ ដេប៉ូឈើទ្រីភាពនៅទូទាំងប្រទេសកម្ពុជា ២០១៤*

ដែនជម្រកសត្វព្រៃនៅលំផាត់ ត្រូវបានកាប់បំផ្លាញយ៉ាងធ្ងន់ធ្ងរចាប់តាំងពីឆ្នាំ២០០៩ ដោយមានក្រុមហ៊ុនជាច្រើន បានទៅធ្វើការនៅតំបន់នោះ ប៉ុន្តែពួកគេបានចាកចេញទៅវិញ បន្ទាប់ពីមិនមានឈើប្រណិតនៅសេសសល់តទៅទៀត។ សហគមន៍បានរាយការណ៍ថា ដំណើរការកាប់ឈើត្រូវបានធ្វើឡើងជាប្រព័ន្ធ ដោយមានបាញ់ថ្នាំជាសញ្ញាកំណត់សំគាល់ជាប់នឹងដើមឈើ។ អ្នកភូមិបាននិយាយថាការរៀបចំបែបនេះ គឺធ្វើឡើងដោយមន្ត្រីបរិស្ថានក្នុងមួយខែ១០០០០ដើម ឬចំងាយ១០ គីឡូម៉ែត្រ ដោយមានសញ្ញាសំគាល់លេខកូដឈើផ្សេងៗគ្នាអាស្រ័យលើមេការ ហើយសញ្ញាសំគាល់ទាំងនោះមានដូចជា M53 M63 SA KM556 CK CM CR, 73 ជាដើម។

រូបថតខាងក្រោមនេះបង្ហាញពីការប្រមូល ការដឹកជញ្ជូន ការស្តុក ដេប៉ូ និងការនាំចេញឈើហ៊ុប ដោយទ្រីភាពគ្រុប ដែលបញ្ជាក់ការពិតអំពីការកាប់ឈើខុសច្បាប់នៅរតនគិរីៈ




រូបភាព២៤៖តំបន់កាប់ឈើនៅក្នុងឧទ្យានជាតិវីរៈជ័យ ចំណុចបៃតងតំបន់កាប់ឈើ និងចំណុចត្រីកោណក្រហម ជាដេប៉ូទ្រីភាព



រូបភាព២៥ និង២៦៖ ឈើប្រណីត





*រូបភាព ២៧ និង ២៨៖ ឈើធ្នង់ត្រូវបានកាប់រំលំ និងដឹកជញ្ជូនចេញពីព្រៃដោយកម្មករក្រុមហ៊ុនទ្រីភាពគ្រុបក្នុងអូរក្រាយ វ៉ឺនសៃ នៃឧទ្យានជាតិវីរៈជ័យ*



*រូបភាព២៩៖:ទាហានកាប់ឈើរបស់តាហយដឹកឈើពីភ្នំក្រាយក្នុងឧទ្យាជាតិវីរៈជ័យទៅដេប៉ូតាហយ នៅឃុំកូកឡាក់ ស្រុកវ៉ឺនសៃ (X: 698836, Y: 1560451).*



*រូបភាព៣០៖ ទាហានកាប់ឈើតាលាងកាប់ឈើនៅចំណុចភ្នំស្រម៉រ ចំណុច(X: 676831, Y: 1562730)*




*រូបភាព៣១ និង៣២៖ តាត្រីដឹកឈើពីវាលអណ្តែងក្នុងវីរៈជ័យនៅស្រុកតាវែងទៅដេប៉ូតាគញរី នៅភូមិផាវ ចំណុច(X: 723848,  Y: 1579255 និងការដឹកជញ្ជូនឈើឆ្លងកាត់អូរឡាឡៃ កូកឡាក់*




*រូបភាព៣៣ និង៣៤៖ រថយន្តដឹកឈើរកឃើញនៅក្នុងឧទ្យានជាតិវីរៈជ័យ ដឹកទៅដេប៉ូទ្រីភាពនៅវ៉ឺនសៃ*



*រូបភាព៣៥៖ ការដឹកជញ្ជូនឈើប្រណីតពីឧទ្យានជាតិវីរៈជ័យទៅកាន់ដេប៉ូទ្រីភាពនៅតាវែង*





*រូបភាព៣៦ និង៣៧៖ កម្មករដឹកឈើចេញពី ឧទ្យានជាតិវីរៈជ័យតាមផ្លូវទៅដេប៉ូទ្រីភាព*



*រូបភាព៣៨ ៖ត្រាក់ទ័រគាបឈើ ដាក់ចូលក្នុងមាស៊ីនរ៉ៃ*



*រូបភាព៣៩៖ ត្រាក់ទ័រអូសឈើចុះពីភ្នំរកឃើញ ក្នុងឧទ្យានជាតិវីរៈជ័យ*



*រូបភាព៤០៖ ការដឹកជញ្ជូនឆ្លងកាត់ទន្លេសេសាន នៅប៉ាកាឡាន់ ស្រុកវ៉ឺនសៃ*
*(X: 694037, Y: 1541823)*



*រូបភាព៤១៖ ការដឹកជញ្ជូនដោយម៉ូតូនៅអណ្ដូងមាស*





រូបភាព៤២ និង៤៣៖ ការដឹកជញ្ជូនឈើពីឧទ្យានជាតិវីរៈជ័យនៅទៅកាន់ដេប៉ូឈើទ្រីភាពនៅតាវែង





រូបភាព៤៤ និង៤៥៖ ការដឹកជញ្ជូនឈើនៅសៀមប៉ាង និងត្រាក់ទ័រឈូសឆាយផ្លូវដឹកឈើ





រូបភាព៤៦ និង៤៧៖ ទាហានជាកម្មករគាស់ឈើទំលាក់ទន្លេនៅវ៉ឺនសៃ



*រូបភាព៤៨ និង៤៩៖ រថយន្តដឹកជញ្ជូនឈើពីឧទ្យានជាតិវីរៈជ័យនៅទៅកាន់ដេប៉ូឈើទ្រីភាពនៅតាវែង*



*រូបភាព៥០ និង៥១៖ រថយន្តដឹកជញ្ជូនឈើពីឧទ្យានជាតិវីរៈជ័យនៅទៅកាន់ដេប៉ូឈើទ្រីភាពនៅសៀមប៉ាង*



*រូបភាព៥២ និង៥៣៖ លេខកូដឈើFNរបស់វៀតណាមមេការទ្រីភាពរកឃើញនៅឧទ្យានជាតិ វីរៈជ័យ*



*រូបភាព៥៤ និង៥៥៖ រថយន្តស្ទូចឈើនៅទន្លេសេសាន ស្រុកវឺនសៃ*




រូបភាព៥៦ និង៥៧៖ រថយន្តដឹកជញ្ជូនឈើមូលឆៅទៅកាន់ដេប៉ូឈើទ្រីភាពនៅសៀមប៉ាង



រូបភាព៥៨ ៖ រថយន្តដឹកជញ្ជូនឈើទ្រីភាព
ពីរតនគីរីមកកាន់ដេប៉ូកុងតឺន័រនៅឧត្តុង្គ កំពង់ស្ពឺ



រូបភាព៥៩៖ រថយន្តកុងតឺន័រដឹកជញ្ជូនឈើពីដេប៉ូឈើទ្រីភាពទៅកាន់កំពង់ផែអន្តរជាតិ





រូបភាព ៦០ និង៦១៖ រថយន្តកុងតឺន័រដឹកជញ្ជូនឈើពីដេប៉ូឈើទ្រីភាពទៅកាន់កំពង់ផែអន្តរជាតិ



រូបភាព៦២៖ដេប៉ូក្រុមហ៊ុនទ្រីភាពគ្រុបនៅបានលុង



រូបភាព៦៣៖ដេប៉ូក្រុមហ៊ុនទ្រីភាពគ្រុបនៅសៀមប៉ាង



រូបភាព៦៤៖ដេប៉ូក្រុមហ៊ុនទ្រីភាពគ្រុបនៅគោកឃ្លៀង ស្ទឹងត្រែង



រូបភាព៦៥៖ដេប៉ូកុងតឺន័រនៅអូរយ៉ាដាវ



រូបភាព៦៦៖ការដឹកជញ្ជូនពីព្រៃទៅដេប៉ូ



រូបភាព៦៧៖ការដឹកជញ្ជូនពីខេត្តទៅឧដុង្គ



រូបភាព៦៨៖ដេប៉ូធំក្រុមហ៊ុនទ្រីភាពគ្រុបនៅឧដ្ដុង្គកំពង់ស្ពឺ



រូបភាព៦៩៖ខ្សែរថយន្តកុងតឺន័រនៅកំពង់ផែអន្តរជាតិ




រូបភាព៧០៖ការដឹកជញ្ជូនទៅកំពង់ផែអន្តរជាតិ



រូបភាព៧១៖រថយន្តកុងតឺន័រមកដល់កំពង់ផែអន្តរជាតិ



រូបភាព៧២៖ កុងតឺន័រត្រូវបានស្ទូចចូលកប៉ាល់



រូបភាព៧៣៖កប៉ាល់ផ្ទុកឈើដឹកទៅចិន

# ៩. ការនាំឈើប្រណីតចេញដោយក្រុមហ៊ុនទ្រី ភាព គ្រុប

ឈើនៅកម្ពុជាភាគច្រើនត្រូវបាននាំចេញទៅកាន់ប្រទេសវៀតណាម ឡាវ និងចិន។ ប្រទេសផ្សេងទៀតរកស៊ីជាដៃគូអាជីវកម្ម ឬជាឈ្មួញកណ្តាលដែលទិញឈើដឹកឆ្លងកាត់ទៅប្រទេសចិន ឬប្រទេសមួយចំនួននៅអាស៊ី សំរាប់ផលិតគ្រឿងសង្ហារឹម។ ទីផ្សារគ្រឿងសង្ហារឹមផ្សេងទៀត គឺមិនទាន់ត្រូវបានស៊ើបអង្កេតនៅឡើយទេ។

ឯកសារនាំឈើចេញបញ្ជាក់ថា អ្នកនាំចេញគឺជារដ្ឋាភិបាលកម្ពុជា និងបានបញ្ជាក់ថាប្រទេសគោលដៅ គឺសាធារណៈរដ្ឋប្រជាមានិតចិន។ អាជ្ញាប័ណ្ណនេះមិនបានដាក់ឈ្មោះឈើប្រណីត ឬឈើខ្នាតធំ(ដែលក្រាស់ជាង២៥សម)ទេ ដោយសារការនាំចេញ ខុសច្បាប់[21]។

រូបភាពជាច្រើន ដែលបានប្រមូលផ្តុំសំរាប់របាយការណ៍នេះ បង្ហាញពីភស្តុតាងក្រុមហ៊ុនទ្រី ភាពគ្រុប និងផ្នែកខ្លះដែលរដ្ឋាភិបាលកំពុងពាក់ព័ន្ធក្នុងការកាប់បំផ្លាញឈើខុសច្បាប់។ រូបភាពបង្ហាញថាឈើជាច្រើនកំពុងត្រូវបានគេកាប់ ដឹកជញ្ជូន និងស្តុកនៅតាមដេប៉ូដែលសុទ្ធសឹងតែជាប្រភេទឈើប្រណីតធំៗ ដូចជា ក្រញូង បេង នាងនួន គ្រើល និងធ្នង់ ដើម្បីផ្គត់ផ្គង់តម្រូវការទីផ្សារចិនដូចដែលបានបង្ហាញនៅក្នុងឯកសារភ្ជាប់មកជាមួយ។

លិខិតបើកផ្លូវពីរដ្ឋបាលព្រៃឈើ (LP/B) ជួយសំរួលមធ្យោបាយដល់ក្រុមហ៊ុនទ្រីភាពគ្រុប ដើម្បីដឹកជញ្ជូនឈើពីក្នុងព្រៃ រហូតដល់ដេប៉ូកុងតឺន័រនៅត្នោតពង ឧត្តុង្គ ខេត្តកំពង់ស្ពឺ។ កងកម្លាំងប្រដាប់អាវុធបានផ្តល់ការការពារសន្តិសុខនៅគ្រប់ជាន់ថ្នាក់ទាំងអស់។ មន្ត្រីរដ្ឋាភិបាលក៏បានជួយសម្របសម្រួលឯកសារដឹកជញ្ជូននាំឈើចេញដោយរលូន និងបែបបទនីតិវិធីនានាតាមរយៈនាយកដ្ឋានគយ និងអគ្គនាយកដ្ឋានត្រួតពិនិត្យទំនិញ នីហរណ៍-អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) នៃក្រសួងពាណិជ្ជកម្មកម្ពុជាអាហ័រណ សម្រាប់ឈើដែលគោលដៅនាំចេញទៅប្រទេសចិនតាមរយៈក្រុមហ៊ុនដឹកជញ្ជូន ហុងកុង គីនចុង (Hong Kong Kin Chung Transportation Co., Ltd.)។

ក្រុមហ៊ុនទ្រីភាពគ្រុប ធ្វើការក្នុងនាមមន្ត្រីរដ្ឋាភិបាលកម្ពុជាមួយចំនួន (តាមរយៈរដ្ឋបាលព្រៃឈើ) ដើម្បីធានាឲ្យបាននូវការផ្គត់ផ្គង់ឈើប្រណីតប្រកបដោយប្រសិទ្ធិភាព និងគ្រប់ចំនួនទៅប្រទេសចិន។ ហេតុនេះហើយបានជារដ្ឋាភិបាលគ្រប់គ្រងមន្ត្រីគ្រប់រូបចាប់ពីអាជ្ញាធរថ្នាក់មូលដ្ឋានទៅដល់ថ្នាក់ជាតិជាពិសេសមន្ត្រីបរិស្ថានរុក្ខាប្រមាញ់ និងកងកម្លាំងប្រដាប់អាវុធ។ រដ្ឋាភិបាលក៏បានគ្រប់គ្រងក្រុមហ៊ុនបុត្រសម្ព័ន្ធដែលជាសាខា ផ្គត់ផ្គង់ឈើប្រណីតឲ្យក្រុមហ៊ុនទ្រីភាពគ្រុបផងដែរមានដូចជាៈ ក្រុមហ៊ុនសុខសំណាង ក្រុមហ៊ុន ស៊ីអរស៊ីខេ ក្រុមហ៊ុន

[21] ឧទាហរណ៍អនុក្រឹត្យ១៣១អំពីការអនុញ្ញាតឲ្យនាំចេញទៅបរទេស

អានម៉ារឌី, ក្រុមហ៊ុនសិលាដាម៉ិច ក្រុមហ៊ុនសុវណ្ណភូមិ ក្រុមហ៊ុនលឹម ប៊ុណ្ណា ក្រុមហ៊ុន ហ័ង អាញ យ៉ាឡាយ (Hoang Anh Gialai) និងក្រុមហ៊ុនក្រុងប៊ុកជាដើម។

អាជ្ញាប័ណ្ណនាំចេញត្រូវបានអនុញ្ញាតដោយចំណារយល់ព្រមលេខៈ០១៩/ពណពតផ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២១០៤ បោះត្រា និងចុះហត្ថលេខាដោយ ឯកឧត្តមស៊ុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងចំណារយល់ព្រមលេខៈ០១៤ រពណឧសណ ចុះថ្ងៃទី៧ ខែមិនា ឆ្នាំ២០១៤ បោះត្រា និងចុះហត្ថលេខាដោយ ឯកឧត្តមបណ្ឌិត ឆេង គឹមស៊ុន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ អាជ្ញាប័ណ្ណនាំចេញរបស់ទ្រី ភាពគ្រុប ត្រូវបានគាំទ្រដោយរដ្ឋាភិបាលដែលមានឯកសារយោងចំនួនពីរ៖ ១) លិខិតលេខៈ ១៥១ សជណ ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី និង ២) លិខិតលេខៈ ១៨៩សណបថ ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១២របស់ក្រសួងបរិស្ថាន។ អាជ្ញាប័ណ្ណនេះត្រូវបានអនុម័ត និងបានផ្តល់គោលការណ៍ដល់ក្រុមហ៊ុនទ្រី ភាពគ្រុប ដើម្បីនាំចេញឈើចំនួន ១០០ ០០០ ម៉ែត្រគូប ឬ ៤៥០០កុងតឺន័រ ដែលបានដឹកជញ្ជូនចេញពីតំបន់ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនទ្រីភាព អ៊ីមផត អ៊ិចផត ខូអិលធីឌី និងក្រុមហ៊ុនអ៊ីមឌីអេស អ៊ីមផត អ៊ិចផត ខូអិលធីឌី(សូមមើលឧបសម្ព័ន្ធ១០-១៣។




*រូបភាព៧៤៖ការដឹកជញ្ជូនឈើដ៏មហិមា និងផ្លូវនាំឈើចេញ*

តំណាងរដ្ឋបាលព្រៃឈើបានរៀបចំឲ្យមានការនាំចេញឈើ។ ពួកគេបានយកចិត្តទុកដាក់លើការបំពេញបែបបទទាំងអស់សម្រាប់ ក្រុមហ៊ុនទ្រីភាព អ៊ីមផតអ៊ិចផត ដែលមានការិយាល័យនៅផ្ទះលេខ ១អា ផ្លូវ២៧១ សង្កាត់ទឹកល្អក់៣ ភ្នំពេញ។ មានករណីមួយដែលឯកសារនាំចេញបានរាយឈ្មោះប្រទេសប្រភពដើមក្នុងការនាំចេញគឺកម្ពុជា ហើយប្រទេសគោលដៅគឺជាសាធារណៈរដ្ឋប្រជាមានិតចិន និងអ្នកបញ្ជាទិញពីបរទេសគឺជាក្រុមហ៊ុនដឹកជញ្ជូនហុងកុងគីនផុង។

អាស័យដ្ឋានរបស់ក្រុមហ៊ុននេះគឺជាផ្ទះល្វែងលេខ ៣៨១០ ផ្ទះកាហ្វេ តំបន់កាស៊ីង ទីក្រុងហ្វានលីង ទីក្រុងហុងកុង សាធារណៈរដ្ឋប្រជាមានិតចិន។ អាជ្ញាប័ណ្ណនេះ មានសុពលភាព ពីថ្ងៃទី១២ ខែមិនា ឆ្នាំ២០១៤ រហូតដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៤ និងត្រូវបានអនុញ្ញាតិសម្រាប់ការនាំចេញឈើលេខ១ ជាឈើជ្រុង ដោយមានទទឹងអតិបរមា និងកម្រាស់ ២៥សម និងចំនួនឈើសរុប ៤,៧០៦.៣៣៩៦ម៉ែត្រគូប (ស្មើនឹង២០៧កុងតឺន័) ដែលមួយម៉ែត្រគូប មានតម្លៃ៥១០ដុល្លា ដូច្នេះ តម្លៃសរុបគឺ ២,៣៤៩,៧៤៣.២០ដុល្លា។ លក្ខខណ្ឌនៃការដឹកជញ្ជូនទំនិញនេះត្រូវបានផ្អែកលើរូបមន្ត (ដឹកជញ្ជូនទំនិញទូទាត់នៅត្រឹមកំពង់ផែ) និងរូបមន្តធីធីអរ(TTR) ដែលត្រូវបានដឹកជញ្ជូនពីកំពង់ផែអន្តរជាតិខេត្តព្រះសីហនុ និងបាននាំចេញតាមកប៉ាល់ទៅប្រទេសចិន។ ការដឹកជញ្ជូននេះ ស្ថិតនៅក្រោមអាជ្ញាប័ណ្ណនាំចេញលេខៈ ០០០៣៤ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

ការស៊ើបអង្កេតរបស់យើងបានរកឃើញថា មន្ត្រីគយបានជួយពិនិត្យមើលឲ្យប្រាកដថារាល់ឯកសារនាំចេញមានភាពត្រឹមត្រូវនិងស្របច្បាប់។ ឧទាហរណ៍ពួកគេជួយផ្ទៀងផ្ទាត់ចំនួនទឹកប្រាក់និងតម្លៃឈើ និងកាត់បន្ថយតម្លៃក្នុងវិក័យប័ត្រដើម្បីបន្ទាបពន្ធនាំចេញ(FOB ) រហូតដល់១%។ ការចំណាយនៃការដាំដើមឈើឡើងវិញ គឺមិនត្រូវបានបង្ហាញទេ។ យោងតាមការស៊ើបអង្កេត ក្រុមហ៊ុននេះបាននាំចេញឈើប្រណីតប្រភេទធ្នង់ ប៉ុន្តែនៅក្នុងឯកសារបានដាក់ថាជាឈើប្រភេទ លេខ១ ដែលមានតម្លៃ៥១០ដុល្លារ ក្នុងមួយម៉ែត្រគូប ដែលតម្លៃជាក់ស្តែងនៅលើទីផ្សារ គឺជាង ២០០០ដុល្លារមួយម៉ែត្រគូប (តម្លៃនៅព្រំដែន)។ ការស៊ើបអង្កេតរបស់យើងបានរកឃើញថាទាំងនៅក្នុងព្រៃ និងនៅតាមដេប៉ូឈើ ដែលកំពុងត្រូវបានយកដោយក្រុមហ៊ុននេះគឺឈើឃ្លុំ មានរាងបួនជ្រុងទ្រវែង មានទំហំទទឹង និងកំរាស់លើសពី ៣០សម x ៣០សម x ២២០សម ។ ទោះជាយ៉ាងណា មន្ត្រីគយបានឃុបឃិតជាមួយក្រុមហ៊ុនបន្លំឯកសារនាំចេញ ហេតុដូច្នេះបានជាគេដាក់ កំរាស់ត្រឹមតែ២៥សមប៉ុណ្ណោះដើម្បីឲ្យអនុលោមទៅតាមច្បាប់ (អនុក្រឹត្យលេខៈ១៣១ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ ដែលហាមឃាត់ការនាំចេញឈើដែលមានកម្រាស់លើស២៥សម)។ នេះសបញ្ជាក់ឲ្យឃើញថាក្រុមហ៊ុននេះបានក្លែងបន្លំឯកសារ ដើម្បីបន្ទាបតម្លៃអត្រាបង់ពន្ធ និងជៀសវាងការត្រួតពិនិត្យដោយគយអន្តរជាតិ។ បន្ទាប់មកទៀត ក្រុមហ៊ុននេះ អាចនឹងមានការផ្តល់មូលនិធិទ្រទ្រង់មិនសមរម្យណាមួយពីរដ្ឋផងដែរ។

# ១០.បទវិភាគផ្នែកច្បាប់ចំពោះសកម្មភាពកាប់ឈើនៅខេត្តរតនគីរី

ការកាប់ឈើនៅកម្ពុជា គឺកំពុងតែអនុវត្តន៍នៅក្នុងតំបន់ពណ៌ប្រផេះដែលត្រូវបានធ្វើអាជីវកម្មឬកេងប្រវ័ញ្ចដោយសម្បទានិក និងអ្នកដែលកំពុងនាំឈើចេញទៅក្រៅ។ នៅត្រង់ចំណុចនេះ យើងពិភាក្សាពីនីត្យានុកូលភាពនៃអាជីវកម្មឈើ។

## ១០.១ អ្វីជាភាពខុសគ្នារវាងសកម្មភាពកាប់ឈើស្របច្បាប់ និងខុសច្បាប់?

ការកាប់ឈើជាសកម្មភាពស្របច្បាប់មួយ នៅពេលដែលអនុវត្តន៍ស្របទៅតាមបទបញ្ញត្តិនានានៃច្បាប់។ សម្បទានិកដែលត្រូវបានផ្តល់សម្បទានដីសេដ្ឋកិច្ចជូនត្រូវបានអនុញ្ញាតិឲ្យកាប់ឈើនៅក្នុងតំបន់សម្បទានរបស់ខ្លួន ដោយមិនឲ្យកាប់ឆ្លួល/ធ្លាក់ចូលនៅក្នុងតំបន់ស្នូល ឬតំបន់អភិរក្សឡើយ[22]។ ទោះបីជាយ៉ាងណាក៏មិនមែនមានន័យថាឈើគ្រប់ប្រភេទ និងគ្រប់ទំហំត្រូវបានអនុញ្ញាតិឲ្យកាប់ឬប្រមូលឡើយ។ មាត្រ២៩នៃច្បាប់ព្រៃឈើហាមឃាត់ការប្រមូលផលឈើប្រភេទកំរ ឬឈើដែលជំរមានតម្លៃខ្ពស់នៅក្នុងព្រៃបំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋ[23]។ មានត្រា៤៣ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិក៏បានចែងបន្ថែមថា គ្មានបុគ្គលណា ឬនីតីបុគ្គលណាអាចយកដី ឬសារធាតុផ្សំនៃធនធានធម្មជាតិពីតំបន់ការពារធ្វើជាកម្មសិទ្ធិបានទេ[24]។ នេះមានន័យថាឈើនៅក្នុងតំបន់ការពារដូចជាឧទ្យានជាតិវីរៈជ័យ ឬដែនជំរកសត្វព្រៃលំផាត់ មិនអាចកាប់រំលំបានឡើយ លុះត្រាណាតែឈើនោះនៅក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច។ ភស្តុតាងពីក្រុមអ្នកស៊ើបអង្កេតបានរកឃើញថាកម្មករ មេការ និងអ្នកកាប់ឈើត្រូវបានពង្រាយពេញព្រៃដើម្បីកាប់ និងប្រមូលឈើប្រណីតពីតំបន់ការពារពីដែនជំរកសត្វព្រៃ និងពីព្រៃរក្សាទុកជាអចិន្ត្រៃយ៍របស់រដ្ឋដែលនៅខាងក្រៅតំបន់សម្បទានដីសេដ្ឋកិច្ចដែលសកម្មភាពកាប់ឈើបែបនេះ គឺខុសច្បាប់។ សកម្មភាពរបស់ទ្រី ភាព គឺផ្ទុយពីលិខិតជូនដំណឹងលេខៈ១៧៧ និងលិខិតលេខៈ២០៦ ចេញដោយក្រសួងបរិស្ថានដែលហាមឃាត់ក្រុមហ៊ុនឯកជននានាចូលទៅក្នុងតំបន់ព្រៃការពារ តំបន់អភិរក្ស និងព្រៃរក្សាបំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋ។

សកម្មភាពកាប់ឈើបន្ថែមទៀត ដែលខុសច្បាប់ក្រោមច្បាប់ប្រទេសកម្ពុជារួមបញ្ចូលទាំងការកែច្នៃឈើដែលបានរំលំនិងអនុផលរបស់វា។ ក្រោមមាត្រា៣០នៃច្បាប់ព្រៃឈើត្រូវបានហាមឃាត់មិនឲ្យបង្កើត ឬប្រតិបត្តិការសេវាកែច្នៃឈើផលិតផលអនុផលព្រៃឈើនៅក្នុងវិស័យព្រៃបំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ហើយទាមទារមិនឲ្យមានសេវាកែច្នៃឈើ ដែលមាន

[22] ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ មាត្រា១១

[23] ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២២០២ មាត្រា២៩

[24] ច្បាប់តំបន់ការពារធម្មជាតិ មាត្រា៤៣

ទីតាំងយ៉ាងហោចណាស់ ៥គីឡូម៉ែត្រ ពីដែនបំរុងទុក[25]។ មាត្រា៤២ នៃច្បាប់តំបន់ការពារធម្មជាតិ ក៏បានហាមឃាត់ការកែច្នៃធនធានធម្មជាតិនិងអនុផលព្រៃឈើនៅក្នុងតំបន់ការពារ[26]។ តាមសកម្មភាពកែច្នៃឈើនៅក្នុងរតនគីរី គឺខុសច្បាប់ប្រសិនបើប្រព្រឹត្តិដោយអ្នកកាប់ឈើនៅក្នុងតំបន់ការពារដូចជាឧទ្យានជាតិវីរៈជ័យ ឬដែនជំរកសត្វព្រៃលំផាត់ជាដើម។

## ១០.២ សេចក្តីសន្និដ្ឋានពីការវិភាគផ្នែកច្បាប់លើអាជីវកម្មឈើប្រណីតរបស់ទ្រីតាពគ្រុប

ការស៊ើបអង្កេតបានរកឃើញថាឯកសាររបស់ក្រុមហ៊ុន គឺខុសច្បាប់ ហើយក្រុមហ៊ុនមិនអនុវត្តតាមនីតិវិធីច្បាប់ក្នុងការនាំឈើចេញនោះទេ។ យើងបានរកឃើញឯកសារខ្លះបានរៀបចំដោយក្លែងបន្លំ តែត្រូវបានការពារដោយផ្នែក/ស្ថាប័នមួយចំនួនរបស់រដ្ឋាភិបាលដោយសារតែមន្ត្រីខ្លះរបស់រដ្ឋបានទទួលអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុនៅក្នុងការនាំឈើចេញ។

ការស៊ើបអង្កេតបានរកឃើញភាពមិនប្រក្រតីនៃអំពើខុសច្បាប់ និងនីតិវិធីក្នុងដំណើរការនាំឈើចេញ និងអាជីវកម្មឈើរបស់ក្រុមហ៊ុនទ្រីភាពគ្រុប ដូចខាងក្រោមៈ

1. អាជ្ញាប័ណ្ណ លិខិតអនុញ្ញាតផ្សេងៗផ្តល់សិទ្ធិឲ្យប្រមូលផល អនុផលព្រៃឈើការដឹកជញ្ជូនឈើកែច្នៃមានចំនួនច្រើនរហូតដល់ ១០០ ០០០ មែត្រ គូបមិនបានឆ្លងកាត់ការពិភាក្សាពីស្ថាប័ននីតិបញ្ញត្តិ។ មិនមានការប្រកាសដេញថ្លៃជាសាធារណៈ និងពិគ្រោះយោបល់ជាមួយសហគមន៍ ដែលសេចក្តីសម្រេចបានធ្វើឡើងដោយសម្ងាត់។

2. ក្រុមហ៊ុននេះ បានពង្រាយកម្មករកាប់ឈើប្រណីតមានដូចជាៈក្រញូង បេង នាងនួន ធ្នង់ហើយនាំចេញទៅបរទេសដែលរំលោភទៅលើអនុក្រឹត្យលេខៈ១៣១ ដែលហាម ឃាត់ការនាំចេញឈើប្រណីត។

3. រូបភាពថតដោយក្រុមស៊ើបអង្កេតសំរាប់របាយការណ៍នេះបង្ហាញថា ឈើធ្នង់មានទំហំបន្ទារកំរាស់លើសពី២៥សម ត្រូវបានកាប់ និងនាំចេញ ដែលសកម្មភាពទាំងនេះត្រូវហាមឃាត់ដោយអនុក្រឹត្យលេខៈ១៣១ ។

4. កម្មករ មេការ និងអ្នកកាប់ឈើត្រូវបានពង្រាយឲ្យកាប់ ប្រមូល ដឹកជញ្ជូនឈើប្រណីតនៅក្នុងតំបន់ព្រៃការពារ ដែនជម្រកសត្វព្រៃ និងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋដែលស្ថិតនៅក្រៅពីតំបន់សម្បទានដីសេដ្ឋកិច្ចរំលោភទៅលើច្បាប់ព្រៃឈើឆ្នាំ២០០២ មាត្រា២៨ មាត្រា ២៩ និងមាត្រា៣០។

5. ការកាប់បំផ្លាញព្រៃឈើ ការប្រមូលយកផល អនុផលព្រៃឈើ ហើយនឹងការធ្វើឲ្យ

[25] ច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២ មាត្រា ៣០

[26] ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ មាត្រា ៤២

ខូចបរិស្ថាន បានរំលោភទៅលើច្បាប់ការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ មាត្រា៨។ រដ្ឋាភិបាលបានបញ្ជាឲ្យក្រុមហ៊ុនរក្សាទុកព្រៃឈើ នៅក្នុងតំបន់ការពារ និងធានាការដាំដើមឈើឡើងវិញ វប៉ុន្តែក្រុមហ៊ុននេះមិនបានបំពេញកាតព្វកិច្ចទាំងនេះ វហើយបានផ្លាស់ប្តូរទៅកាប់នៅកន្លែងផ្សេងបន្ទាប់ពីព្រៃឈើត្រូវបានកាប់ឈូសឆាយខ្ទេចខ្ទីអស់។ វនៅឯដេប៉ូស្តុកឈើ វ៉ឺនសៃ និងតាវែង អ្នកស៊ើបអង្កេតបានរកឃើញគំនរឈើអារប្រណីតដ៏ធំមហិមាវវ ត្រូវបានយកចេញពីឧទ្យានជាតិដែលមិនក្រោមគំរោងសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនទ្រីភាពគ្រុបឡើយ។

6. ក្រុមហ៊ុនទ្រីភាពគ្រុបបានរំលោភមាត្រា៨នៃច្បាប់ការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិឆ្នាំ១៩៩៦ ដែលបានចែងថាៈ ព្រៃឈើ និងធនធានធម្មជាតិត្រូវអភិរក្ស អភិវឌ្ឍន៍ គ្រប់គ្រង និងប្រើប្រាស់ឲ្យមានក្ខណៈសមហេតុសមផល ស្ថិតស្ថេរ និងប្រកបដោយនិរន្តរភាព[27]។ មាត្រា២ នៃអនុក្រឹត្យលេខៈ១៣១ ហាមឃាត់ការនាំចេញឈើប្រណីត[28]។ លើសពីនេះមាត្រា៣នៃអនុក្រឹត្យលេខៈ១៣១ចែងថា ឈើជ្រុងមានទទឹង និងកំរាស់លើសពី ២៥សម គឺមិនត្រូវបានអនុញ្ញាតិឲ្យនាំចេញឡើយ[29]។

7. អ្នកស្រាវជ្រាវបានប្រទះឃើញរថយន្តស្ទូច និងរថយន្តដឹកឈើដែលមានស្លាកសញ្ញាសំគាល់ទ្រី ភាពគ្រុប កំពុងដឹកជញ្ជូនឈើប្រណីតចេញពីក្នុងព្រៃ ហើយស្ទូចឈើចេញពីទន្លេ។ អ្នកស្រាវជ្រាវក៏បានសម្ភាសន៍អាជ្ញាធរមូលដ្ឋាន និងកម្មករកាប់ឈើដែលអះអាងថា មេការក្រុមហ៊ុនទ្រី ភាពគ្រុប បានពាក់ព័ន្ធជាមួយនឹងការកាប់ឈើខុសច្បាប់ទាំងនេះ។

ដូច្នេះ វាច្បាស់ណាស់ថា រាល់សកម្មភាពនាំឈើចេញរបស់ក្រុមហ៊ុនទ្រីភាពគ្រុបក្រោមអាជ្ញាប័ណ្ណដឹកជញ្ជូនឈើ ១០០ ០០០ ម³ គឺវាមិនស្របច្បាប់មែនទេដោយយោងទៅលើច្បាប់នៃព្រះរាជាណាចក្រកម្ពុជា?

បទវិភាគផ្នែកច្បាប់អន្តរជាតិបន្ថែមទៀតទាក់ទងនឹងផលប៉ះពាល់នៃការកាប់ឈើទៅលើសហគមន៍ជនជាតិដើមភាគតិចក៏បានបង្ហាញឲ្យឃើញថា សកម្មភាពដែលក្រុមហ៊ុនទ្រីភាពបានប្រព្រឹត្ត គឺរំលោភទៅលើអនុសញ្ញាអន្តរជាតិនានាដែលកម្ពុជាជាប្រទេសហត្ថលេខីមួយដែរ។

---

27 ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឆ្នាំ១៩៩៦ មាត្រា ៨

28 អនុក្រឹត្យស្តីពីផល និងអនុផលព្រៃឈើអនុញ្ញាតអោយនាំចេញ និងនាំចូលលេខ ១៣១ ឆ្នាំ២០០៦ មាត្រា ២

29 អនុក្រឹត្យស្តីពីផល និងអនុផលព្រៃឈើអនុញ្ញាតអោយនាំចេញ និងនាំចូលលេខ ១៣១ ឆ្នាំ២០០៦ មាត្រា ៣

## ១០.៣ តើអាជ្ញាប័ណ្ណចេញដោយរាជរដ្ឋាភិបាលកម្ពុជាជូនដល់ទ្រីភាពគ្រុបអនុញ្ញាតឲ្យទិញឈើកាប់នៅក្នុងខេត្តរតនគីរីស្របច្បាប់នៅក្រោមច្បាប់អន្តរជាតិដែរឬទេ?

មាត្រា២៧នៃកាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ(ដែលកម្ពុជាជាភាគីមួយ ហើយបានបញ្ចូលទៅក្នុងច្បាប់កម្ពុជាក្រោមមាត្រា៣១នៃរដ្ឋធម្មនុញ្ញ) ចែងថាមនុស្សស្ថិតក្នុងចំណោមជនជាតិភាគតិចមិនត្រូវបានបដិសេធសិទ្ធិ ក្នុងការរីករាយជាមួយវប្បធម៌របស់គេបានឡើយ[30]។ អ្វីដែលបានកំណត់ដោយគណៈកម្មាធិការសិទ្ធិមនុស្សថា ដែលមាត្រា២៧បានអនុវត្តន៍ទៅលើជនជាតិដើមភាគតិច[31]។ គណៈកម្មាធិការបានពន្យល់បន្ថែមថាវប្បធម៌បង្ហាញនូវរូបរាងប្លែកៗពីគ្នា ច្រើនបែបយ៉ាងណាស់រួមបញ្ចូលមធ្យោបាយនៃជីវិតដែលមានទំនាក់ទំនងជាមួយនឹងការប្រើប្រាស់ធនធានដីធ្លីជាដើម[32]។ នៅក្នុងករណី អ៊ីលម៉ារី ឡានស្មាន់ អេ អាលវី ហ្វីនលែន ដែលបានកំនត់ក្នុងមាត្រា២៧ គឺការពារជីវភាពរស់នៅរបស់ក្រុមជនជាតិដើមភាគតិចតាមបែបទំនៀមទំលាប់ប្រពៃណី[33]។ លើសពីនេះ ករណីជូរីអ៊ីឡាស្មាន់ អេ អាល់វី ហ្វីនលែន គណៈកម្មាធិការសិទ្ធិមនុស្ស បានថ្លែងថាទោះជាសកម្មភាពកាប់ឈើក្នុងរូបភាពតូចតាចក្តីមិនអាចរាប់ជាការរំលោភមាត្រា២៧ទេ ប៉ុន្តែការកាប់ឈើដែលជាសកម្មភាពមានលក្ខណៈកេងប្រវ័ញ្ច ដូចជាការជីករករ៉ែជាទង្វើ អាចប៉ះពាល់ដល់សិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការរីករាយនូវប្បធម៌របស់ពួកគេ[34]។

លិខិតអនុញ្ញាតលេខៈ១២៧០ កសក អនុញ្ញាតឲ្យប្រមូល និងទិញគ្រប់ដើមឈើផ្តួលរំលំទាំងអស់ពីដីសម្បទានសេដ្ឋកិច្ចក្នុងខេត្តរតគីរី ដែលត្រូវបានផ្តល់ជូនក្រុមហ៊ុនទ្រីភាពគ្រុបដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣។ ទំហំសរុបនៃទឹកដីខេត្តរតនគីរីគឺ ១,០៧៨,២០០ហិកតា ក្នុងនោះ ២៣២,១៦៨ហិកតា គឺស្ថិតនៅក្រោមប្រតិបត្តិការរបស់ក្រុមហ៊ុនចំនួន ដែលទទួលបានការផ្តល់សម្បទានដីសេដ្ឋកិច្ច។ វិសាលភាពចំបងនៃសកម្មភាពកាប់ឈើ ដែលបានកើតឡើងធ្វើឲ្យប៉ះពាល់ប្រយោជន៍ទៅលើសហគមន៍ជនជាតិដើមភាគតិច ដែលពួកគាត់រស់នៅអាស្រ័យទៅលើព្រៃឈើដែលជាប្រភពចំណូលដ៏ចម្បងពិសេសសំរាប់អាហារហូបចុក និងរុក្ខជាតិឱសថជាដើម។

---

[30] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចាប់អនុវត្តពីថ្ងៃទី២៣ ខែមីនា ១៩៧៦ មាត្រា២៧

[31] យោបល់ទូទៅរបស់គណៈកម្មការសិទ្ធិមនុស្ស លេខ២៣(៥០) ផលិតជាថ្មីនៅអង្គការសហប្រជាជាតិHRI/GEN/1/Rev.5.

[32] យោបល់ទូទៅរបស់គណៈកម្មការសិទ្ធិមនុស្ស លេខ២៣(៥០) ផលិតជាថ្មីនៅអង្គការសហប្រជាជាតិHRI/GEN/1/Rev.5.

[33] យោបល់ទូទៅរបស់គណៈកម្មការសិទ្ធិមនុស្ស លេខ២៣(៥០) ផលិតជាថ្មីនៅអង្គការសហប្រជាជាតិHRI/GEN/1/Rev.5.

[34] គណៈកម្មការសិទ្ធិមនុស្ស បានអនុម័តនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៦ Un Doc. A/52/40 ('Jouni E. Länsman et al. v. Finland').

ដោយផ្គត់ផ្គង់អ្នកកាប់ឈើជាមួយនឹងអ្នកទិញឈើ តាមរយៈអាជ្ញាប័ណ្ណទ្រីភាពគ្រុប រដ្ឋាភិបាលកំពុងតែជំរុញឲ្យអ្នកកាប់ឈើឈូសឆាយដើមឈើទាំងអស់នៅក្នុងតំបន់សម្បទាននានា។ អាជ្ញាប័ណ្ណ បានបង្កើននូវតំរូវការឈើ ដូច្នេះវាកំពុងជំរុញដល់អ្នកកាប់ឈើខុសច្បាប់ បូកបញ្ចូល អ្នកភូមិធ្វើការឈូសឆាយដើមឈើនៅក្រៅតំបន់សម្បទានដើម្បីរកផលប្រយោជន៍។ ការផ្តល់ជូនសម្បទានដីសេដ្ឋកិច្ចទ្រង់ទ្រាយធំបែបនេះ និងរួមបញ្ចូលជាមួយនឹងអាជ្ញាប័ណ្ណ ផ្តល់ជូនក្រុមហ៊ុនទ្រីភាពគ្រុប ដែលជំរុញឲ្យមានការប្រមូល និងទិញឈើចំនួនច្រើនដែលជាដើមចមធ្វើសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការអនុវត្តន៍ និងរីករាយជាមួយវប្បធម៌របស់ខ្លួនមានការធ្លាក់ចុះ អាស្រ័យហេតុនេះ វាក៏បានរំលោភច្បាប់អន្តរជាតិមួយផងដែរ។

### ១០.៤ តើរាជរដ្ឋាភិបាលកម្ពុជារំលោភច្បាប់ជាតិ និងអន្តរជាតិ ដោយខកខានមិនបានប្រឹក្សាយោបល់ជាសាធារណៈដោយត្រឹមត្រូវមុនពេលផ្តល់អាជ្ញាប័ណ្ណជូនទ្រី ភាពគ្រុបដែរឬទេ?

គោលការណ៍ទី១០ នៃសេចក្តីប្រកាសនៅរីយ៉ូ ថ្លែងថា ដើម្បីដោះស្រាយបញ្ហាបរិស្ថានឲ្យកាន់តែប្រសើរឡើង ត្រូវមានការចូលរួមពីគ្រប់ប្រជាពលរដ្ឋ ដែលមានការព្រួយបារម្ភនៅកំរិតដែលពាក់ព័ន្ធ ហេតុដូច្នេះរដ្ឋនីមួយៗគួរតែសម្របសម្រួល និងជំរុញឲ្យមានការផ្តល់ចំណេះដឹងជាសាធារណៈ និងការចូលរួមផ្តល់ព័ត៌មានឲ្យបានទូលំទូលាយដែលអាចធ្វើទៅបាន[35]។ គណៈកម្មការ សិទ្ធិមនុស្សបានបញ្ជាក់ថា "រដ្ឋគួរឈានដល់ជំហានចំបាច់ណាមួយដើម្បីធានាសុវត្ថិភាពអ្នកស្រុកជនជាតិដើមឲ្យមានតួនាទីសំខាន់មួយក្នុងសេចក្តីសំរេចចិត្តទៅលើដី ប្រពៃណី និងធនធានធម្មជាតិនានា"[36]។ ម៉្យាងវិញទៀត គណៈកម្មការសិទ្ធិមនុស្សបានយោងយ៉ាងច្បាស់លាស់ទៅមាត្រា១ និង២៧ នៃកាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ដើម្បីធានាថារដ្ឋនីមួយៗបានជំរុញឲ្យមានការប្រឹក្សាយោបល់ ដោយពេញលេញជាមួយជនជាតិដើមភាគតិចរបស់ខ្លួនក្នុងបញ្ហាដែលប៉ះពាល់ជីវភាពប្រពៃណីរបស់ពួកគេ[37]។ គោលការណ៍ច្បាប់អន្តរជាតិទាំងនេះទាក់ទងនឹងការប្រឹក្សាយោបល់ជាមួយសហគមន៍ ក៏បានឆ្លុះបញ្ចាំងច្បាប់នៅកម្ពុជាផងដែរ។ មាត្រា៤នៃច្បាប់ព្រៃឈើចែងថាៈ

ច្បាប់គួរតែត្រូវបានគេអនុវត្តន៍ ដើម្បីធានាឲ្យមានការចូលរួមជាសាធារណៈរាល់សេចក្តីសំរេចចិត្តរបស់រដ្ឋាភិបាល ដែលមានសក្តានុពលប៉ះពាល់ដ៏ធ្ងន់ធ្ងរទៅលើជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និងធនធានព្រៃឈើនានានៅកម្ពុជា[38]។

[35] សេចក្តីប្រកាសរីយ៉ូរបស់អង្គការសហប្រជាជាតិអំពីបរិស្ថាន និងការអភិវឌ្ឍន៍ ១៩៩២ គោលការណ៍១០

[36] សេចក្តីសន្និដ្ឋាននៃការសង្កេតការណ៍ទៅលើបញ្ហាអូស្រ្តាលីឯកសារអង្គការសហប្រជាជាតិ UN doc. CCPR/CO/69/AUS (2000).

[37] សេចក្តីសន្និដ្ឋានរបស់គណៈកម្មការសិទ្ធិមនុស្សទៅលើបញ្ហាណរវ៉េសលេខៈ CCPR/C/79/Add.112 (1999).

[38] ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ មាត្រា ៤

អាជ្ញាប័ណ្ណ និងឯកសារអនុញ្ញាតនានាដែលត្រូវបានផ្តល់ជូនក្រុមហ៊ុនទ្រី ភាពគ្រុប អនុញ្ញាតឲ្យប្រមូលទិញ និងនាំចេញឈើពីសម្បទានដីសេដ្ឋកិច្ចនៅក្នុងខេត្តរតនគីរី មិនត្រូវបានឆ្លងកាត់ស្ថាប័ននីតិបញ្ញត្តិ។ ផ្ទុយទៅវិញការសំរេចផ្តល់អាជ្ញាប័ណ្ណ ត្រូវបានធ្វើដោយសំងាត់ ដោយមិនមានការដេញថ្លៃជាសាធារណៈ ឬក៏មិនមានការប្រឹក្សាយោបល់ជាមួយសហគមន៍ទាល់តែសោះ។ ដូចដែលបានពិភាក្សាពីមុនមក ឥទ្ធិពលអាជ្ញាប័ណ្ណរបស់ទ្រីភាពគ្រុបបានធ្វើឲ្យអន្តរាយដល់ព្រៃឈើ ក៏ដូចជាដល់ជីវភាពរស់នៅរបស់សហគមន៍ដែលពឹងផ្អែកលើព្រៃឈើផងដែរ។ ដោយសារតែ សេចក្តីសំរេចផ្តល់អាជ្ញាប័ណ្ណបានធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់ធនធានធម្មជាតិ និងជីវភាពរស់នៅ ដូច្នេះរដ្ឋាភិបាលកម្ពុជាគួរតែផ្សព្វផ្សាយព័ត៌មានដល់សាធារណៈ និងធានាថាសហគមន៍រងគ្រោះ បានចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្តនេះផងដែរ។ កន្លងមករដ្ឋាភិបាលមិនបានអនុវត្ត តាមនិតិវិធីទាំងនេះទេ ដូច្នេះរដ្ឋាភិបាលបានរំលោភច្បាប់ក្នុងស្រុកនិងច្បាប់អន្តរជាតិផងដែរ។

## ១១.ពាក្យបច្ចេកទេសពន្យល់អំពីឈើប្រណីត

ឈើប្រណីតកំពុងតម្រូវការ

- បេង
- ក្រញូង
- នាននួន
- ធ្នង់
- សុក្រម
- ថ្នឹក

ធ្នង់មាន៤ប្រភេទៈ

- ធ្នង់ផ្កា
- ធ្នង់បារ៉ា
- ធ្នង់កប្រ
- ធ្នង់ធម្មតា

ខ្នាតរង្វាស់ៈ មួយម៉ែត្រគូបស្មើនឹង១,៣៥០គីឡូក្រាម មួយកុងតឺន័រគឺប្រហែល៣០តោន

<u>តម្លៃឈើប្រណីត</u>៖ ឈើមានតម្លៃខុសៗគ្នាតាមប្រភេទ តាមទំហំ តាមខ្នាត និងតាមរូបរាងរបស់វាផងដែរ។ តម្លៃក៏អាចប្រែប្រួលទៅតាមទីផ្សារ និងតម្រូវការទាំងក្នុងនិងក្រៅប្រទេស។ ដោយសារតែឈើពិបាកក្នុងការប្រមូល ពិបាកក្នុងការដឹកជញ្ជូន និងត្រូវប្រឈមមុខនឹងច្បាប់ទើបតម្លៃរបស់វាមានការឡើងចុះ។ ឧទាហរណ៍ ដើមធ្នង់ឈរមួយដើមមានអង្កត់ផ្ចិតធំជាង៥០សម ឬ៦០សម មានតម្លៃត្រឹមតែ២០០ទៅ២៥០ដុល្លារប៉ុណ្ណោះនៅក្នុងព្រៃ។ ប៉ុន្តែនៅពេលវាត្រូវបានគេកែច្នៃធ្វើជាឈើសន្លឹក ឈើឃ្លុំ កាត់តាមខ្នាតតម្រូវការ នោះវានឹងមានតម្លៃជាង៥០០ដុល្លារសំរាប់ទីផ្សារនៅតាមស្រុក ៨០០ដុល្លារនៅទីផ្សារក្នុងខេត្ត និងអាចឡើងដល់១៥០០ដុល្លារនៅតាមព្រំដែន។ ដឹកហ៊ុបទាំងមូលទៅដល់ព្រំដែនឡាវឈើនោះនឹងមានតម្លៃរហូតដល់២០០០ដុល្លារក្នុងមួយម៉ែត្រគូប (សូមមើលឧបសម្ព័ន្ធ១)។ ឈើធ្នង់មុខ ៣០សម ឬ ៤០សម ប្រសិនដឹកដល់ព្រំដែនឡាវ តម្លៃវានឹងស្មើនឹងតម្លៃឈើដែលមានមុខកាត់១០០សម។ នេះជាតម្លៃសមរម្យសំរាប់ទីផ្សារវៀតណាម និងទីផ្សារក្នុងស្រុក។ សំរាប់ឈើល្អដែលមានមុខកាត់ធំចាប់ពី៨០សម ឬ១០០សមឡើងទៅ គេមិនលក់ជាគូបនោះទេ គេអាចច្នៃលក់ជាដើមហ៊ុបទាំងមូលបើអាចដឹកទៅបាន ឬអាចច្នៃច្រៀកជាង្បើ មានតម្លៃខ្ពស់ជាងឈើឃ្លុំដែលគិតជាគូប។ ឈើក្ដារង្បើអាចច្រៀកច្នៃជាទម្រង់ឈើមូល ដែលល្អជាងឈើឃ្លុំតម្លៃនៅទីផ្សារចំហរអាចច្រើនជាងទ្វេរដងនៃតម្លៃនៅក្នុងក្រុមហ៊ុនទ្រីភាពគ្រុប ប៉ុន្តែថៅកែឈើបានជ្រើសរើសរកស៊ីជាមួយក្រុមហ៊ុនទ្រីភាពដោយសារគេស្គាល់គ្នា ហើយមិនត្រូវបានចាប់ខ្លួនអ្វីនោះទេ។



*រូបភាព៧៥ :ឧទាហរណ៍មួយនៃឈើគ្រញូង*

ឈើឈរទាំងមូល៖ តម្លៃឈើឈរ អាស្រ័យលើទំហំរបស់វា

- ៣០-៤០សម តម្លៃ $២០០
- ៥០-៦០សម តម្លៃ $៣០០
- ៧០-៨០សម តម្លៃ $៣៥០ ទៅ $៤០០
- ៩០-១០០សម តម្លៃ $៥០០
- ១០០-២០០សម តម្លៃ $២,០០០
- ២០០-៣០០សម តម្លៃ $៣,០០០ រហូតដល់ $៥,០០០

ជនជាតិដើមភាគតិចម្នាក់ដែលចាត់ទុកថាខ្លួនឯងជាម្ចាស់ឈើ បានរកឃើញឈើនៅក្នុងចម្ការនៅលើភ្នំបានបាញ់ថ្នាំចំណាំឈ្មោះនៅជាប់នឹងដើមឈើថាជារបស់ខ្លួន បន្ទាប់មកគាត់បានលក់ដើមឈើនោះឲ្យឈ្មួញជាបន្តទៀត។

ឈើសន្លឹកធម្មតា៖ ទាំងនេះជាឈើសន្លឹកដែលបានច្រៀកទំហំ ១០/១៥សម x ៤០សម x ១២០សម មានតម្លៃ៥០ដុល្លារសំរាប់ឈើធ្នង់ និងតម្លៃរហូតដល់រាប់ពាន់ដុល្លារសំរាប់ឈើក្រញូងឬបេង។ ឈើសន្លឹកក្រាស់ គឺមិនអនុញ្ញាតឲ្យដឹកជញ្ជូនក្នុងស្រុកបានទេ ដូច្នេះឈើសន្លឹកស្តើងៗ ភាគច្រើនត្រូវបានគេដឹកជាលក្ខណៈឯកជនទៅឲ្យឈ្មួញក្នុងស្រុក ឬនាំចេញទៅវៀតណាមនិងឡាវ។

ឈើសន្លឹកឡូតប៉ាត់ (Lort Pat)៖ ជាឈើខ្លឹមសុទ្ធ សាច់ស្អាតរលោង គ្មានស្នាមប្រេះស្រាំ គ្មានប្រហោង មានទំហំមុខកាត់ ១០/១៥សម x៤០សម x១២០សម តម្លៃចន្លោះពី៤០០,០០ទៅ៥០០,០០ ដុល្លា។

ធ្នឿធម្មតា ឈើសន្លឹកឡូតប៉ាត់ (Lort Pat)៖ មានមុខកាត់ធំ និងវែង ជាឈើខ្លឹមសុទ្ធ សាច់ស្អាតរលោង គ្មានស្នាមប្រេះស្រាំ គ្មានប្រហោង មានទំហំមុខកាត់១៥សម x ៨០សម x ២៥០សម

- ធ្នឿធ្នង់: តម្លៃ១២៥ដុល្លារ ១សន្លឹក
- ធ្នឿធ្នង់ឡូតប៉ាត់: តម្លៃ៥០០ដុល្លារ ១សន្លឹក
- ធ្នឿបេង និងក្រញូង: តម្លៃ២០០០០ដុល្លារ ១សន្លឹក

(កុសង្រក្នុរៀងទីម្លតែ)

- ធ្នឿធ្នង់ដែលមានកំរាស់២០សម ទទឹង ៨០សម បណ្តោយ២៥០សម មានតម្លៃទ្វេរដង។ ចំពោះឈើមួយសន្លឹកដែលមានមានទទឹង៨០សម ទៅ១០០សម និងបណ្តោយ៣៥០សម តម្លៃចាប់ពី២០០០០ ទៅ៥០០០០ដុល្លារ។
- ធ្នឿបេង ឬក្រញូង ទំហំ១០សម x ៨០សម x ២៥០សម តម្លៃចាប់ពី៣០០០០ ទៅ១លាន ដុល្លារ នៅប្រទេសចិន (ពត៌មានស្តីពីរបាយការណ៍ទីផ្សារនៅប្រទេសចិន នេះបើយោងតាមទីភ្នាក់ងារស៊ើបអង្កេតបរិស្ថាន)។




*រូបភាព៧៦-៧៧៖ ឧទាហរណ៍នៃឈើឡតប៉ាត់ មុខរលោង ស្អាត*

<u>ឈើឃ្លុំ៖</u> ជាឈើអារបួនជ្រុងទ្រវែងរឹង។ ចំពោះឈើឃ្លុំ មួយដុំមានប្រវែង៣០សម x ២២០សម តម្លៃនៅក្នុងព្រៃគឺចន្លោះ២០០ ទៅ ២៥០ដុល្លារក្នុង១គូប   តម្លៃនៅតាមភូមិ៣០០ទៅ៣៥០ ដុល្លារ និង តម្លៃនៅមាត់ទន្លេគឺ៥០០ ទៅ ៧០០ដុល្លារ។  ចំណែកតម្លៃនៅទីរួមខេត្តពី៧០០ ទៅ៨០០ដុល្លារ  រហូត ដល់១០០០ទៅ១២០០ដុល្លារ    និងតម្លៃនៅព្រំដែនកុងត្រូលចាប់ពី ២០០០ ទៅ ៣០០០ដុល្លារ។ ឈើឃ្លុំមានតម្លៃទ្វេរដងនៅប្រទេសចិន ថ្លៃជាងនៅវៀតណាម និងឡាវ។

<u>ឈើហ៊ុបទាំងមូល</u>:  ឈើដែលកាប់ទាំងមូល ត្រូវបានគេប្រើសម្រាប់ការតុបតែងជាច្រើនប្រភេទ ដូចជាគ្រឿងសង្ហារឹមធ្វើជាសសរផ្ទះវីឡា និងសណ្ឋាគារ។ វាមានតម្លៃថ្លៃខ្លាំងណាស់ឈើមួយ កង់ទំហំ១០០សម x ៤០០សម   មានតម្លៃចន្លោះពី ១០០០០ ទៅ ៥០០០០ដុល្លារ។ ឈើ ប្រភេទនេះត្រូវបានច្បាប់ហាមឃាត់ចំពោះការនាំចេញ។ នៅច្រកព្រំដែនប្រទេសឡាវ ថៅកែ ឡាវបានឲ្យតម្លៃឈើមូលនៅទំហំ ៣០សម x ៤០០សម    ដូចអត្រាតម្លៃឈើដែលមានទំហំ ១០០សម x ៤០០សម ។

__អារលំឈើ__: កម្មករម្នាក់ និងជំនួយការម្នាក់សំរាប់កាប់ឈើក្នុងមួយម៉ែត្រគូបទទួលបាន៨ទៅ ១០ដុល្លាដោយក្នុងនោះរណាយន្តនិងប្រេងសាំងត្រូវបានផ្គត់ផ្គង់ដោយក្រុមហ៊ុន។ ប្រសិនបើពួកគេប្រើឧបករណ៍ និងប្រេងផ្ទាល់ខ្លួន នោះតម្លៃឈ្នួលគឺ ១៥ ទៅ ២០ដុល្លារក្នុងមួយម៉ែត្រគូប។ ជំនួយការម្នាក់អាចរកចំណូលបានចន្លោះពី ២០ ទៅ ២៥ដុល្លារក្នុងមួយថ្ងៃ។ អ្នកកាប់ឈើវិញគឺទទួលបានប្រាក់ពីថៅកែជារៀងរាល់ខែ។




*រូបភាព៧៨៖ ឈើឃ្លុំដែលមានអង្កត់ផ្ចិត៤០សម នៅក្នុងដេប៉ូក្រុមហ៊ុនទ្រីភាព នៅភូមិតាខែង ឃុំគោកឡាក់ ស្រុកសៀមប៉ាង (X:៦៣១៧៦៨ , Y: ១៥៤៩៩៧០*



*រូបភាព ៧៩: ឈើអារនៅមិនអនុញ្ញាតឲ្យនាំចេញ*

<u>អ្នកផៃឈើ</u>: ច្រៀកតាមទម្រង់ឈើ កាត់សំបកចេញតាមទម្រង់ដែលអ្នកទិញចង់បាន។ ការងារអ្នកផៃឈើ គឺមានលក្ខណៈបច្ចេកទេសនិងពិសេសជាងការងារអ្នកអារឈើ។ អ្នកផៃឈើមានព្រូ(ជំនួយការ)ម្នាក់ហើយទទួលបានប្រាក់ដូចអ្នកអារឈើរំលំឈើដែរ។

<u>ព្រូរណោ</u>: ព្រូរណោជួយរៀបចំសំភារៈដល់អ្នកអារឈើ ដូចជារណា ប្រេង និងមើលថែទាំសំភារៈដូចជាសំលៀងច្រវាក់។ ព្រូរណោអាចរកកំរៃបានពី២០ទៅ២៥ដុល្លារក្នុងមួយថ្ងៃពីថៅកែឈើ។



*រូបភាព ៨០:អ្នកផៃឈើកាត់ និងផៃឈើផ្ទង់នៅភ្នំស្រមរ តំបន់ (X: 676831, Y: 1562730).*

<u>ការដឹកឈើប្រណីតចេញពីព្រៃ</u>: ការដឹកជញ្ជូនឈើដែលមានបរិមាណច្រើន ទាមទារឲ្យមានរថយន្តដឹកទំនិញប្រភេទធំៗ។ ក្រុមហ៊ុនបានប្រើរថយន្តម៉ាករ៉េវដែលអាចផ្ទុកឈើបានច្រើនដល់ទៅ១៥ម៉ែត្រគូបឬ១០ម៉ែត្រគូបសំរាប់រថយន្តម៉ាកដំរីទឹក។ ជាទូទៅអ្នកបើកឡានទទួលបានប្រាក់ខែពី១០០ ទៅ ២០០ដុល្លារ និងផលប្រយោជន៍ផ្សេងៗទៀតពីថៅកែឈើ។ ក្នុងកំឡុងពេលដឹកជញ្ជូន៉កម្រៃសេវា៉ត្រូវបានបង់សំរាប់បើកផ្លូវ។ នៅក្នុងព្រៃ អ្នកបើកឡានត្រូវបង់២៥ដុល្លា ទៅអាជ្ញាធរ មូលដ្ឋាន សហគមន៍ និងសមាជិកអ្នកសារពត៌មានដែលចាំកាក់លុយនៅតាមផ្លូវ។ ថៅកែបានផ្ញើប្រាក់ជាមុនដើម្បីរត់ការផ្លូវ បើពុំនោះទេរថយន្តដឹកឈើមិនឲ្យឆ្លងកាត់បានឡើយ។

<u>ឈើកែច្នៃ</u>: ឈើកែច្នៃត្រូវបាននាំចេញសម្រាប់ការប្រើប្រាស់គ្រប់ប្រភេទដូចជាគ្រឿងសង្ហារឹមទូតាំង ផលិតផលចម្លាក់ធ្វើពីឈើ ប្រដាប់ក្មេងលេងធ្វើពីឈើ របស់របរសំរាប់តុបតែងលំអរនិងវត្ថុអនុស្សាវរីយ៍ផ្សេងៗ។ សម្ភារៈប្រើប្រាស់ផ្សេងទៀតរួមមាន សម្ភារៈការិយាល័យដែលធ្វើពីឈើ ផលិតផលមិនមែនជាឈើកុងផ្លាកេ ពិដាន កំរាល ឡាំង និងសាឡុងផ្សំឬមិនផ្សំពីឈើ ឈើចំហុយចាក់ពុម្ព គ្រោងទ្វារ គ្រោងបង្អួចឈើ និងដងសំភារៈដែលធ្វើអំពីឈើ។ល។

<u>ម្ចាស់ដើមឈើ៖</u> សហគមន៍ដែលរស់នៅក្នុងព្រៃដូចជាជនជាតិដើមភាគតិចព្រៅ ការ៉េត និងគ្រឹង សុទ្ធសឹងជាអ្នកការពារ និងអភិរក្សព្រៃឈើជាច្រើនឆ្នាំណាស់មកហើយ។ ពួកគេបានចាត់ទុកខ្លួនឯងថាជាម្ចាស់នៃដើមជ័រ តួយ៉ាងពួកគេបានធ្វើការប្រមូលជ័រជាប្រចាំ។ ថ្មីៗនេះជនជាតិខ្មែរឥស្លាម បានមកដល់ ហើយបានប្រកាសខ្លួនគេថាជាម្ចាស់ដើមឈើប្រណិត និងបានបាញ់កូដ លាបពណ៌លើដើមឈើ ដើម្បីកំណត់អត្តសញ្ញាណនៃភាពជាម្ចាស់/កម្មសិទ្ធិរបស់ពួកគេ។ ថៅកែឈើបានទិញដើមឈើឈរពី "ម្ចាស់" ទាំងនេះ។

<u>ព្រៃបំរុងទុកអចិន្ត្រៃយរបស់រដ្ឋ:</u> ក្រោមការគ្រប់គ្រងរបស់រដ្ឋាបាលព្រៃឈើ ព្រៃឈើទាំងនេះមិនត្រូវបានអនុញ្ញាតឲ្យកាប់ដឹកជញ្ជូន ឬនាំចេញឡើយ លុះត្រាតែមានការអនុញ្ញាតពីរដ្ឋាភិបាល បន្ទាប់ពីមានសំណើពិសេសមួយពីរដ្ឋបាលព្រៃឈើ។

<u>ឧទ្យានជាតិ៖</u> ត្រូវបានការពារដោយក្រសួងបរិស្ថាន មន្ទីរបរិស្ថានថ្នាក់ខេត្ត និងសហគមន៍។ ការចូលទៅក្នុងតំបន់បរិស្ថានដោយមិនមានការអនុញ្ញាតគឺត្រូវហាមឃាត់យ៉ាងតឹងរ៉ឹង។ មន្ត្រីបរិស្ថានយាមប្រចាំការឧទ្យានជាតិដើម្បីទប់ស្កាត់ការកាប់ឈើ តែទោះជាយ៉ាងណាក៏ ក្រុមហ៊ុនទ្រីភាពគ្រុប បានប្រតិបត្តិការកាប់ឈើនៅក្នុងឧទ្យានជាតិនានា។ រាល់ការធ្វើដំណើរចូលទៅក្នុងឧទ្យាន ត្រូវមានការអនុញ្ញាតពីអ្នកគ្រប់គ្រងឧទ្យាន ហើយត្រូវអមដំណើរដោយអ្នកនាំផ្លូវម្នាក់។ ប៉ុន្តែក្រុមហ៊ុនជាច្រើនកំពុងតែកាប់ឈើនៅក្នុងឧទ្យានជាតិ ហើយដើមឈើត្រូវបានគេបាញ់ថ្នាំសំគាល់លេខកូដ សំរាប់ទុកលក់។

<u>អ្នករត់ការផ្លូវ៖</u> អ្នករត់ការផ្លូវត្រូវទៅមុនរថយន្តដឹកឈើ ដើម្បីបង់ប្រាក់ដល់ប៉ូលីស ប៉េអឹម អ្នកសារព័ត៌មាន មន្ត្រីបរិស្ថាន មន្ត្រីរុក្ខាប្រមាញ់ មន្ត្រីអភិរក្ស មេភូមិ មេឃុំ សន្តិសុខ និងសមាជិកសហគមន៍ដើម្បីធានា ថារថយន្តដឹកឈើត្រូវបានគេអនុញ្ញាតឲ្យឆ្លងកាត់។ ការបង់ប្រាក់នេះជាទូទៅមានតម្លៃ២៥ដុល្លារក្នុងមួយរថយន្ត។ ក្នុងមួយជើងៗការបង់ប្រាក់ប្រមាណ ២៥០ដុល្លារ។ ក្រុមហ៊ុនបាននិយាយថា នឹងបង់ប្រាក់ថ្លៃជួសជុល និងថែទាំផ្លូវសំរាប់សហគមន៍ ជាជាងការបង់ "កំរៃសេវា" មិនផ្លូវការ ប៉ុន្តែវាមិនដែលកើតឡើងឡើយ។

<u>ការដឹកជញ្ជូនប្រឈមនឹងហានិភ័យ/លោតឆ័ត្រ៖</u> ការដឹកជញ្ជូនឈើប្រណិតដោយគ្មានច្បាប់អនុញ្ញាតត្រឹមត្រូវ ដូចជាគ្មានលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ(PC/B) ឬលិខិតអនុញ្ញាតផ្តល់អាជ្ញាប័ណ្ណ(PL/B)ពីរដ្ឋបាលព្រៃឈើ។ ឈើត្រូវតែដឹកចូលទៅដេប៉ូទ្រីភាពព្រោះក្រុមហ៊ុននេះមានអាជ្ញាប័ណ្ណផ្តាច់មុខពីរដ្ឋាភិបាល។ មិនមានការចាប់ខ្លួនទេ ប្រសិនបើឈើត្រូវបានដឹកទៅកាន់ដេប៉ូទ្រីភាព។ អ្នករកស៊ីឈើខ្លះបានដឹកហួសក្រុមហ៊ុននេះ ដោយសារគេអាចលក់បានតម្លៃខ្ពស់ជាងទៅឲ្យម៉ូយនៅតាមព្រំដែនវៀតណាម ឬឡាវ។ ការដឹកជញ្ជូនលោតឆ័ត្រគឺបានកំរៃច្រើនជាងការដឹកទៅលក់ឲ្យដេប៉ូទ្រីភាព ប៉ុន្តែតម្រូវឲ្យមានការប្រាស្រ័យទាក់ទងជាមួយអាជ្ញាធរនៅតាមដងផ្លូវ ដោយបង់ប្រាក់ជាមុនសិន មុននឹងអនុញ្ញាតឲ្យដឹកជញ្ជូនឆ្លងកាត់បាន។

<u>ថៅកែឈើៈ</u> អ្នកទាំងនោះគឺទទួលបន្ទុកទិញឈើឲ្យមេការ ពួកគេចែករំលែកផលប្រយោជន៍ជាមួយមេការ។ ថៅកែឈើជាទូទៅជាទាហាន ប៉ូលីស ប៉េអឹម ឬឈ្មួញឈើ។ ដើម្បីក្លាយជាថៅកែឈើបានត្រូវមានរថយន្ត កម្មករ សំភារៈផ្សេងៗទៀត ឃ្លាំងស្តុកឈើ និងប្រាក់គ្រប់គ្រាន់ដើម្បីទូទាត់នៅដៃប៉ូធំៗ។

<u>មេការក្រុមហ៊ុនៈ</u> មនុស្សនេះជាទូទៅចាត់ចែងគ្រប់ការងារក្រុមហ៊ុន។ មេការតែងតាំង/រើសដង្ហៅ ដើម្បីចុះប្រមូលឈើ និងត្រួសត្រាយផ្លូវចូលក្នុងព្រៃ។ មេការមើលការខុសត្រូវក្នុងតំបន់របស់ខ្លួន ហើយមិនត្រូវរាតត្បាតចូលក្នុងតំបន់មេការដ៏ទៃទៀតឡើយ។ រថយន្តដឹកឈើមិនអាចជាន់គ្នានៅលើផ្លូវដែលត្រួសត្រាយដោយមេការផ្សេងបានឡើយ។ មេការយកប្រាក់ពីនាយកក្រុមហ៊ុនដើម្បីទិញឈើពីថៅកែឈើ ហើយដឹកជញ្ជូនវាដោយផ្ទាល់ទៅក្រុមហ៊ុន។ មេការទទួលខុសត្រូវលើអ្វីៗទាំងអស់ដែលបានកើតឡើងនៅតាមផ្លូវ ដូចជាការបញ្ចុះបញ្ចូលសហគមន៍មូលដ្ឋានដើម្បីសុំការអនុញ្ញាតចូលកាប់ឈើនៅក្នុងតំបន់ការពារជាដើម។ មេការភាគច្រើន គឺជា ប៉ូលីស ប៉េអឹមទាហាន ឬ ជាមន្ត្រីជាន់ខ្ពស់។

<u>ការដឹកជញ្ជូនតាមទូកៈ</u> ក្រុមនេះមិនមែនធ្វើការឲ្យក្រុមហ៊ុននោះទេ ប៉ុន្តែធ្វើការដោយឯករាជ្យ។ ពួកគេជាក្រុមចល័តដែលដឹកឈើតាមទូក មានទំហំរហូតដល់៥ម៉ែត្រគូបក្នុងមួយជើង ដែលសោហ៊ុយដឹក គឺ២៥ដុល្លារក្នុងមួយម៉ែត្រគូប។ ទូកមួយអាចដឹកបានរហូតដល់ទៅ៥ជើងក្នុងមួយថ្ងៃ។ ពួកគេដឹកពីត្រើយម្ខាងនៃទន្លេសេសាន្ត ទន្លេសេកុងឬទន្លេមេគង្គទៅត្រើយម្ខាងទៀតដែលរថយន្ត ស្វូច និងគ្រឿងយន្តរបស់ក្រុមហ៊ុនទ្រីភាពបានចតចាំនៅទីនោះ។ កម្មករទូកម្នាក់អាចរកកំរៃបានរហូតដល់១០០ដុល្លារក្នុងមួយថ្ងៃ។




*រូបភាព ៨១: ការដឹកជញ្ជូនតាមទូកឆ្លងកាត់ទន្លេសេសាន*

<u>ជំរុំកាប់ឈើ និងកន្លែងស្តុកឈើៈ</u> ជាជម្រកកណ្តាលសំរាប់អ្នកកាប់ឈើនៅក្នុងព្រៃ ដែលមានអាហារ និងសំភារៈផ្សេងៗ។ ជាទូទៅជំរុំកាប់ឈើមានទីតាំងនៅក្បែរស្ទឹង។ រាល់ឈើអារ

ប្រណីតត្រូវបានយកទៅគរទុកនៅកន្លែងស្តុកឈើ រង់ចាំអ្នកបើកឡានមកប្រមូលយកទៅកាន់ដេប៉ូ។ កងកំលាំងប្រដាប់អាវុធត្រូវបានដាក់ពង្រាយឲ្យការពារជំរុំកាប់ឈើ។



*រូបភាព៨២: ជំរុំកាប់ឈើរកឃើញនៅក្នុងភ្នំក្រាយ ឧទ្យានជាតិវីរៈជ័យ*



*រូបភាព៨៣: ដេប៉ូថៅកែឈើ ស្តុកឈើអារកូដ KC នៅតាមមាត់ទន្លេសាសាន វឺនសៃ*



*រូបភាព៨៤: ដេប៉ូថ្លឹងឈើ នៅភូមិហ្វាំង ឃុំប៉ុង ស្រុកវឺនសៃ*

<u>ដេប៉ូឈើរបស់ថៅកែ:</u> ជាកន្លែងមួយសំរាប់ស្តុកឈើបណ្តោះអាសន្ន ពេលខ្លះថៅកែជួលដីពីអ្នកភូមិក្នុងមួយខែ១០០ដុល្លារ ដើម្បីគរឈើ។ ដេប៉ូនេះបានរើទៅកន្លែងថ្មីនៅពេលព្រៃឈើត្រូវបានគេកាប់អស់និងផ្លាស់ប្តូរទីតំបន់ផ្សេង។

<u>ដេប៉ូថ្នាក់ស្រុក:</u> ជាកន្លែងសម្រាប់ស្តុកឈើប្រមូលដោយមេការពីគ្រប់តំបន់ដែលនៅជិតដេប៉ូ។ ដេ ប៉ូទាំងនេះគឺមានរយៈពេលវែង ហើយអាចត្រូវបានគេរកឃើញនៅពីក្រោយការិយាល័យរដ្ឋបាលព្រៃឈើ។ វាត្រូវបានគេធ្វើជារបងរុំព័ទ្ធ និងមានការយាមកាមយ៉ាងតឹងរ៉ឹងដោយកងកំលាំងប្រដាប់អាវុធ ដូចជាទាហាន និងប៉េអឹម ជាដើម។

<u>ដេប៉ូឈើខេត្ត</u>៖ ជាកន្លែងសំរាប់សម្រាំងប្រភេទ និងគុណភាពឈើ ថ្លឹងទម្ងន់ឈើម្តងទៀតហើយគណនាចំនួនឈើ ដែលបានបញ្ជូនមកពីមេការនីមួយៗតាមដេប៉ូស្រុក។ ឈើត្រូវបានគេដឹកចេញពីនេះយកទៅកាន់ដេប៉ូកុងតឺន័រ។ នាយកតាមខេត្តត្រូវផ្តល់ប្រាក់ទៅមេការស្រុក ដើម្បីទិញឈើ។

<u>ដេប៉ូថ្លឹងឈើ</u>៖ ជាកន្លែងថ្លឹងឈើ និងវាស់វែងឈើ ព្រមទាំងទូទាត់ការចំណាយផ្សេងៗ។

<u>ដេប៉ូកុងតឺន័រ</u>៖ ទីនេះជាកន្លែងបញ្ជាទិញ និងបំពេញបែបបទផ្សេងៗ ព្រមទាំងជាកន្លែងធ្វើការទូទាត់លុយកាក់ជាមួយអ្នកទិញ។ ជាទូទៅដេប៉ូនេះនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ហើយត្រូវបានយាមកាមយ៉ាងតឹងរ៉ឹង។ ក្រុមហ៊ុននាំឈើចេញត្រូវតែសុំអាជ្ញាប័ណ្ណពីដេប៉ូទាំងនេះ។ គយ និងកាំកុងត្រូលក៏បានឈរជើងនៅក្នុងដេប៉ូនេះផងដែរ។

<u>ដេប៉ូឈើក្រុមហ៊ុនទ្រីភាពគ្រុប</u>៖ ជាកន្លែងដេប៉ូឈើដ៏ធំមហិមាមួយនៅតាមផ្លូវលេខ៥១ ស្ថិតក្នុងឃុំភ្នំតូច ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ។ គ្រប់ប្រភេទឈើប្រណីតមកពីទូទាំងប្រទេសត្រូវបាននាំ



*រូបភាព៨៥: ដេប៉ូធំរបស់ទ្រី ភាពនៅឧត្តុង្គ កំពង់ស្ពឺ*

មកកាន់ដេប៉ូនេះ។ ឈើប្រណីតត្រូវបានបែងចែកតាមប្រភេទ ហើយដាក់ក្នុងកុងតឺន័រ បន្ទាប់មកវាយត្រា និងបិទតែមដោយគយ។ ដេប៉ូនេះគ្របដណ្តប់លើផ្ទៃដីជាង១០០០ហិកតា និងមានកំលាំងទាហានយាមប្រចាំការយ៉ាងតឹងរឹង។ បន្ទាយទាហាននៅជុំវិញភ្នំ ហើយអ្នកភូមិត្រូវបានហាមឃាត់មិនឲ្យចូលឡើយ។ រាល់ឈើទាំងអស់នៅក្នុងដេប៉ូនេះ ត្រូវតែមានអាជ្ញាប័ណ្ណនាំចេញពីក្រុមហ៊ុនទ្រីភាពគ្រុប បើមិនដូច្នោះទេឈើទាំងនោះត្រូវបានចាត់ថាជាការនាំចេញដោយខុសច្បាប់។

**លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ(PC/B)**៖ លិខិតអនុញ្ញាតដឹកជញ្ជូនឈើ និងឈើកែច្នៃ ត្រូវបានចេញដោយរដ្ឋបាលព្រៃឈើសំរាប់ការដឹកជញ្ជូនក្នុងស្រុក។ លិខិតភ្ជាប់ខាងក្រោម(មើលតារាង៩៨) បង្ហាញថាចំនួនទឹកប្រាក់ត្រូវបានបង់ទៅធនាគារជាតិ ប៉ុន្តែមិនបញ្ជាក់ពីប្រភេទឬទំហំឈើប្រណីតនោះទេ។


010149 /PC/B

010150 /PC/B

*រូបភាព៨៦: ឧទាហរណ៍នៃ PC/B សំរាប់ការដឹកជញ្ជូនឈើអនុញ្ញាតដោយរដ្ឋបាលព្រៃឈើ*

**លិខិតអនុញ្ញាតផ្តល់អាជ្ញាប័ណ្ណ (LP/B)៖** លិខិតអនុញ្ញាតថ្នាក់ជាតិចុះហត្ថលេខាដោយប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុករដ្ឋបាលព្រៃឈើ ហើយបានផ្តល់ជូនក្រុមហ៊ុនឬបុគ្គលសំរាប់ការដឹកជញ្ជូនឈើឆ្លងកាត់គ្រប់តំបន់ទាំងអស់។

**លិខិតអនុញ្ញាតសំរាប់នាំឈើចេញ៖** លិខិតអនុញ្ញាតបានចុះហត្ថលេខាដោយទីស្តីការគណៈរដ្ឋមន្ត្រី ដោយអនុម័តតាមសំណើរបស់ក្រុមហ៊ុនទ្រីភាពគ្រុប តាមរយៈរដ្ឋមន្ត្រីក្រសួងបរិស្ថានដើម្បីនាំឈើកែច្នៃចំនួន១០០,០០០ ម៉ែត្រគូប ចេញពីកម្ពុជា តាមច្រកព្រំដែនអន្តរជាតិអូរយ៉ាដាវ ខេត្តរតនគិរី និងតាមច្រកវាលី ខេត្តក្រចេះ ព្រមទាំងតាមច្រកកំពង់ផែអន្តរជាតិ។ អាជ្ញាប័ណ្ណនេះមិនបានបញ្ជាក់ប្រភេទឈើ និងទំហំឈើសំរាប់ការនាំចេញនោះទេ (មើលឧបសម្ព័ន្ធ ១១ និង១៣)។

អាជ្ញាប័ណ្ណនាំទំនិញចេញទៅបរទេស៖ លិខិតអនុញ្ញាត ដែលបានចុះហត្ថលេខារួមគ្នាដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាមួយនឹងប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុករដ្ឋបាលព្រៃឈើដែលអនុញ្ញាតឲ្យក្រុមហ៊ុនទ្រីភាពគ្រុបធ្វើការនាំឈើចេញទៅបរទេស(មើលតារាង១០០)។



*រូបភាព៨៧: ឧទាហរណ៍នៃ LP/B អនុញ្ញាតឲ្យដឹកជញ្ជូនឆ្លងប្រទេស*



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលព្រៃឈើ

005081/ PC/B

លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើ

*រូបភាព ៤៨:អាជ្ញាប័ណ្ណដឹកជញ្ជូនឈើ*

# ១២. បទសំភាសន៍ជាមួយស្ថាប័នពាក់ព័ន្ធ

១. នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០១៤ អ្នកកាសែតម្នាក់ដែលឃ្លាំមើលព្រៃឈើនៅក្នុងខេត្តរតនគិរី បានផ្តល់ព័ត៌មានតាមទូរស័ព្ទថា មានអ្នកកាសែតជាច្រើន បានដឹងពីមុខរបរកាប់ឈើនៅក្នុងខេត្តស្ទឹងត្រែង រតនគីរី និងមណ្ឌលគីរី។ កាលពីមុនក្រុមហ៊ុនរកស៊ីឈើធំៗមួយចំនួនមានក្រុមហ៊ុនម៉ុង រិទ្ធីគ្រុប ក្រុមហ៊ុនអានម៉ារឌី ក្រុមហ៊ុនលឹម ប៊ុណ្ណា និងក្រុមហ៊ុនមួយចំនួនផ្សេងទៀត ប៉ុន្តែនៅចុងឆ្នាំ២០១៣ ឈានចូលឆ្នាំ២០១៤ ក្រុមហ៊ុនទ្រីភាពគ្រុបទទួលបានសិទ្ធិផ្តាច់មុខក្នុងការប្រមូលឈើប្រណីតនៅក្នុងខេត្តទាំងបីនេះ និងនៅទូទាំងប្រទេស។ អ្នកកាសែតរូបនេះ បានឃើញឃ្លាំងស្តុកឈើ តំបន់ស្តុកទុក និងដេប៉ូឈើជាច្រើនទៀតរបស់ក្រុមហ៊ុនទីភាពគ្រុប។ លោកបាននិយាយថា ដេប៉ូឈើដ៏ធំបំផុតមានទីតាំងស្ថិតនៅឧដ្ដុង្គខេត្តកំពង់ស្ពឺ ជាកន្លែងស្តុកទៅដោយឈើប្រណីតៗប្រមូលមកពីទូទាំងប្រទេសកម្ពុជា មុនធ្វើការ

នាំចេញទៅកាន់ប្រទេសចិន។ កន្លងមកក្រុមហ៊ុន ក៏បានដឹកជញ្ជូនឈើទៅកាន់ប្រទេសវៀតណាមផងដែរ ប៉ុន្តែនៅពេលដែលតម្លៃឈើបានកើនឡើងខ្ពស់ក្រុមហ៊ុនទ្រីភាពគ្រុបបានចាប់ផ្តើមនាំឈើចេញទៅកាន់ប្រទេសចិនដោយផ្ទាល់វិញម្តង។ អ្នកការសែតរូបនេះបានអះអាងបញ្ជាក់ថា ក្រុមហ៊ុននិងអ្នកកាប់ឈើទាំងអស់ចាំបាច់ត្រូវសុំអាជ្ញាប័ណ្ណពីក្រុមហ៊ុនទ្រីភាពគ្រុប។ ក្រុមហ៊ុនទ្រីភាពគ្រុប ទទួលបានសិទ្ធិផ្តាច់មុខលើការនាំចេញឈើប្រណីត ដែលគាំទ្រដោយលោក"ឪពុកធម៌" (អ្នកកាសែតបានសំដៅទៅលើនាយករដ្ឋមន្ត្រី)។ ប្រតិបត្តិការរបស់ក្រុមហ៊ុននេះត្រូវបានការពារដោយកងកម្លាំងប្រដាប់អាវុធ ទាហានព្រំដែន មន្ត្រីរុក្ខាប្រមាញ់ និងមន្ត្រីតុលាការ ហេតុដូច្នេះគ្មាននរណាម្នាក់ហ៊ានប្រឈមជាមួយក្រុមហ៊ុននេះទេ។ ប្រសិនបើមានក្រុមហ៊ុនផ្សេងទៀតចូលមកកាប់ឈើក្នុងតំបន់ ហើយមិនលក់ឲ្យក្រុមហ៊ុនទ្រីភាពនោះទេ កងកម្លាំងប្រដាប់អាវុធរបស់ក្រុមហ៊ុននឹងរឹបអូសយកឈើនិងជាញាប់ញាប់បានចាប់អ្នកកាប់ឈើទាំងនោះ។ ទោះជាយ៉ាងណាគេក៏បានដឹងដែរថា សមាជិកនៃកងកម្លាំងប្រដាប់អាវុធ និងមន្ត្រីរុក្ខាប្រមាញ់ បានអនុញ្ញាតឲ្យកាប់ឈើជាឯកជន តែតម្រូវឲ្យអ្នកកាប់ឈើបង់ប្រាក់។ ចំពោះចំនួនទឹកប្រាក់ ដែលបានបង់ទៅឲ្យមន្ត្រីទាំងនោះ គឺវាអាស្រ័យលើទំហំឈើដែលដឹកជញ្ជូន។ ការដឹកជញ្ជូនតាមម៉ូតូត្រូវបង់តម្លៃពី ១០.០០០រៀល ទៅ ២០.០០០ រៀលក្នុងមួយជើងខណៈដែលតម្លៃសរុបសំរាប់ដឹកឈើទៅព្រំដែនវៀតណាម គឺមានតម្លៃចន្លោះពី ៣០០.០០០រៀល ទៅ៥០០.០០០រៀលក្នុងមួយជើង។ ការបង់ប្រាក់ទៅឲ្យមន្ត្រីមួយចំនួនដែលប្រចាំការនៅតាមផ្លូវសំរាប់ការដឹកជញ្ជូនឈើដោយរថយន្តគឺមានចន្លោះពី១០០.០០០រៀល ទៅ ៤០០.០០០រៀល។ សរុបមកដើម្បីដឹកឈើទៅដល់ព្រំដែនវៀតណាមត្រូវចំណាយអស់ ២០០០ ទៅ៣០០០ដុល្លារក្នុងមួយជើង។

អ្នកកាប់ឈើដែលមិនធ្វើការឲ្យក្រុមហ៊ុនទ្រីភាព មិនចង់លក់ឈើរបស់គេឲ្យក្រុមហ៊ុនទេ ខណៈពេលដែលតម្លៃគឺទាបជាងនូវអ្វីដែលគេអាចទទួលបាននៅឯព្រំដែនវៀតណាម និងឡាវ។ ឧទាហរណ៍ ឈើផ្ចង់មុខកាត់៣០សម និងបណ្តោយប្រវែង១២០សម អាចបានតំលៃពី១៥០ទៅ ២០០ដុល្លារក្នុងមួយម៉ែត្រគូបនៅលើទីផ្សារក្នុងព្រៃ។ នៅទីផ្សារតាមភូមិដែលតម្លៃកើនឡើងរហូត ដល់២៥០ទៅ៣០០ដុល្លារក្នុងមួយម៉ែត្រគូប និងនៅទីផ្សារសេរីតម្លៃកើនឡើងម្តងទៀត ចន្លោះពី ៨០០ទៅ១០០០ដុល្លារក្នុងមួយម៉ែត្រគូប។ នៅដេប៉ូទ្រីភាពឲ្យតែ ៧០០ដុល្លារអាមេរិកតែប៉ុណ្ណោះ ក្នុងមួយម៉ែត្រគូប។ ប្រសិនបើលក់ឲ្យឈ្មួញឯកជនវិញមួយម៉ែត្រគូប អាចទទួលបាន ២០០០ ទៅ ៣០០០ដុល្លារ (តម្លៃនៅតាមព្រំដែននៃតំបន់សវៀតណាម និងឡាវ)។ តម្លៃនេះអាចកើនឡើងរហូតដល់៥០០០ដុល្លារ[39] ក្នុងមួយម៉ែត្រគូបនៅទីផ្សារក្នុងប្រទេសវៀតណាម។

ប្រសិនបើអ្នកកាប់ឈើ សហការជាមួយក្រុមហ៊ុនវិញនោះគេនឹងទិញក្នុងតម្លៃ ១០០០

[39] www.alibaba.co, ចូលមើលថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤ និងយោងEIA

ដុល្លារ ក្នុងមួយម៉ែត្រគូប។ តម្លៃសំរាប់អាជ្ញាប័ណ្ណ២០០ដុល្លារក្នុងឈើមួយម៉ែត្រគូប សរុបទាំងអស់១២០០ ដុល្លារក្នុងមួយម៉ែត្រគូប។ ការសហការនេះសំរួលដល់ការដឹកជញ្ជូន អាជ្ញាប័ណ្ណ និងការនាំចេញ ដែលត្រូវបានដោះស្រាយដោយក្រុមហ៊ុន ដោយគ្មាននរណាម្នាក់នឹងបញ្ឈប់ការដឹកជញ្ជូននេះ បានទេ។

អ្នកកាសែតរូបនេះមានការទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយមេការក្រុមហ៊ុននៅក្នុងខេត្តរតនគិរី គឺលោកសាល (ប៉ុល វិសាល)។ គាត់បាននាំអតិថិជនទៅទិញឈើពីក្រុមហ៊ុនដោយទទួលបានកំរៃជើងសារ។

បុរសម្នាក់ដែលធ្វើការឲ្យក្រុមហ៊ុនទ្រីភាព អស់រយៈពេលដ៏យូរបាននិយាយថាក្រុមហ៊ុននេះបានបញ្ជូនកងកម្លាំងប្រដាប់អាវុធ ចូលទៅក្នុងព្រៃ ដើម្បីឃ្លាំមើលមេការ និងកម្មករទាំងអស់។ ប្រសិនបើរកឃើញថាពួកគេលក់ឈើឲ្យអ្នកក្រៅដោយផ្ទាល់ឬឈ្មួញផ្សេងទៀតនៅតាមបណ្ដោយព្រំដែនឡាវ នោះពួកគេនឹងត្រូវចាប់ខ្លួនជាក់ជាមិនខាន។

២. អ្នកការពារព្រៃឈើនៅក្នុងប៉ាក់កាឡាន់ ស្រុកវ៉ឺនសៃ បាននិយាយថា ក្រុមហ៊ុនទ្រីភាពបានពង្រាយមេការនិងថៅកែឈើជាច្រើននាក់ពេញព្រៃដើម្បីកាប់ឈើប្រណីត។ លោកបាននិយាយថា យ៉ាងហោចណាស់មានដេប៉ូឈើចំនួន២០កន្លែងនៅតាមដងទន្លេសេសាន។ នៅភាគខាងលិចនៃភូមិកាឡាន់ មានរថយន្តដឹកឈើយ៉ាងហោចណាស់២០០គ្រឿង បានដឹកឈើជារៀងរាល់ថ្ងៃ។ មេភូមិ មេឃុំ ប៉ូលីស យោធា ប៉ូលីស និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់បានយកប្រាក់ ១០០.០០០រៀល ក្នុងមួយរថយន្ត(ក្នុងឆ្នាំ២០១៣) ដើម្បីអនុញ្ញាតឲ្យរថយន្តឆ្លងកាត់បាន។ នៅខែមិថុនា ឆ្នាំ២០១៤ ការកាប់ឈើបានថយចុះក្នុងតំបន់នោះ ដោយសារតែដើមឈើដែលនៅសេសសល់គឺមានចំនួនតិចតួចប៉ុណ្ណោះដែលជាហេតុនាំអោយអ្នកដឹកជញ្ជូនបានកាត់បន្ថយចំនួនទឹកប្រាក់ដែលពួកគេចង់បង់ទៅឲ្យមន្ត្រីមួយចំនួននោះ។ នៅឆ្នាំ២០១៣ និងឆ្នាំ២០១៤ ក្រុមហ៊ុនបានកាប់ឈើនៅក្នុងព្រៃដែលសហគមន៍ប្រើប្រាស់។ មេការបានត្រួសត្រាយផ្លូវពីឧទ្យានជាតិទៅដល់ព្រំដែនឡាវ ដែលជាកន្លែងសម្បូរណ៍ទៅដោយឈើធ្នង់ និងឈើប្រណីតដ៏ទៃទៀត។ លោក អ៊ិត ណៃ ដែលជាទាហាននៅភូមិប៉ាកាឡាន់ លោក ហំ ហយ ជាទាហានផ្លាយពីរមកពីផ្នែកកង៧០ និងលោកស៊ឹម លាង ត្រូវបានឈរជើងនៅកូកឡាក់ ពួកគាត់សុទ្ធសឹងជាអ្នកធ្វើការឲ្យក្រុមហ៊ុនទ្រីភាព។

ក្នុងដំណាក់កាលដំបូងបង្អស់ សហគមន៍មូលដ្ឋាន បានបរាជ័យក្នុងការព្យាយាមរារាំងមិនឲ្យក្រុមហ៊ុនធ្វើការកាប់ឈើ។ អ្នកតំណាងក្រុមហ៊ុនជាច្រើននាក់បានប្រាប់សហគមន៍មូលដ្ឋានទាំងនោះថា គេមានឯកសារផ្លូវច្បាប់សំខាន់ៗដែលអនុញ្ញាតឲ្យពួកគេចូលទៅកាប់ឈើ ប៉ុន្តែពួក គេមិនដែលបានបង្ហាញឯកសារទាំងនោះជាសាធារណៈឡើយ។ ពួកគេក៏បាននាំកងកម្លាំងប្រដាប់អាវុធមកបំភិតបំភ័យអ្នកភូមិ។ ប្រជាជនមូលដ្ឋានមិនដឹងថា តើពួកគេត្រូវការពារព្រៃឈើទាំងនោះ បានដោយរបៀបណានោះទេ ហេតុដូច្នេះវាបណ្ដាលឲ្យសហគមន៍

មួយចំនួនបានចូលរួមកាប់ឈើដោយជឿថា ព្រៃឈើនឹងត្រូវបានគេកាប់បំផ្លាញអស់ជាមិនខាន ហើយពួកគេគួរតែទទួលបានប្រយោជន៍ហិរញ្ញវត្ថុខ្លះដែរ។ នៅដើមឆ្នាំ២០១៤ ព្រៃដែលសហគមន៍ប្រើប្រាស់ត្រូវបានគេបំផ្លាញស្ទើរគ្មានសល់ ដូច្នេះមេការក៏បានសំរុកយ៉ាងលឿនប្តូរទៅក្នុងឧទ្យានជាតិវីរៈជ័យ។ នៅដើមខែកក្កដា ឆ្នាំ២០១៤ ក្រុមហ៊ុននេះបានផ្អាកកាប់ឈើដោយសារតែភ្លៀងធ្លាក់ខ្លាំងពិបាកដឹកជញ្ជូន ស្របពេលដែលវៀតណាមបានផ្អាកទិញឈើដោយសារតែបញ្ហាជម្លោះកោះជាមួយប្រទេសចិន។

៣. សកម្មជនព្រៃឈើនៅតាំពួនរឿងធំក្នុងឃុំតាវែងក្រោម ស្រុកតាវែង បាននិយាយថាមេការរបស់ក្រុមហ៊ុនទ្រី ភាព បួននាក់កំពុងប្រតិបត្តិការនៅក្នុងតំបន់នេះ មានឈ្មោះ តា គ្រី (ត្រូវបានគេស្គាល់ផងដែរថា ម៉េង គ្រី មកពីក្រុមហ៊ុនក្រុងប៊ុក) តាអេង តាម៉ាប់ និងតាណាក់។ មន្ត្រីបរិស្ថានម្នាក់ ឈ្មោះតាសិដ្ឋ (គេស្គាល់ថាអាំ និសិដ្ឋ ) ក៏ជាប់ពាក់ព័ន្ធផងដែរ។ បុរសម្នាក់ឈ្មោះ តាឈុយ ជាកងរាជអាវុធហត្ថម្នាក់ និងម្នាក់ទៀត មានឈ្មោះតាឃាំជាអ្នកទិញឈើខណៈដែល បុរសម្នាក់ឈ្មោះ តាចាន់ ដែលត្រូវជាដៃដើងមេការ។ តាគ្រី ដែលជាមេការល្បីល្បាញម្នាក់ បានទិញព្រៃសហគមន៍ ពីសហគមន៍ និងអាជ្ញាធរមូលដ្ឋាន។ អ្នកផ្សេងទៀតបានទិញឈើនៅក្នុងព្រៃ ហើយដឹកទៅដេប៉ូជាបន្តទៀត។

តាសិដ្ឋ បានពង្រាយមន្ត្រីបរិស្ថាន ដើម្បីកាប់ឈើនិងយាមកាមនៅតំបន់ព្រៃការពារ ដូច្នេះ គ្មាននរណាម្នាក់មកពីខាងក្រៅអាចចូលបានទេ។ តាអេងដែលជាម្ចាស់ត្រាក់ទ័រមានកូនប្រុសម្នាក់ ធ្វើការជាមន្ត្រីបរិស្ថានផងដែរ។ ក្នុងមួយខែគាត់ទទួលបានប្រាក់២00ដុល្លារពីក្រុមហ៊ុន។ អាជ្ញាធរមូលដ្ឋាននិងប្រធានសហគមន៍ទទួលបានប្រាក់ និងរបស់របរដែលជា "អំណោយ" ជាថ្នូរនឹងការអនុញ្ញាតឲ្យកាប់ឈើចូលទៅមុខបន្តទៀត ក្នុងតំបន់របស់ពួកគេ។ ការចំណាយទាំងនេះរួមមាន៖ ប្រាក់៣០០០ដុល្លារសម្រាប់មេឃុំ ប្រាក់៦00ដុល្លារ និងម៉ូតូមួយគ្រឿងសម្រាប់មេភូមិ ម៉ូតូមួយគ្រឿងសម្រាប់មេសហគមន៍ និងបង់២៥ដុល្លារឲ្យប៉ូលីសក្នុងរថយន្តដឹកឈើមួយគ្រឿងដើម្បីធានាបាននូវការឆ្លងកាត់ដោយសុវត្ថិភាព។ ការបង់ប្រាក់នេះលែងមានទៀតហើយដោយសារតែឈើប្រ ណីតនៅតំបន់នេះបានរេចរិលអស់ ហើយអ្នកកាប់ឈើបានផ្លាស់ទីតាំងទៅកន្លែងផ្សេងទៀតនៅក្នុងតំបន់ការពារឧទ្យានជាតិ ។

៤. សកម្មជនព្រៃឈើពីររូបដែលជាឪពុកនិងកូនមកពីភូមិឡុំឡែម ដែលពួកគាត់ជាញឹកញាប់បានដឹកនាំការទាមទារតវ៉ាប្រឆាំងនឹងក្រុមហ៊ុន ដែលកំពុងកាប់ឈើនៅអណ្តូងមាសក្នុងឃុំម៉ាលិក បានរៀបរាប់ពីការកាប់បំផ្លាញព្រៃឈើ នៅតំបន់អណ្តូងមាសថា ក្រុមហ៊ុន៧មករា ក្រុមហ៊ុនក្រុងប៊ុក ក្រុមហ៊ុនហ័ងអាញយ៉ាឡាយ (Hoang Anh Gai Lai) ក្រុមហ៊ុនម៉ានយ៉ាង ក្រុមហ៊ុនយ៉ាងជាំងលី(Yang Jaing Li) និងក្រុមហ៊ុនអានម៉ារឌី បានបំផ្លាញព្រៃឈើទាំងស្រុងនៅក្នុងតំបន់នេះ។ ពួកគាត់បាននិយាយថាក្រុមហ៊ុនទ្រីភាពគ្រប់បានដឹកឈើទាំងយប់ទាំងថ្ងៃ និងរាល់ក្រុមហ៊ុនកាប់ឈើនៅក្នុងព្រៃ បានដឹកជញ្ជូនយកទៅរោងម៉ាស៊ីនអារឈើ

របស់ទ្រីភាព។ ចំណែកកម្មករកាប់ឈើវិញគឺមកពីតាមបណ្តាខេត្តនានា ដែលពួកគេជួលក្នុងកំរ៉ៃ២០ដុល្លារក្នុងមួយម៉ែត្រគូប។ អ្នកភូមិមូលដ្ឋានមិនត្រូវបានគេជួលយកទៅធ្វើការជាមួយក្រុមហ៊ុននោះទេ សូម្បីតែធ្វើដំណើរឆ្លងកាត់តាមផ្លូវក្រុមហ៊ុនក៏មិនបានផង។ ដំបូងឡើយក្រុមហ៊ុនបានសន្យាជាមួយអ្នកភូមិថា ពួកគេនឹងទទួលបានការប៉ះប៉ូវ ឬសំណងតាមរយៈការអភិវឌ្ឍន៍ និងបង្កើនជីវភាពរស់នៅរបស់អ្នកភូមិឲ្យកាន់តែមានភាពប្រសើរឡើង ផ្ទុយទៅវិញអ្នកភូមិកាន់ក្រទៅៗ ដោយសារតែការបាត់បង់ធនធានធម្មជាតិ ដីបង្កបង្កើនផល និងការខូចខាតផ្លូវថ្នល់ជាដើម។ ក្រុមហ៊ុនទ្រីភាពបានសង់ស្ពានដែក ឆ្លងកាត់ទន្លេសេសាន ដូច្នេះការដឹកជញ្ជូនឈើរបស់ពួកគេគឺអាចដំណើការបានយ៉ាងងាយស្រួល។ ប្រជាជនមូលដ្ឋានមិនត្រូវបានគេអនុញ្ញាតឲ្យធ្វើដំណើរឆ្លងតាមស្ពាននោះទេ ហើយពួកគេមិនអាចចូលទៅក្នុងតំបន់ឧទ្យានជាតិដោយគ្មានការអនុញ្ញាតពីក្រុមហ៊ុន។ អ្នកស្រុកបាននិយាយថា ពួកគាត់មានជីវភាពល្អប្រសើរមុនពេលដែលក្រុមហ៊ុនចូលមកដល់។ ពួកគាត់អាចរកចំណូលបានពីវិស័យទេសចរណ៍ធម្មជាតិ ដោយនាំអ្នកទេសចរណ៍ដោយជូនដើរថ្មើជើងទៅកំសាន្តលេងក្នុងឧទ្យានជាតិតែបច្ចុប្បន្នភ្ញៀវទេសចរណ៍លែងមកតំបន់នេះទៀតហើយ ព្រោះឧទ្យានមិនត្រូវបានគេអនុញ្ញាតិឲ្យចូលម្យ៉ាងទៀត សត្វព្រៃក៏បានបាត់បង់ដូច្នេះមិនមានអ្វីដែលត្រូវមើលតទៅទៀតនោះទេ។ អ្នកទេសចរណ៍ បានធ្វើការត្អូញត្អែរនៅលើប្រព័ន្ធអ៊ីនធឺណែតថា អ្វីដែលពួកគេបានលឺនៅក្នុងព្រៃគឺមានតែសំលេង រណាអារឈើតែប៉ុណ្ណោះ។

៥. សកម្មជនព្រៃឈើម្នាក់ និងអតីតកម្មកររបស់ទ្រីភាព ដែលរស់នៅភូមិទាមលើ ឃុំការចូន ស្រុកវ៉ឺនសៃ បានរៀបរាប់អំពីការងារជាកម្មករអារឈើឲ្យក្រុមហ៊ុនទ្រីភាពគ្រប។ លោកបាននិយាយថា មេការ តាលាង និងតាហាយ បានឲ្យគាត់៥០ដុល្លារក្នុងមួយម៉ែត្រគូប ដើម្បីកាប់ឈើផ្ទង់។ ប្រសិនបើគាត់ប្រើម៉ាស៊ីនអារឈើផ្ទាល់ខ្លួន គាត់អាចរកប្រាក់ចំណូលបាន ១០០ ដុល្លារក្នុងមួយម៉ែត្រគូប។ ក្រុមហ៊ុនជាចំណាយលើថ្លៃប្រេង។ តាហាយ និងតាលាងបានចំណាយប្រាក់១០០០ដុល្លារទៅឲ្យមេភូមិសំរាប់ការយល់ព្រមឲ្យពួកគេចូលកាប់ឈើ ទោះជាយ៉ាងណា ការទទួលប្រាក់នេះមិនបានយូរប៉ុន្មាននោះទេ ដោយសារតែការកាប់ឈើបានរើទៅកន្លែងផ្សេងទៀតអស់ទៅហើយ។

៦. អ្នកភូមិជនជាតិដើមភាគតិចកាវ៉េតម្នាក់ និងសមាជិកព្រៃសហគមន៍នៅភូមិល្មើយ ឃុំកុកឡាក់ ស្រុកវ៉ឺនសៃ ពួកគេបានស្គាល់មេការរបស់ទ្រីភាព មានឈ្មោះតាលាង និងតាហាយ។ អ្នកភូមិនេះ មិនធ្លាប់មានការពាក់ព័ន្ធនឹងការកាប់ឈើនោះទេ ប៉ុន្តែគាត់បានឃើញមេការទាំងពីរនាក់ មកទិញព្រៃឈើដែលប្រើប្រាស់ដោយសហគមន៍នៅដើមឆ្នាំ២០១៣។ នៅពេលនោះមេឃុំបានប្រកាសថា ប្រសិនបើនរណាម្នាក់មានឈើក្រុមហ៊ុននឹងប្រមូលទិញយកទាំងអស់។ តាលាង និងតាហាយ កាប់ឈើនៅកោះពាកនិងនៅផាបាំង បន្ទាប់មកពួកគេបានផ្លាស់ទៅអូរក្រាយ អូទុង អូប្រា និងនៅចម្លងជលផាត(អូរខ្យាច់)។ ពួកគេបានជួលអ្នកភូមិឲ្យកាប់ឆ្ការផ្លូវ

ដឹកឈើ ក្នុងមួយថ្ងៃ១៥០០០រៀល។ ផ្លូវដែលបានកាប់ឆ្ការគឺចេញពីវាលធំទៅវីរៈជ័យ រហូតដល់វៀតណាមនិងឡាវ។ តាលាង និងតាហាយ ក៏បានកាប់ឈើចាប់ពីអូរក្រាយ អូរទុង និងនៅតំបន់ដទៃទៀត។ ពួកគេបានស្តុកឈើទុកនៅឯភូមិឡាឡៃនៃឃុំកូកឡាក់ ដែលជាស្ថានីយ៍ស្តុកឈើ មុនពេលដឹកជញ្ជូនតាមទូកទៅកាន់ភូមិទាម។ ពួកគេបានឲ្យលុយ១០០០០រៀលទៅឲ្យប្អូនប្រុសម្នាក់របស់អ្នកដែលយើងបានសំភាសន៍ ដើម្បីចតទូកនៅក្បែរច្រាំង។ បុរសដែលយើងសម្ភាសន៏ម្នាក់បានឲ្យដឹងថាដំឡូងគាត់បានឃើញមានរថយន្តដឹកឈើយ៉ាងហោចណាស់១០គ្រឿង បានបើកកាត់តាមភូមិក្នុងមួយថ្ងៃ ប៉ុន្តែឥឡូវនេះមានតិចតួចដោយសារអត់សូវសំបូរឈើដូចកាលពីមុន។

៧. ប្រធានភូមិ និងអ្នកការពារព្រៃឈើដ៏ក្លាហានម្នាក់ មកពីភូមិត្រា ដែលប្រាប់ថាខ្លួនមានឈ្មោះ សេង ខាន់។ គាត់ធ្លាប់ឈ្លោះប្រកែក និងជំទាស់ជាមួយមេឃុំកូកឡាក់ ដើម្បីធ្វើការហាមឃាត់មិនឲ្យកាប់ព្រៃឈើដែរ ប៉ុន្តែគាត់មិនបានទទួលជោគជ័យទេ ដោយសារតែមេឃុំបានព្រមព្រៀងជាមួយរួចទៅហើយ។ ទោះបីជាអ្នកភូមិបានធ្វើការតវ៉ាយ៉ាងណាក្តី ក៏ពួកគេមិនអាចទប់ស្កាត់ការកាប់ឈើមិនឲ្យដំណើការទៅមុខបានដែរ។ អ្នកកាប់ឈើមានអាវុធក្នុងដៃ និងមានការគាំទ្រពីអាជ្ញាធរទៀតនានា។ នៅទីបំផុត អ្នកភូមិនិងសហគមន៏ផ្សេងទៀតជាច្រើន ក៏បានចូលរួមការកាប់ឈើដោយជឿជាក់ថា ដើមឈើទាំងនេះនឹងត្រូវបានគេកាប់បំផ្លាញចោលអស់ជាមិនខាន ហើយយ៉ាងហោចណាស់ក៏ពួកគេបានកំរៃមួយចំនួនផងដែរ។ ថៅកែឈើនៅក្នុងតំបន់នេះ មានឈ្មោះ សែន គាត់ក៏បានលក់ឈើប្រណីតទៅឲ្យតាលាង និងតាហាយ ផងដែរ។

ប្រជាជននៅក្នុងតំបន់នេះក៏ដូចជាតំបន់ផ្សេងទៀត នាពេលបច្ចុប្បន្នមានជីវភាពកាន់តែលំបាកជាងមុនពេលដែលក្រុមហ៊ុនកាប់ឈើបានមកដល់។ ពួកគាត់លែងមានព្រៃឈើគ្មានសត្វព្រៃ ហើយក៏មិនអាចមានទេសចរណ៍ធម្មជាតិតទៅទៀតនោះទេ។

៨. អ្នកដែលត្រូវបានសំភាសន៍ម្នាក់ទៀត គឺលោក ហាក់ សុខគា បាននិយាយថាគាត់បានសម្រេចចិត្តឲ្យមានការកាប់ឈើក្នុងតំបន់របស់គាត់ ព្រោះជីវភាពរស់នៅមិនអំណោយផល និងប្រជាជនមានស្ថានភាពកាន់តែក្រលំបាកខ្លាំងឡើងៗ។ កាលពីឆ្នាំ២០១៣ គ្រោះទឹកជំនន់បានបំផ្លាញតំបន់នេះយ៉ាងធ្ងន់ធ្ងរ ដែលធ្វើឲ្យអ្នកភូមិមិនអាចធ្វើស្រែចំការបានដូច្នេះពួកគាត់ក៏បានប្រឈមនឹងបញ្ហាខ្វះខាតស្បៀងអាហារ។

នៅដើមឆ្នាំ២០១៣ តាលាង និងតាហាយបានសាងសង់ផ្លូវមួយខ្សែរ ស្ពានមួយកន្លែង និងសាលប្រជុំក្នុងភូមិមួយ (មើលឧបសម្ព័ន្ធ១៥) ហើយបានផ្តល់៣០០០ដុល្លារទៅឲ្យមេឃុំនិង៣០០ដុល្លា ទៅឲ្យមេភូមិនីមួយៗ ដើម្បីសាងសង់ស្នាក់ការភូមិ។ ពួកគេក៏បានចំណាយប្រាក់ដើម្បីរៀបចំធ្វើពិធីសែនព្រេនតាមប្រពៃណី (ការប្រារព្ធពិធីមួយ ដើម្បីបង្ហាញ

អំពីភាពត្រឹមត្រូវរបស់អ្នកមកពីក្រៅ ធ្វើអាជីវកម្មនៅក្នុងឃុំ)។ ពួកគេបានកាប់គោឬក្របីផ្តត់ផ្តង់ជាស្រាបៀរ និងតន្ត្រី ដោយមានការប្រួងស្ទួងតាមប្រពៃណីជនជាតិដើមភាគតិចការ៉ែត។ ក្នុងរថយន្តដឹកឈើមួយគ្រឿងមេការបានធ្វើការចំណាយ១០០,០០០រៀលដើម្បីធានាឲ្យមានការឆ្លងកាត់ដោយរលូន។ ក្រោយមកសោហ៊ុយបង់ ផ្លូវបានធ្លាក់ចុះមកត្រឹម៥០,០០០រៀលក្នុងមួយឡាន។

ក្រុមហ៊ុនបានទិញដើមឈើឈរជាច្រើនសំរាប់កាប់នៅក្បែរចម្ការវិលជុំ និងដាក់ពង្រាយកម្មករជាច្រើន ដើម្បីកាប់ឈើនៅក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ រហូតដល់សៀមប៉ាង និងអូរតាពើ នៅជិតព្រំដែនឡាវ។ សមាជិកសហគមន៍ម្នាក់បានបន្ថែមថា ប្រាក់ចំនួនតិចតួចណាស់ដែលបានមកពីក្រុមហ៊ុន និងត្រូវបានប្រើប្រាស់ដោយក្រុមប្រឹក្សាឃុំ ចំណែកប្រាក់ដែលនៅសល់ត្រូវបែងចែករវាងប៉ូលីស និងប្រធានភូមិ។ គាត់បាននិយាយថា នៅពេលដែលក្រុមហ៊ុនកាប់ឈើមកបានដល់តំបន់នេះដំបូង ស្ថានភាពរស់នៅរបស់ប្រជាជនមូលដ្ឋានមានភាពប្រសើរឡើង ប៉ុន្តែនៅពេលដែលព្រៃឈើត្រូវបានគេកំទេចអស់ ហើយធនធានធម្មជាតិក៏បាត់បង់ និងវិស័យទេសចរណ៍ក៏មានភាពរអាក់រអួល។

៩. គ្រូប្រង្រៀនផ្សំថ្នាំឱសថបុរាណម្នាក់ ដែលមានជីវភាពរស់នៅពឹងផ្អែកលើព្រៃឈើ និងអនុផលព្រៃឈើបានធ្វើការតវ៉ាប្រឆាំងនឹងក្រុមហ៊ុនទ្រីភាព ដែលបានចូលមកកាប់ព្រៃឈើ។ គាត់រស់នៅក្នុងភូមិកងណាក ឃុំវ៉ឺនសៃ ហើយគាត់បានធ្វើការសច្ចាការពារ អភិរក្សព្រៃឈើ និងមិនចូលរួមក្នុងការកាប់បំផ្លាញព្រៃឈើ ជាមួយអ្នកភូមិផ្សេងទៀតជាដាច់ខាត។ គាត់បានប្រឈមនឹងការលំបាកផ្នែកហិរញ្ញវត្ថុដោយសារតែការបាត់បង់នៃធនធានធម្មជាតិ។ គាត់បាននិយាយថាតាលាងនិង តាហាយកាប់ឈើ និងបានដឹកចេញពីតំបន់នេះជារៀងរាល់ថ្ងៃ។ គាត់បានបន្ថែមថា សូម្បីតែអាជ្ញា ធរភូមិក៏បានចូលរួមកាប់ឈើជាមួយក្រុមហ៊ុនដែរ។ គាត់បានរាយការណ៍ថា គាត់បានដាក់ពាក្យបណ្តឹងទៅអាជ្ញាធរគ្រប់ជាន់ថ្នាក់ទាំងអស់របស់រដ្ឋាភិបាល ប៉ុន្តែផ្ទុយទៅវិញគាត់បែរជាទទួលបាននូវការព្រមានមួយពីមេភូមិថា កុំធ្វើឲ្យឧកញ៉ាទ្រី ភាពខឹងឲ្យសោះ ព្រោះលោកឧកញ៉ាជាមិត្តភក្តិរបស់លោកនាយករដ្ឋមន្ត្រី។ មេការបានទិញឈើផ្ទង់ក្នុងតម្លៃ២០០ដុល្លារក្នុងមួយម៉ែត្រគូប និងបានទិញដើមឈើឈរដែលមានទំហំចាប់ពី៤០សមពីអ្នកភូមិ ក្នុងតម្លៃចន្លោះពី ១០០ ទៅ ២៥០ ដុល្លារអាស្រ័យលើទំហំមុខកាត់។ មេការឈ្មោះតាលាង តាហ៊ុយ តាឈុន (សុង លិបឈុន ) និងតាចង មានទីតាំងជំរុំមួយកន្លែងនៅកូកឡាក់ ក្បែរកំពុងចម្លងសាឡាងក្នុងស្រុកវ៉ឺនសៃ។ ថៅកែឈើផ្សេងទៀតនៅប៉ាកាឡាន សុទ្ធតែជា ទាហាន និងប៉េអឹម។

កូនប្រុសពិការជើងរបស់តាហាយ បានឈរជើងនៅ អូរកាសៀប និងអូរកាយ៉ាកដែលជាតំបន់ព្រៃអារក្ស នៅកងណាក។ គាត់បានចាំទារយកលុយពីអ្នកបើករថយន្តដឹកឈើឆ្លងកាត់ផ្លូវដែលសាងសង់ដោយឪពុករបស់គាត់។

ដើមឈើឈរជាច្រើនប្រភេទត្រូវបានគេកាប់ផ្តួលរំលំ ដើម្បីឲ្យអ្នកកាប់ឈើអាចចូលទៅដឹកឈើប្រណីតបាន។ តំបន់ដែលបានទទួលរងការបំផ្លិចបំផ្លាញទាំងនោះ រួមមានៈ វាំងធឿន លូងខាប់ និងស៊ូត្រាដែលស្ថិតក្នុងឃុំកងណក និងយានបែក នៅល្មើយ។ មេការបានកាប់ឈើនៅក្នុងតំបន់ថ្មីៗ ដូចជាអូរចង អូរប្រា អូរមឿងទើស និងអូរមឿងហាយ ហើយបានបំលាស់ទី យ៉ាងលឿនទៅសៀមប៉ាង ក្នុងខេត្តស្ទឹងត្រែង។

១០. អ្នកបើកបររថយន្តម្នាក់ ដែលបានបំរើការឲ្យទ្រី ភាពគ្រុប នៅស្រុកសណ្តាន់ ខេត្តកំពង់ធំ អស់រយៈពេលយូរឆ្នាំណាស់មកហើយបាននិយាយថាគាត់មានជំរុំទីតាំងនៅកាឡាន ស្រុករ៉ុនសែ ដែលគ្រប់គ្រងដោយលោកថេន។ គាត់បាននិយាយថា គាត់បានដើរតាមថៅកែឈើរបស់គាត់ចូលទៅក្នុងព្រៃនៅខេត្តរតនគិរី ប៉ុន្តែគាត់មិនភ័យខ្លាចអ្វីទេព្រោះថៅកែបានជឿទុកចិត្តលើគាត់។ គាត់ចេះគណនាទំហំនិងថ្លឹងទម្ងន់ឈើបានអាចដើរក្នុងព្រៃ ចេះដោះស្រាយបញ្ហា និងជួសជុលរថយន្ត។ គាត់ខំប្រឹងធ្វើការ និងមិនសូវបានត្រលប់ទៅផ្ទះទេ។

គាត់បាននិយាយថា ថៅកែឈើទាំងអស់ គឺជាប៉ូលីស កងរាជអាវុធហត្ថ ទាហាន ឬជាមនុស្សមានអំណាច ដោយគ្មាននរណាម្នាក់ហ៊ានសួរនាំអ្វីឡើយ។ ថៅកែថេនបានណែនាំគាត់ថា ប្រសិនបើមាននរណាម្នាក់សួរ គាត់គួរនិយាយថាឈើទាំងនេះជារបស់ក្រុមហ៊ុនទ្រីភាពគ្រុប ដែលមានខ្នងបង្អែកជាព្រះឥន្ទ (លោកនាយករដ្ឋមន្ត្រី)។ គាត់ត្រូវបានគេប្រាប់ថា ប្រសិនបើមាននរណាម្នាក់សួរនាំពីភាពស្របច្បាប់នៃការរកស៊ី គួរណែនាំគាត់ឲ្យទៅសួរព្រះឥន្ទដោយផ្ទាល់។

អ្នកផ្តល់បទសំភាសន៏រូបនេះ បាននិយាយថាគាត់អាចដឹកឈើបាន ១០ម៉ែត្រគូបក្នុងជើងបានកំរៃ១៨០ដុល្លារ។ លោកបាននិយាយថា លោកអាចដឹកពី៥ ទៅ១០ជើងក្នុងមួយខែ អាស្រ័យលើអាកាសធាតុ ឬឧប្បត្តិហេតុផ្សេងទៀត ដូចជាឡានខូច ជាដើម។ គាត់មានព្រូឡានពីរនាក់ម្នាក់ជាអ្នករត់ការផ្លូវ និងម្នាក់ទៀតជាអ្នកត្រួតពិនិត្យ ដែលថៅកែឲ្យ២០ដុល្លារក្នុងមួយថ្ងៃ។

អ្នកបើកបរឡានរូបនេះ បាននិយាយថាមុនដំបូង ក្នុងមួយកន្លែងគាត់បានបង់ ១០០.០០០រៀលទៅឲ្យប៉ូលិស កងរាជអាវុធហត្ថ ទាហាន មន្ត្រីបរិស្ថាន មន្ត្រីរុក្ខាប្រមាញ់ មេភូមិ មេឃុំ សន្តិសុខ សមាជិកសហគមន៍ និងអ្នកកាសែត ទើបគាត់អាចឆ្លងកាត់ផ្លូវ និងស្ពានបាន។ ក្រោយមកក៏ ធ្លាក់មកនៅត្រឹម តែ១០.០០០ឬ២០.០០០រៀល ដោយសារតែគាត់បានបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយអ្នកទាំងនោះ។ សម្រាប់ការដឹកជញ្ជូនមួយជើងៗគឺ ថៅកែជាអ្នកទទួលខុសត្រូវក្នុងការទិញម្ហូបអាហារ និងប្រេងម៉ាស៊ូត (៩០០លីត្រ ឬ ៣០កាន) និងការផ្តល់ប្រាក់ដើម្បីទិញឈើ (យ៉ាងហោច២០០ដុល្លារក្នុងមួយម៉ែត្រគូប)។ បន្ទាប់មកឈើដែលបានទិញ ត្រូវលក់ទៅឲ្យអ្នកគ្រប់គ្រងសាខារបស់ក្រុមហ៊ុនទ្រីភាពក្នុងតម្លៃ៧០០ដុល្លាក្នុងមួយម៉ែត្រគូប។ ប្រសិនបើអ្នកបើកឡានលក់ ផ្ទាល់ទៅឲ្យ ដេប៉ូទ្រីភាព

នោះគាត់អាចទទួលតម្លៃ៨០០ដុល្លារក្នុង១ម៉ែត្រគូប ដក១០ដុល្លារថ្លៃអាជ្ញាប័ណ្ណ។ ថៅកែក៏ត្រូវចំណាយផងដែរចំពោះការដឹកជញ្ជូនឈើដែលឆ្លងកាត់ទន្លេ ក្នុងនោះមានតម្លៃ២៥ដុល្លារក្នុងមួយម៉ែត្រគូប។ អ្នកបើកបរបាននិយាយថា ក្រុមហ៊ុនទ្រីភាពគ្រុប បានផ្គត់ផ្គង់ស្បៀងអាហារទៅឲ្យទាហាន ប៉ូលីស កងរាជអាវុធហត្ថ និងមន្ត្រីរដ្ឋាភិបាលផ្សេងទៀត ដើម្បីដាក់កាតព្វកិច្ចរក្សាខ្សែសង្វាក់សកម្មភាពកាប់ឈើជាបន្តទៅទៀត។

ថៅកែឈើបានបង់កម្រៃប្រចាំឆ្នាំ និងប្រចាំខែទៅអាជ្ញាធរស្រុក និងខេត្តដើម្បីដំណើរការរកស៊ីរបស់ខ្លួន។ ពួកគេក៏ចំណាយលើការថែទាំរថយន្តដឹកឈើរបស់ខ្លួន។ ប្រាក់ចំណាយ និងចំណូលរបស់ពួកគេក្នុងមួយជើងអាចត្រូវបានគណនាដូចខាងក្រោម៖

| | | |
|---|---|---|
| ▪ ការទិញឈើ | $២០០ x១០ម៣ | = $ ២០០០ |
| ▪ អ្នកបើកបរ | | = $ ១៨០ |
| ▪ ព្រូឡាន/ជំនួយការ | ២នាក់ x $២០ x ៤ថ្ងៃ | = $១៦០ |
| ▪ អ្នករត់ការ | ១នាក់ x $៣០ x ៤ថ្ងៃ | = $១២០ |
| ▪ អ្នកត្រួសត្រាយផ្លូវ | | = $៣០០ |
| ▪ សាំងរថយន្ត | | = $៩០០ |
| ▪ ម្ហូបអាហារ | | = $២៥០ |
| សរុប | | = $៣,៩១០ |

| | |
|---|---|
| ប្រាក់ចំណូលសំរាប់ថៅកែក្នុង១ជើង | = $៧,០០០ |
| ការចំណាយ | = $៣,៩១០ |
| ប្រាក់ចំណេញសរុប | = $៣,០៩០ |

ប្រសិនថៅកែមានរថយន្តដឹកឈើ៦គ្រឿង ពួកគេម្នាក់អាចរកប្រាក់បាន ១៨,៥៤០ ដុល្លារ ហើយក្នុងមួយខែថៅកែអាចរកបាន ១៤៨,៣២០ ដុល្លារ ពីការដឹកជញ្ជូនចំនួនប្រាំបីជើង។

១១. មេភូមិម្នាក់ និងមេឃុំម្នាក់ បានសំដែងការព្រួយបារម្ភណ៍ចំពោះការកាប់បំផ្លាញព្រៃឈើ។ ពួកគាត់បានឃើញរថយន្តដឹកឈើប្រណីតរបស់ទ្រីភាពឆ្លងកាត់តាមភូមិកាឡាន់ទាំង

ថ្ងៃទាំងយប់ប៉ុន្តែ មិនដឹងថាត្រូវស្វែងរកនរណាមកជួយទេ។ មុនឆ្នាំ ២០១០ មិនមានការកាប់ឈើរូបភាពធំធេងកើតឡើងនៅក្នុងតំបន់នេះទេ។ បន្ទាប់ពីក្រុមហ៊ុនទ្រីភាព បានប្រកាសក្នុងកិច្ចប្រជុំនៅអាជ្ញាធរខេត្តថា ក្រុមហ៊ុនបានឈ្នះការដេញថ្លៃសិទ្ធិកាប់ឈើនៅទូទាំងប្រទេសកម្ពុជា។ ជាគោលការណ៍ ក្រុមហ៊ុនត្រូវបានគេសន្មត់ថានឹងជួយដល់ការអភិវឌ្ឍនៅក្នុងតំបន់នេះ ដើម្បីជាថ្នូរនឹងការកាប់ឈើ។ ប៉ុន្តែវាមិនបានកើតឡើងទេ រថយន្តធំៗបានចូលមកដល់ការកាប់ឈើបានចាប់ផ្តើម ហើយផ្លូវថ្នល់ក្នុងតំបន់នោះត្រូវបានបំផ្លាញ។ នៅពេលដែលសហគមន៍ធ្វើការទាមទារតវ៉ា និងបានបិទផ្លូវក្រុមហ៊ុនបានប្រើប្រាស់ផ្លូវផ្សេងដោយមិនធ្វើការជួសជុលផ្លូវចាស់ដែលជារបស់រដ្ឋ។ ក្រុមហ៊ុននេះបានព្យាយាមបំពេញចិត្តសហគមន៍ និងអាជ្ញាធរមូលដ្ឋាន ដោយបានផ្តល់សត្វពាហនៈសម្រាប់ធ្វើពិធីបែបប្រពៃណី និងការបង់ថ្លៃសេវាប្រើប្រាស់ផ្លូវ និងស្ពាន។ ក្រុមហ៊ុនបានបង់ ១០,០០០ ទៅ ៥០,០០០ រៀល ទៅឲ្យមេឃុំ ៥០,០០០រៀលទៅប៉ូលីស ១០០,០០០រៀលទៅប៉េអឹម និង២០០,០០០រៀលទៅមន្ត្រីរដ្ឋបាលព្រៃឈើ មន្ត្រីបរិស្ថាន និងការិយាល័យល្បាតព្រៃរបស់អង្គការអភិរក្សអន្តរជាតិនៅអូរកាស៊ីប។ ក្រុមហ៊ុនក៏បានបង់១,០០០ដុល្លារផងដែរទៅឲ្យអាជ្ញាធរខេត្ត ចំពោះការអនុញ្ញាតិឲ្យសាងសង់ដេប៉ូឈើមួយកន្លែង។ នៅក្នុងកិច្ចប្រជុំជាមួយនឹងអាជ្ញាធរខេត្ត ក្រុមហ៊ុនមិនបានបង្ហាញឯកសារដែលអនុញ្ញាតឲ្យពួកគេធ្វើការកាប់ឈើនោះទេ ហើយក៏មិនបានបង្កើតផែនការអភិវឌ្ឍន៍ដែរ។ អ្នកដឹកនាំឃុំជាច្រើន នៅតែមិនទាន់បានឃើញឯកសារ និងផែនការអភិវឌ្ឍន៍ណាមួយនៅតំបន់នោះទេ។ មេឃុំបានបន្ទោសក្រុមហ៊ុន ដែលបានធ្វើឲ្យមនុស្សនៅក្នុងតំបន់ដែលមិនបានចូលរួមកកាប់ឈើកាន់តែមានជីវភាពក្រីក្រ។ យោងតាមស្ថិតិដែលបានកត់ត្រាដោយមេឃុំមានដេប៉ូឈើយ៉ាងហោចណាស់ ២០កន្លែង នៅតាមបណ្តោយមាត់ទន្លេ និងរថយន្តដឹកឈើចំនួន២០០គ្រឿង។ បច្ចុប្បន្នមាននៅសល់តែ៥ដេប៉ូ និងរថយន្ត៤០គ្រឿងប៉ុណ្ណោះដោយសារតែព្រៃឈើត្រូវបានគេបំផ្លាញអស់រលីង ហើយអ្នកកាប់ឈើបាផ្លាស់ទីតាំងទៅកាន់តំបន់ផ្សេងទៀតនៅឧទ្យានវីរៈជ័យ។

១២. បុរសវ័យចំណាស់ម្នាក់មកពីភូមិអ៊ីទូប បាននិយាយថា កិច្ចខិតខំប្រឹងប្រែងដើម្បីការពារព្រៃឈើបានក្លាយជាភាពអស់សង្ឃឹម ព្រោះអ្នកភូមិភាគច្រើនក៏បានចូលរួមពាក់ព័ន្ធនឹងការកាប់ឈើ។ លោកបានអះអាងថា សូម្បីតែបុគ្គលិកមួយចំនួនដែលបំរើឲ្យអង្គការអភិរក្សអន្តរជាតិដែលកាលពី ឆ្នាំ២០០៨ជាដៃគូរសហការជាមួយរដ្ឋបាលព្រៃឈើដើម្បីបើកស្ថានីយ៍មួយមានទំហំ៥៥.០០០ហិកតា សំរាប់ការពារតំបន់អភិរក្សវ៉ឺនសៃសៀមប៉ាង ពួកគេបានលក់ឈើប្រណីតទៅឲ្យតាឈុន (សុង លីបឈុន)។ ទង្វើនេះបានកើតមានឡើង នៅពេលដែលតំបន់នោះស្ថិតក្រោមការគ្រប់គ្រងរបស់អតីតមេស្ថានីយ៍អង្គការអភិរក្សអន្តរជាតិ និងរដ្ឋបាលព្រៃឈើនៅអូរកាសៀប។ អ្នកគ្រប់គ្រងថ្មីក៏ត្រូវបានគេរកឃើញផងដែរថា បានពង្រាយកម្លាំងប្រដាប់អាវុធ ដើម្បីយកប្រាក់ពីអ្នកកាប់ឈើក្នុងតំបន់អភិរក្សវ៉ឺនសៃសៀមប៉ាង។ សកម្មជនរូបនេះបានអះអាងថា បុគ្គលិកដែលជួលដោយអង្គការអភិរក្សអន្តរជាតិ (រដ្ឋបាលព្រៃឈើ និង

កងរាជអាវុធហត្ថ) បានទារ១០០,០០០រៀលជាកំហិត។ គាត់បានអះអាងថា មន្ត្រីបរិស្ថានបានដាក់ពង្រាយកងកម្លាំងប្រដាប់អាវុធការពារតាមច្រកចូលនៃឧទ្យានជាតិវីរៈជ័យដើម្បីកុំឲ្យមានមនុស្សចូលទៅឃើញការកាប់ឈើដែលកំពុងកើតនៅក្នុងព្រៃ។

១៣. អ្នកការពារព្រៃឈើដ៏លេចធ្លោម្នាក់ នៅក្នុងភូមិតាវែ្ឡ ឃុំសន្តិភាព បានបោះបង់ការងារ និងចាប់ផ្តើមរកស៊ីកាប់ឈើឲ្យថៅកែមានអំណាចម្នាក់ឈ្មោះ យាយ អឿន ដែលបានកាប់ឈើនៅតាវែ្ឡតាំងពីឆ្នាំ២០០៤ និងបានចាប់ផ្តើមកាប់ឈើក្រញូង បេង នាងនួន និងធ្នង់គីអាស្រ័យលើតម្រូវការទីផ្សារ។ បច្ចុប្បន្ន ឈើប្រណីតពីក្នុងព្រៃសហគមន៍នេះត្រូវបានគេកាប់ក្លាយជាវាលល្វឹងល្វើយ ហើយអ្នកកាប់ឈើបានផ្លាស់ទីតាំងទៅលើភ្នំ និងកំណត់គោលដៅក្នុងតំបន់ថ្មីមួយគឺ លើកំពូលភ្នំចងដែលជាតំបន់ដ៏សក្តិសិទ្ធិមួយ។ គាត់បានយកឈើពីព្រៃនិងស្តុកនៅផ្ទះរបស់គាត់ ដើម្បីឲ្យយាយ អឿនមកវាស់ និងទូទាត់ប្រាក់ដែលក្នុងមួយម៉ែត្រគូប មានតម្លៃ២៥០ដុល្លារ។ អ្នកភូមិបាននិយាយថា ប្រសិនបើគាត់មិនកាប់ដើមឈើទេ ក៏ត្រូវគេកាប់ដែរដូច្នេះបានជាគាត់សម្រេចចិត្តចូលរួមជាមួយកាប់ឈើវិញ។

លោកបានបញ្ជាក់ថា ក្រុមហ៊ុននេះបានទិញដើមឈើ នៅក្នុងព្រៃតំបន់ការពាររ៉ឺនសែសៀមប៉ាង និងព្រៃអារក្សដោយផ្ទាល់ពីសហគមន៍នៅពេលដែលឈើធំៗទំហំជាង៥០សមនៅក្នុងឧទ្យានជាតិត្រូវបានគេកាប់ផ្តួល។ អ្នកភូមិបានអនុញ្ញាតិឲ្យគេធ្វើការកាប់ឈើ។ កាលពីមុនប្រសិនបើសហគមន៍កាប់ដើមឈើ ពួកគេនឹងត្រូវបានគេចាប់ខ្លួន និងពិន័យជាប្រាក់៥០០០ដុល្លារ ដោយក្រុមហ៊ុន។ យាយ អឿន បានអះអាងថាគាត់បានចំណាយប្រាក់រាប់ម៉ឺនដុល្លារ ដើម្បីត្រួសត្រាយផ្លូវនេះ ដូច្នេះតំបន់នេះជាកម្មសិទ្ធិរបស់គាត់។ លោកគង់ គាំដែលជាអ្នកភូមិម្នាក់ទៀតនៅតាវែ្ឡ បាននិយាយថា វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការកាត់បន្ថយចំនួនអ្នកបញ្ជាទិញ ដើម្បីសង្គ្រោះព្រៃឈើឡើងវិញ។ លោកបានថ្លែងថា ការកាប់ឈើបានផ្តល់ទ្រព្យសម្បត្តិ ឬភាពមានបានក្នុងរយៈពេលខ្លី រីឯមនុស្សមិនអាចរស់នៅដោយគ្មានព្រៃឈើដែលមានអាយុកាលរាប់រយឆ្នាំនោះទេ។

គាត់បានបន្ថែមថា មេភូមិម្នាក់បានប្រាប់ប្រជាពលរដ្ឋថាពួកគេគួរតែលក់ឈើទៅឲ្យក្រុមហ៊ុនដែលជាវិធីសាស្ត្រមួយកាត់បន្ថយភាពក្រីក្រ។ លោកបាននិយាយថាវាប្រសើរចំពោះអ្នកភូមិក្នុងការរកចំណូល ជាជាងទុកឲ្យក្រុមហ៊ុនយកកម្មករមកពីខាងក្រៅ។

១៤. សមាជិកក្រុមប្រឹក្សាម្នាក់មកពីឃុំ សន្តិភាព ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង បានរាយការណ៍ថា យាយ អឿនគឺជាថៅកែធំនិងមានឥទ្ធិពលមួយរូបនៅតាវែ្ឡ។ ដំបូងឡើយអ្នកភូមិបានតវ៉ាប្រឆាំងនឹងការកាប់ឈើ តែទោះបីយ៉ាងណាពួកគេមិនអាចតទល់ជាមួយនឹងកងកំលាំងប្រដាប់អាវុធរបស់ថៅកែឈើបានទេ ហើយទីបំផុតពួកគេក៏បានចូលរួមកាប់ឈើ។ ប្រជាពលរដ្ឋកាប់ឈើតែនៅក្នុងចំការរបស់ពួកគេឬប្រមូលបំណែកតូចៗនៃឈើប្រណីតដែលក្រុមហ៊ុនបន្សល់ទុកតែប៉ុណ្ណោះ។

នៅពេលដែលពួកគេចុះប្រមូលឈើអ្នកភូមិត្រូវបង្ខំលក់ទៅឲ្យយាយ អឿន។ ប្រសិន បើពួកគេត្រូវបានរកឃើញថា បានលក់ទៅឲ្យអ្នកផ្សេងនោះ ក្រុមហ៊ុនយាយ អឿន នឹងធ្វើការ រឹបអូសយកឈើនោះតែម្តង។ ចំពោះតម្លៃឈើ យាយអឿនឲ្យថ្លៃ២៥០ដុល្លារក្នុងមួយម៉ែត្រគូប សំរាប់ឈើធ្នង់មានមុខកាត់៣០សម និងប្រវែង២២០សម។ ក្រុមហ៊ុនរបស់គាត់ បានបង់ ប្រាក់ទៅឲ្យស្ថាប័ននានា ដែលឈរជើងនៅតាមខ្សែបណ្តោយដូចជា មេភូមិ មេឃុំ និងមេ សហគមន៍។ ពួកគេទទួលបាន៥០,០០០រៀលសម្រាប់រថយន្តនីមួយៗ ឆ្លងកាត់ផ្លូវ និងស្ពាន។ ប៉ូលីស កងរាជអាវុធហត្ថ និងមន្ត្រីព្រៃឈើ ដែលត្រូវបង់១០០,០០០រៀល។ បន្ថែមពីនេះ ក្រុមហ៊ុន បានបង់៣០០ដុល្លារក្នុងមួយខែ ជាវិភាគទានដល់ក្រុមប្រឹក្សាឃុំ។

សមាជិកក្រុមប្រឹក្សាឃុំបានបង្ហាញថា ថៅកែឈើ និងមេការនៅតំបន់នេះ មានការ ភ័យខ្លាចចំពោះអង្គការមិនមែនរដ្ឋាភិបាល ប្រព័ន្ធពត៍មាន និងជនបរទេស ដែលបានថតយករូបភាព ទៅផ្សព្វផ្សាយ ដែលបង្ហាញការកាប់ឈើខុសច្បាប់កំពុងកើតឡើង នៅក្នុងព្រៃ។ ដេប៉ូទីក្រាពបានធ្វើការហាមឃាត់មិនឲ្យមានការថតរូបភាពនៅដេប៉ូខ្លួនឡើយ។

១៥. អតីតទាហានម្នាក់ពីប៉ាងសី ខេត្តតាកែវ ដែលធ្លាប់បានធ្វើការឲ្យតាហយមេការរបស់ទ្រី ភាព ដែលក្នុងក្រុមរបស់គាត់មានកម្មករប្អូននាក់ផ្សេងទៀត។ ពួកគេបានកាប់ និងដឹកជញ្ជូន ឈើមូល និងឈើនៅពីអូរចង អូរចាយនៃដែនវីរៈជ័យ។ ក្រុមរបស់គាត់បានមកជាមួយ តាហយ ពីខេត្តពោធិ៍សាត់ ជាកន្លែងមួយដែលក្រុមទ្រីភាពបានកាប់ឈើផងដែរ។ នៅពេល ដែលឈើនៅទីនោះកាប់អស់ ពួកគេក៏បានផ្លាស់ទៅធ្វើការនៅខេត្តរតនគីរីវិញម្តង។ អតីតកង ទ័ពរូបនោះបាននិយាយថាគាត់បានទទួលប្រាក់ខែ ៥00 ដុល្លារក្នុងមួយខែ និងប្រាក់ឧបត្ថម្ភ ផ្សេងទៀត។ ក្រុមរបស់គាត់បានកាប់និងដឹកជញ្ជូនឈើឆៅមូលដែលមានតម្លៃថ្លៃជាងឈើ ឃ្លុំ។ ក្រុមរបស់គាត់បានកាប់ឈើ ហើយមិនអនុញ្ញាតឲ្យអ្នកខាងក្រៅចូលមកធ្វើការកាប់ឈើ ឡើយដោយសារក្រុមហ៊ុននេះ បានឈ្នះការដេញថ្លៃពីក្រសួងបរិស្ថានដើម្បីកាប់ឈើក្នុងតំបន់ ឧទ្យានជាតិ។

អតីតទាហានរូបនេះ បាននិយាយថា ឯកសារច្បាប់ទាំងអស់បានចែងថា លោក ឧកញ៉ាទ្រីភាព ទទួលបានសិទ្ធិពីព្រះឥន្ទ(លោកនាយករដ្ឋមន្ត្រី)ដើម្បីប្រមូលឈើ។ ជាលទ្ធផល ឬមានន័យថាព្រៃឈើក៏ជាកម្មសិទ្ធិរបស់ព្រះឥន្ទផងដែរ។ ប្រសិនបើគាត់ត្រូវបានគេរារាំងមិន ឲ្យដឹកជញ្ជូនឈើប្រណីតគាត់ប្រាប់គេថាគាត់ធ្វើការឲ្យទ្រីភាព ដូច្នេះគ្មាននរណាម្នាក់ចាប់ខ្លួន គាត់ឡើយ។ គាត់បាននិយាយថា ប្រសិនបើនរណាម្នាក់សុំប្រាក់ពីគាត់ ដូចជាប្រាក់សម្រាប់ ឆ្លងកាត់ភូមិ ឬឆ្លងកាត់ស្ពាននោះគាត់ឲ្យ។ ក្រុមរបស់គាត់បានដឹកឈើទៅស្ថានីយ៍នៅកុកឡាក់ និងឆ្ពោះទៅកាន់ដេប៉ូនៅកាចូន។ រាល់ការចំណាយផ្សេងៗត្រូវបានរៀបចំដោយតាហយ។

១៦. មន្ត្រីអង្គការអភិរក្សអន្តរជាតិ (CI) ដែលឈរជើងនៅអូរកាសៀប ស្រុកវ៉ឺនសៃ បាននិយាយថា ការកាប់បំផ្លាញព្រៃឈើនៅក្នុងតំបន់នេះ គឺបណ្ដាលមកលទ្ធផលនៃការផ្ដល់ដីសម្បទានសេដ្ឋកិច្ច។ មន្ត្រីរបស់CIបាននិយាយថាគាត់បានលឺថា ក្រុមហ៊ុនទ្រីភាពគ្រុប បានទទួលអាជ្ញាប័ណ្ណពីរដ្ឋាភិបាល ប៉ុន្តែគាត់មិនដែលបានឃើញអាជ្ញាប័ណ្ណនោះសោះ។ លោកបានបន្តទៀតថា ក្រុមហ៊ុននេះ បានប្រតិបត្តិការដោយខុសច្បាប់ ហើយបានកាប់ឈើដោយមិនកំណត់ដោយមិនគោរពច្បាប់ ឬតំបន់ការពារអ្វីឡើយ។

១៧. អ្នកដឹកនាំម្នាក់របស់ភូមិស្រម៉រ បានជួបបរាជ័យក្នុងការប៉ុនប៉ងហាមឃាត់អ្នកភូមិមិនឲ្យលក់ឈើឈរ។ គាត់មិនដែលឃើញមន្ត្រីអនុវត្តច្បាប់ ឬក្រុមល្បាតព្រៃណាមួយចាត់វិធានការប្រឆាំងនឹងអ្នកកាប់ឈើទាំងនោះទាល់តែសោះ។ ពួកគេគ្រាន់តែមកយកប្រាក់ពីថៅកែឈើតែប៉ុណ្ណោះ។ អ្នកភូមិទាំងនោះគឺជាជនជាតិភាគតិចឡាវ ដែល៥៦គ្រួសារបានពាក់ព័ន្ធនឹងរបររកស៊ីកាប់ឈើ ហើយឈើប្រណីតជាង២០,០០០ដើមត្រូវបានគេលក់ទៅឲ្យឈ្មួញ។ នៅក្នុងឆ្នាំ២០១២ ក្រុមហ៊ុន ទ្រីភាពគ្រុប បានប្រកាសផែនការសំរាប់អភិវឌ្ឍន៍ក្នុងភូមិនេះ ក៏ដូចជាផែនការជួសជុលផ្លូវ ដែលត្រូវបានបំផ្លាញដោយរថយន្តដឹកឈើ។ ទោះជាយ៉ាងណារយៈពេលពីរឆ្នាំកន្លងមកហើយ ពុំមានការអភិវឌ្ឍន៍អ្វីទាល់តែសោះ។ ថៅកែជាច្រើនបានពាក់ព័ន្ធរបររកស៊ីឈើក្នុងតំបន់នេះ រួមមាន៖ តាពង និងបងប្រុសរបស់គាត់មកពីវ៉ឺនសៃ តាឈុនមកពីវ៉ឺនសៃ យាយអឿនមកពីតាវ៉ែ្យ ទេព (កងរាជអាវុធហត្ថពីរតនគីរី) តាលាង តាហយមកពីកូកឡាក់និងតាស៊ីមមកពីក្រចេះ។ នៅក្នុងភូមិនេះប៉ូលីស កងរាជអាវុធហត្ថ និងទាហានបានយកលុយជាប្រចាំពីរថយន្តដឹកឈើ ក្នុងចន្លោះ២០.០០០ ទៅ៥០.០០០រៀល។ មានផ្លូវពីរដើម្បីដឹកឈើឆ្លងកាត់តាមតំបន់នេះ ផ្លូវសំខាន់ គឺដឹកទៅសៀមប៉ាង និងមួយទៀតគឺទៅប៉ាកាឡាន់ ដែលជាកន្លែងថៅកែដេប៉ូឈរជើងនៅទីនោះ។

១៨. បុរសចំណាស់ជនជាតិកាវ៉ែតម្នាក់ ឈ្មោះ រ៉ាំង តាញ គឺជាមេភូមិកាពីន ឃុំសន្តិភាព ស្រុកសៀមប៉ាង។ គាត់បានគ្រប់គ្រងជាង១០៣គ្រួសារ ដែលរកស៊ីកាប់ឈើ។ គាត់បាននិយាយថាមានថៅកែឈើនិងឈ្មួញសត្វព្រៃម្នាក់នៅក្នុងតំបន់នេះ ឈ្មោះ ចាន់ នី ដែលជាជនជាតិខ្មែរឥស្លាមរស់នៅក្បែរផ្ទះរបស់គាត់។ ចាន់ នី គឺជាដៃគូររបស់តាឈុន។ គាត់បានបំផុសឲ្យអ្នកភូមិចូលទៅក្នុងព្រៃកាប់ឈើផ្ទង់លក់ឲ្យក្រុមហ៊ុន បានប្រាក់២០០ដុល្លារក្នុងមួយម៉ែត្រគូប។ កាលពីមុនមេភូមិរូបនេះបានទទួល១០០.០០០រៀលក្នុងមួយរថយន្តដែលគេបានបង់សម្រាប់ការឆ្លងកាត់ស្ពាន ប៉ុន្តែឥឡូវនេះរថយន្តបានបើកតាមផ្លូវផ្សេងនៅក្នុងព្រៃ ដោយគ្រាន់តែបង់ប្រាក់ជូនកងរាជអាវុធហត្ថ ប៉ូលីសនិង ទាហានតែប៉ុណ្ណោះ។

១៩. លោក មាស ពិសិដ្ឋ ដែលមេភូមិរបស់ជានជាតិខ្មែរឥស្លាម ដែលស្ថិតក្នុង ឃុំសន្តិភាព

បានរកស៊ីកាប់ឈើនៅ អូរកាតាល់ អូរគំនាប់ និងអូរក្រូច ហើយគាត់បានលក់ឈើឲ្យថៅកែនៅស្ទឹងត្រែង។ គាត់បានកាត់ធ្នង់ជាសន្លឹក មានមុខកាត់៦០សម កំរាស់១០សម និងបណ្តោយ២២០សម។ គាត់បានកំណត់តម្លៃលក់គឺ ១00ដុល្លារក្នុងមួយសន្លឹក ប៉ុន្តែអាចចរចារគ្នាបាន។ មាន៦៥គ្រួសារដែល ស្ថិតក្រោមការគ្រប់គ្រងរបស់គាត់។ ពួកគេរកស៊ីកាប់ឈើពីព្រោះពួកគេជឿថា វាអយុត្តិធម៌ណាស់ដែលអ្នកមានអំណាច អ្នកមានទ្រព្យសម្បត្តិបានមកបំផ្លាញព្រៃឈើរបស់ពួកគាត់ ដើម្បីយកផល ចំណេញ/ប្រយោជន៏ផ្ទាល់ខ្លួន។ ទាំងមេភូមិ និងអ្នកភូមិរបស់គាត់បានសម្រេចចិត្តកាប់ឈើ ដើម្បីព្យាយាមធ្វើឲ្យស្តង់ដានៃជីវភាពរស់នៅរបស់ពួកគាត់កាន់តែប្រសើរឡើង។ មេភូមិបាននិយាយថា ការកាប់ឈើអាចជាអំពើស្របច្បាប់សម្រាប់អ្នកមានទ្រព្យ និងអ្នកមានអំណាច តែមិនអាចស្របច្បាប់បានទេសំរាប់អ្នកក្រ។

២០. បុរសម្នាក់ឈ្មោះ យុន វីរៈ និងម្នាក់ទៀតឈ្មោះ សេង លីណា ជាជនជាតិដើមភាគតិចការ៉េត បានលក់ដើមឈើឈរនៅក្នុងតំបន់ស្ទឹងចាយ ភ្នំតាង៉ូវ។ ពួកគេមកពីភូមិអូរខ្នាង ឃុំសន្តិភាព ស្រុកសៀមប៉ាង។ ពួកគេបានឡើងទៅលើភ្នំរកឈើប្រណីតធ្នង់ នៅក្នុងតំបន់ឧទ្យានជាតិ។ ពួកគេបានបាញ់ថ្នាំជាសញ្ញាសំគាល់ម្ចាស់ដើមឈើ។ យុន វីរៈ បានរកឃើញធ្នង់២០ដើម ដែលមានមុខកាត់៣០សម មុខកាត់៤០សមចំនួន៥ដើម និងមុខកាត់ ៥០សម និង៦០សមចំនួន៥ដើម។ ដើមឈើមុខ៣០សម និង៤០សម អាចលក់បាន ១៥0ដុល្លារក្នុងមួយដើម ខណៈដែលដើមឈើមានមុខកាត់៥០សមមានតម្លៃ២00ដុល្លារក្នុងមួយដើម។ ឈើទាំង២០ដើម នោះគាត់លក់បាន៤000ដុល្លារ។ កាលពីខែមេសា ឆ្នាំ២០១៤ យុន វីរៈ បានលក់ឈើធ្នង់ចំនួន៨០ដើម ទៅថៅកែម្នាក់ឈ្មោះរិទ្ធ ក្នុងតម្លៃ២០.០០០ដុល្លារ។ បុរសម្នាក់ (មិនព្រមប្រាប់ឈ្មោះ) រកបានឈើធ្នង់ចំនួន៣០ដើម និងបានលក់វាក្នុងតម្លៃ ៦០០០ដុល្លារ។ ក្នុងឈើមួយដើមអាចអារបានផលជាសាច់ឈើពីរម៉ែត្រគូប។

អ្នកភូមិជនជាតិភាគតិចឡាវម្នាក់ នៅភូមិស្រែននោង បានប្រទះឃើញឈើធ្នង់២០ដើមនៅតំបន់អូរចាយ លក់បាន៦០០០ដុល្លារ។ មានឈើចំនួន៥ដើមដែលមានមុខកាត់៦០សម មួយដើមមានមុខកាត់៩០សម មុខកាត់៨០សមមាន១ដើម មុខកាត់៥០សម និង៦០សមមានចំនួន៣ដើមនិងមុខកាត់៣០សមនិង៤០សមមានចំនួន១០ដើម។

ពុំមានឯកសារដែលបានសរសេរបញ្ជាក់អំពីការលក់ដើមឈើទាំងនេះទេ។ អ្នកលក់ និង អ្នកទិញត្រូវមានទំនុកចិត្តលើគ្នាទៅវិញទៅមក។ អ្នកលក់បានបាញ់ថ្នាំសំគាល់សញ្ញានៅជាប់ដើមឈើ ហើយអ្នកទិញគ្រាន់តែពិនិត្យ និងផ្ទៀងផ្ទាត់ចំនួនឈើប៉ុណ្ណោះ។ វិធីនេះធានាថា មិនមានទំនាស់គ្នារវាងអ្នកលក់និងអ្នកទិញអ្វីនោះទេ។

២១. មន្ត្រីមកពីឃុំសន្តិភាពម្នាក់ដែលគាំទ្រគណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាច បានសំដែងការតូចចិត្តដែលក្រុមហ៊ុនទ្រីភាពគ្រុប បានមកធ្វើសកម្មភាពកាប់ឈើ និងបំផ្លាញព្រៃឈើនៅក្នុងឃុំរបស់គាត់ តាំងពីដើមឆ្នាំ២០១៣មកម្ល៉េះ។ ផ្លូវដែលគាត់បានកសាងក្រោម

ថវិកាដែលគាត់បានស្នើសុំទៅអង្គការម្ចាស់ជំនួយនានា ត្រូវបានរថយន្តដឹកឈើបំផ្លាញ ហើយក្រុមហ៊ុនមិនបានធ្វើការជួសជុលសងឬសាងសង់ឡើងវិញទេ។ ក្រុមហ៊ុនដំបូងគេដែលបានចូលមកតំបន់នោះ គឺជារបស់លោកឧកញ៉ា ខ្នា។ មន្ត្រីរូបនេះបាននិយាយថា ក្រោយមកក្រុមហ៊ុនទ្រីភាពគ្រុប ក៏បានចូលមកដល់ហើយបានប្រមូលយកធនធានទាំងអស់ព្រមទាំងបានបំផ្លាញព្រៃឈើដែលនៅសេសសល់ចុងក្រោយបន្ថែមទៀត។ មន្ត្រីឃុំបាននិយាយថា មិនមានការពិគ្រោះយោបល់ ការចូលរួម ឬកិច្ចព្រមព្រៀងរវាងក្រុមហ៊ុននិងអាជ្ញាធរមូលដ្ឋាន ក៏ដូចជាប្រជាពលរដ្ឋឡើយ។ ក្រុមប្រឹក្សាឃុំបានស្នើឲ្យក្រុមហ៊ុនបង់៥.០០០ដុល្លារក្នុងមួយខែ សំរាប់ការអភិវឌ្ឍន៍ឃុំ ប៉ុន្តែក្រុមហ៊ុនបានបង់តែ៣០០ដុល្លារប៉ុណ្ណោះក្នុងមួយខែ។ នេះបូករួមបញ្ចូលទឹកប្រាក់ចំនួន៣០.០០០រៀល ដែលប្រមូលបានពីរថយន្តដឹកឈើនីមួយៗ ដើម្បីរួមចំណែកកសាងផ្លូវ។

មានមេការ និងថៅកែឈើជាច្រើនបានប្រតិបត្តិការនៅក្នុងតំបន់នេះរួមមាន៖ យាយអឿន តាលាង តាហយ តាជាតិ តារិទ្ធ តាជ្រុយ តាប៉ូ តាពៅ តាឡា តាយុធ្យា តាយ៉ម តាវ៉ាន់ និងតាវ៉ា។ ប៉ូលីស ប៉េអឹម ទាហាន មន្ត្រីជាន់ខ្ពស់ថ្នាក់ស្រុកនិងអ្នកផ្សេងទៀតសុទ្ធតែពាក់ព័ន្ធផងដែរ។ មេការ និងថៅកែឈើគ្រប់គ្រងតំបន់ផ្សេងៗគ្នា ដូចជា អូរចាយ អូរឡាឡី អូរកំផា អូរជាងហ៊ាង អូររួយ អូរចំលងបរ ហុង ដាក់ឡេក ប៉ុកប៉ាត់ អូរអំបិល ដាក់ពើក ដាក់ឡាក់ អូរក្រញូង វាលធំ និងវាលអណ្តែងនៃឧទ្យានជាតិវីរៈជ័យ។

មន្ត្រីឃុំបានថ្លែងជាចំហថាក្រុមហ៊ុនទ្រីភាពគ្រុប បានផ្លាស់ចូលទៅក្នុងតំបន់នេះ ដើម្បីរកប្រាក់តែប៉ុណ្ណោះ ហើយមិនបានរួមចំណែកអភិវឌ្ឍន៍អ្វីទេ។ គាត់បាននិយាយថា ឥឡូវនេះជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋានកាន់តែយ៉ាប់ទៅៗ ដោយសារតែព្រៃឈើបានខ្ទេចខ្ទីអស់សត្វព្រៃបានបាត់បង់ហើយផ្លូវក៏ត្រូវបានខូចខាតផងដែរ។ គាត់បាននិយាយថា គាត់បានលឺពាក្យចចាមអារ៉ាមថា ក្រុមហ៊ុនបានចំណាយទៅលើមន្ត្រីជាន់ខ្ពស់នគរបាល ប៉េអឹម មន្ត្រីបរិស្ថាន អាជ្ញាធរខេត្ត និងគណបក្សប្រជាជនកម្ពុជា ប៉ុន្តែមិនបានចូលរួមចំណែកក្នុងការដោះស្រាយទុក្ខលំបាករបស់ប្រជាជនមូលដ្ឋានទាល់តែសោះ។

បច្ចុប្បន្នក្រុមហ៊ុននេះ បានខិតចូលជិតដល់ព្រំដែនប្រទេសឡាវ នៅក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ ព្រោះព្រៃឈើនៅក្នុងតំបន់របស់គាត់ត្រូវបានបំផ្លិចបំផ្លាញអស់ហើយ។ មន្ត្រីរូបនោះបាននិយាយថា លោកបានឃើញក្រុមហ៊ុនកាប់យកឈើធ្នង់ក្នុងឧទ្យានជាតិវីរៈជ័យ ហើយថែរក្សាវាទុកកុំឲ្យប្រេះស្រាំមុនពេលដឹកជញ្ជូន។ គាត់បាននិយាយថា ពីមុនរដ្ឋាភិបាលបានដាក់វិធានការយ៉ាងតឹងរ៉ឹងទៅលើការកាប់ឈើប្រណីត ដូច្នេះក្រុមហ៊ុន បានអះអាងថាពួកគេគ្រាន់តែប្រមូលយកឈើដែលបានកាប់រួចទៅហើយដោយអ្នកកាប់ឈើតែប៉ុណ្ណោះ។ នេះជាយុទ្ធសាស្ត្ររបស់ពួកគេ ដើម្បីជៀសផុតពីការទទួលខុសត្រូវតាមផ្លូវច្បាប់។

មន្ត្រីឃុំរូបនេះ បាននិយាយថាលោកគ្រោងនាំអ្នកកាសែត អង្គការមិនមែនរដ្ឋាភិបាល និងជនបរទេស ដើម្បីទៅត្រួតពិនិត្យឃ្លាំមើលការកាប់ឈើខុសច្បាប់ដោយក្រុមហ៊ុនទ្រីភាព នៅក្នុងឧទ្យានជាតិវីរៈជ័យនាវជូវប្រាំង។ គាត់ចង់ដឹកនាំបេសកកម្មស្វែងរកការពិត និងប្រមូលភស្តុតាង។ គាត់បាននិយាយថា គាត់ធ្វើជាសាក្សីថាក្រុមហ៊ុនទ្រីភាព បានពង្រាយមេការ និងកម្មករ នៅគ្រប់ទីកន្លែងដើម្បីកាប់ឈើ។ គាត់ជឿជាក់ថា មិនយុត្តិធម៌ទេដែលអ្នកមាន និងអ្នកមានអំណាច អាចចូលទៅកាប់ឈើបានដោយគ្មានការដាក់ទោសខណៈដែលអ្នកក្រត្រូវបានគេចាប់ខ្លួនប្រសិនបើគេរកឃើញថាពួកគាត់បានកាប់ឈើ។

២២. មានថៅកែឈើស្រីម្នាក់នៅភូមិខ្មែរឥស្លាម ស្ថិតក្នុងឃុំសន្តិភាព។ គាត់មានអ្នករថយន្តដឹកឈើចំនួន៥គ្រឿងនិងកម្មរជាង២០នាក់។ អ្នកបើករថយន្តពីរនាក់ត្រូវបានដាក់ប្រចាំការដើម្បីទិញឈើ ហើយលក់បន្តទៅឲ្យមេការដែលមានឈ្មោះ រិទ្ធ នៅបានលុង។ គាត់បានរៀបចំយានដ្ឋាន កន្លែងចតរថយន្ត និងកន្លែងសំរាប់កម្មករកាប់ឈើស្នាក់នៅក្នុងភូមិខ្មែរឥស្លាម ដើម្បីទិញឈើដែលគេនាំចុះមកពីកំពូលភ្នំ។ គាត់បានទូទាត់កម្រៃសេវា និងគណនីទាំងអស់ជាមួយមេការក្រុមហ៊ុនដោយផ្ទាល់នៅវ៉ឺនសៃ។ កម្រៃសេវាដែលបានបង់ គឺសំរាប់ឆ្លងកាត់ផ្លូវជាច្រើនកន្លែង រួមមានបង់ ៣០.000រៀលនៅចន្ទុក និង ១00ដុល្លារទៅឲ្យអាជ្ញាធរនៅប៉ុស្តិ៍ត្រួតពិនិត្យបាក់កែ។ ព្រមទាំងបង់៥0ដុល្លារ នៅប៉ាកាឡាន់ និងកាឡាន់ និង១៣0.000 រៀលសម្រាប់ទូកដឹកឈើ។

កម្មកររបស់គាត់ បាននិយាយថា តម្លៃឈើធ្នង់ដែលមានមុខកាត់៣0សម គឺ ២00 ដុល្លារក្នុងមួយម៉ែត្រគូប និង២៥0ដុល្លារសម្រាប់ដុំមានទទឹង៥0សម។ ឈើសន្លឹកប្រវែងមុខកាត់៤0សម មួយសន្លឹកកម្រាស់១០សម ប្រវែង១២០សម គឺមានតម្លៃ៥0ដុល្លារ។ ចំណែកឯសន្លឹកដែលមានទំហំ៦០សមx២២០សមវិញមានតម្លៃ១០0ដុល្លារ។

២៣. ថៅកែដ៏មានអំណាច និងឥទ្ធិពលបំផុតដែលត្រូវបានគេចាត់ទុកថាជា «ដៃស្តាំ» របស់មេការទ្រីភាពគឺមានឈ្មោះយាយអឿន។ គាត់បានរកស៊ីកាប់ឈើនៅភូមិតាឡៃ ឃុំសន្តិភាព ស្រុកសៀមប៉ាង។ គាត់បានរកស៊ីផ្តាច់មុខជាយូរមកហើយ ដោយបានប្រមូលទិញឈើប្រណីត និងលក់ទៅឲ្យដេប៉ូទ្រីភាពដោយផ្ទាល់។ បន្ទាប់ពីបានសហការជាមួយតាឃុន ឥឡូវនេះគាត់បានក្លាយទៅជាថៅកែដ៏លេចធ្លោមួយរូបនៅវ៉ឺនសៃ។

បងថ្លៃរបស់យាយអឿនបានបម្រើការងារជាទាហាន ហើយក៏មានការពាក់ព័ន្ធជាមួយការកាប់ឈើដែរ។ នៅឆ្នាំ២០១៣ យាយអឿនបានសហការរកស៊ីជាមួយថៅកែឈើម្នាក់ដែលមានឈ្មោះឧកញ៉ាខ្នា(លឹម ប៊ុណ្ណា)។ ក្រោយមកយាយអឿម ក៏បានប្តូរទៅសហការជាមួយនឹងក្រុមហ៊ុនទ្រីភាព ដែលមានសិទ្ធិផ្តាច់មុខក្នុងការប្រមូលឈើ។ យាយអឿន មានស្រុក

កំណើតនៅខេត្តរតនគិរី ហើយបានមករកស៊ីមុខរបរកាប់ឈើនៅតំបន់នេះនៅឆ្នាំ ២០០៤ ដែលកាលនោះឈើក្រញូងកំពុងត្រូវហាងឆេង ប៉ុន្តែបច្ចុប្បន្នឈើធ្នង់កំពុងត្រូវប៉ាន់វិញម្តង។ បច្ចុប្បន្ននេះគាត់ត្រូវបានគេចាត់ទុកស្មើរជាឧកញ៉ាមួយរូបទៅហើយ។ យាយអឿមមានទំនាក់ទំនង និងទទួលប្រាក់ទូទាត់ដោយផ្ទាល់ពីទ្រីភាព។ គាត់ក៏មានឥទ្ធិពលលើឈ្មួញឈើដ៏ទៃទៀតដែរដូចជាតាលាង តាហយ និងចាន់នី។ គាត់ជាមនុស្សដំបូងគេដែលបានមកដល់តំបន់នេះ និងបានត្រួសត្រាយផ្លូវសម្រាប់រថយន្តរបស់គាត់បើកបរឆ្លងកាត់។ គាត់បានចំណាយប្រាក់ដើម្បីសាងសង់ផ្លូវ បើមានថៅកែផ្សេងឆ្លងកាត់តាមផ្លូវនោះគាត់នឹងពិន័យ៥០០០ដុល្លារក្នុងរថយន្តមួយគ្រឿង។

នៅពេលល្ងាចគាត់បានដើរវាស់ឈើ ហើយរៀងរាល់ព្រឹក គាត់ធ្វើការទូទាត់ប្រាក់ទៅឲ្យអ្នកភូមិ។ គាត់មានមនុស្ស១៥នាក់ យាមការពារផ្ទះគាត់ក្នុងនោះរួមមាន ប៉ូលីស កងរាជអាវុធហត្ថ ទាហាន អ្នកភូមិ អ្នកល្បាតសហគមន៍និងមន្ត្រីបរិស្ថាន។ គាត់បានឲ្យអ្នកយាមម្នាក់ ១០០.០០០រៀលក្នុងមួយខែ។ អ្នកភូមិតាឡៃ និងកម្មករកាប់ឈើ មានការភ័យខ្លាចចំពោះអំណាច និងឥទ្ធិពលរបស់យាយអឿនខ្លាំងណាស់។ ពួកគេដឹងថា គាត់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយទ្រីភាព។ គាត់ទិញឈើពីអ្នកភូមិហើយយកទៅលក់នៅដេប៉ូ។ គាត់ក៏បានរកប្រាក់ដោយការលក់ឈើផ្ទាល់ទៅឲ្យឈ្មួញដ៏ទៃទៀតផងដែរ។ ចំពោះឈើឃ្លុំធ្នង់គាត់បានទិញពីអ្នកភូមិក្នុងតម្លៃ២៥០ដុល្លារក្នុងមួយម៉ែត្រគូប ហើយលក់បន្តក្នុងតម្លៃ៣០០ដុល្លារក្នុងមួយម៉ែត្រគូប។ គាត់បានរឹបអូសឈើពីអ្នកភូមិដែលមិនចង់លក់ឲ្យគាត់ ព្រោះគាត់បានចំណាយបង់ប្រាក់លើថ្លៃការពារ ហើយបានអះអាងថា គាត់ទទួលបានការអនុញ្ញាតពីក្រុមហ៊ុនដើម្បីកាប់ឈើនៅតំបន់នេះ។

២៤. អ្នកការពារព្រៃឈើវ័យក្មេងម្នាក់មកពីគោកឃ្លាង ភូមិតាខែង ឃុំព្រៃកមាស ខេត្តស្ទឹងត្រែង ដែលបានដឹកនាំការតវ៉ាប្រឆាំងនឹងក្រុមហ៊ុន បានចង្អុលបង្ហាញកន្លែងដែលក្រុមហ៊ុនបានចាប់ផ្តើម កាប់ឈើ។ គាត់បាននិយាយថា កម្មកររបស់ក្រុមហ៊ុនមាននៅក្នុងតំបន់ព្រៃការពារសៀមប៉ាងខាងលិច។ នេះគឺជាតំបន់ការពារមួយកន្លែងដែលថ្មីៗនេះបានបង្កើតរដ្ឋបាលព្រៃឈើដោយសហការជាមួយ អង្គការជីវិតសត្វព្រៃ(NGO Birdlife)។ គាត់បាននិយាយថា អ្នកកាប់ឈើបានបាញ់ថ្នាំ ធ្វើជាសញ្ញាលេខ៣៩ជាប់ដើមឈើដែលមានទីតាំងមិនឆ្ងាយពីព្រំដែនឡាវ នៅអូរកំផាក។

មេការរបស់ក្រុមហ៊ុនទ្រីភាព បានចាប់ផ្តើមកាប់ព្រៃ ដោយគ្មានការយល់ព្រមពីអ្នកភូមិ។ នៅពេលដែលក្រុមហ៊ុនបានមកដល់ដំបូង អ្នកភូមិបាននាំធ្វើការតវ៉ា។ មេការបានប្រាប់អ្នកភូមិថាថាគាត់មានអាជ្ញាប័ណ្ណពីរដ្ឋាភិបាល។ អ្នកភូមិបានស្នើរសុំមើល ប៉ុន្តែគាត់បានប្រាប់អ្នកភូមិថាគួរតែទៅសុំពីលោក ហ៊ុន សែនផ្ទាល់ ប្រសិនបើចង់មើលអាជ្ញាប័ណ្ណនោះ។ មេការ

បាននិយាយថា ប្រសិនបើនរណាម្នាក់ហ៊ានរារាំងដល់អ្នកកាប់ឈើ នោះពួកគេនឹងត្រូវចាប់ខ្លួនភ្លាម។ អ្នកការពារព្រៃឈើរូបនោះ បាននិយាយថាគាត់មានអារម្មណ៍សោកស្តាយកាលដែលឃើញឈើធ្ងន់ជាច្រើន ត្រូវបានគេកាត់ហើយដឹកចេញពីព្រៃ។ គាត់បាននិយាយថា ក្នុងមួយថ្ងៃយ៉ាងហោចណាស់មាន១០រថយន្តគ្រឿង ដឹកឈើយកទៅដេប៉ូ ដែលស្មើនឹង៥០០ម៉ែត្រគូប។ នៅក្បែរៗដេប៉ូគាត់ឃើញមានទាហាននិងអ្នកយាមមានកាន់កាំភ្លើង។ អ្នកភូមិមិនអនុញ្ញាតឲ្យចូលទៅក្នុងដេប៉ូឡើយ។ គាត់បាននិយាយថា ច្បាស់ណាស់ គឺក្រុមហ៊ុននេះមកបំផ្លាញព្រៃឈើ ដោយមិនចាប់អារម្មណ៍នៅក្នុងការអភិវឌ្ឍន៍អ្វីទេ។ លោកបាននិយាយថា សូម្បីតែអាជ្ញាធរស្រុក និងថ្នាក់ខេត្តក៏មិនហ៊ានដោះស្រាយបញ្ហានេះដែរ ព្រោះក្រុមហ៊ុននេះជាកម្មសិទ្ធិរបស់លោកហ៊ុន សែន។ អាជ្ញាធរខេត្តបានប្រាប់អ្នកភូមិឲ្យនៅឲ្យឆ្ងាយនៅពេលដែលពួកគេមានកិច្ចប្រជុំជាមួយមន្ត្រីក្រុមហ៊ុន។

២៥. អ្នកភូមិចំណាស់ម្នាក់មកពីបាក់កែដែលរកស៊ីកាប់ឈើបាននិយាយថា អ្នកភូមិទាំងមូលបាន ចូលរួមកាប់ឈើ ព្រោះពួកគេអះអាងថា ប្រសិនបើមិនប្រឡូកទេប្រាកដជាអត់បាយដាច់ពោះមិនខាន។ គាត់ដឹងថាវាជាអំពើខុសច្បាប់ ហើយគាត់បានចោទជាសំនួរថា ហេតុអ្វីបានជាអ្នកមានអំណាចមកពីរាជធានីភ្នំពេញ ឬមកពីបណ្តាខេត្តផ្សេងទៀតត្រូវបានគេអនុញ្ញាតឲ្យកាប់ឈើ។ គាត់បានព្យាយាមដែរ តែបានបរាជ័យក្នុងការការពារព្រៃឈើឲ្យមាននិរន្តភាព គាត់មិនអាចថែរក្សាព្រៃឈើទាំងនោះបានទេ។ គាត់បាននិយាយថា ប្រសិនបើអ្នកភូមិចង់ការពារព្រៃឈើពួកគេត្រូវតែទៅជួបលោក ហ៊ុន សែន ហើយសុំយោបល់គាត់ដោយផ្ទាល់ថាគួរធ្វើដូចម្តេចដើម្បីឲ្យជីវភាពអ្នកភូមិកាន់តែប្រសើរឡើងដោយមិនបាច់កាប់ព្រៃឈើ។ គាត់បានបង្ហាញអ្នកស្រាវជ្រាវនូវបង្គោលសសរដ៏ធំមួយនៅពីក្រោយផ្ទះរបស់គាត់។ គាត់បាននិយាយថា មានថៅកែម្នាក់ឈ្មោះតាតឹកដែលជាកងរាជអាវុធហត្ថមកពីស្រុករ៉ូនសែ។ តាតឹកមានបងប្រុសម្នាក់ឈ្មោះឈុន ដែលជាឈ្មួញឈើ ផងដែរ។ បុរសចំណាស់បាននិយាយថា គាត់បានទទួលប្រាក់ពីឡានដឹកឈើយ៉ាងហោចចំនួន៣០គ្រឿងដែលបានឆ្លងកាត់ ភូមិរបស់គាត់ក្នុងមួយថ្ងៃដែលឡានមួយគ្រឿងបង់៣០.០០០រៀល។ សព្វថ្ងៃមានឡានដឹកឈើតិចតួចណាស់ដែលបានឆ្លងកាត់ដោយសារតែព្រៃឈើហិចហោចអស់។

២៦. សកម្មជនព្រៃឈើដ៏វ័យក្មេងនិងក្លាហានម្នាក់ និងជាអ្នកដឹកនាំភូមិផាវ ឃុំតាវែងក្រោម ស្រុកតាវែង បានតវ៉ាប្រឆាំងនឹងមេការតាគ្រីនៅឆ្នាំ២០១៣។ គាត់បានរៀបរាប់ពីវិធីសាស្ត្រកាប់ឈើនានារបស់ក្រុមហ៊ុន។

ថៅកែឈើម្នាក់ឈ្មោះតាណាក់ បានចាប់ផ្តើមរកស៊ីកាប់ឈើជាមួយលោក ផុន ផាវ ដែលជាជនជាតិចិនរៀបការជាមួយនឹងស្ត្រីជនជាតិដើមភាគតិចព្រៅនៅភូមិផាវ។ លោកផុន ផាវ គឺជាថៅកែឈើក្នុងស្រុក។ តាណាក់រកប្រាក់បានច្រើនហើយបានក្លាយជាឧកញ៉ាម្នាក់។ តាណាក់ បានជំនួសមេការឈ្មោះតាគ្រី នៅពេលដែលតាគ្រីបានផ្លាស់ទៅតំបន់កាប់ឈើ

ផ្សេងទៀត។ នៅខែមិថុនា ឆ្នាំ២០១៣ តាគ្រី និងតាផុន បានព្យាយាមបញ្ចុះបញ្ចូលអ្នកភូមិ ដោយរៀបចំពិធីជប់លៀងជាមួយពួកគេនិងប៉ូលីស មេឃុំ ព្រមទាំងមេភូមិ ដើម្បីទទួលបានការអនុញ្ញាតចូលទៅកាន់ព្រៃសហគមន៍។ តាគ្រីបានរៀបចំពិធីជប់លៀង កាប់ក្របីមួយក្បាលធ្វើម្ហូប និងទិញស្រាបៀរ ABC រៀបចំពិធីរាំច្រៀង ហើយបានផ្តល់ថវិកាគាំទ្រទៅដល់មេភូមិ មេឃុំ ប៉ូលីស និងប្រធានសហគមន៍។ ប្រធានភូមិពីររូបបានទទួល ម៉ូតូម៉ាកហុងដា វ៉េវ (Honda Wave) ស៊េរីឆ្នាំ២០១៣។ ពួកគេបានបង់/ឲ្យប្រាក់ ចំនួន៣លើកសរុប ២៥០០ ដុល្លារសម្រាប់ "ការប្រើប្រាស់ផ្ទៃក្នុង"។ ហើយពួកគេក៏បានបង់ប្រាក់ទៅឲ្យក្រុមសន្តិសុខចំនួន៣លើកសរុប១០០០ដុល្លារ។ នាយប៉ុស្តិ៍ប៉ូលីស ទទួលបាន ១០០ដុល្លារក្នុងមួយខែពីតាគ្រីសម្រាប់ថ្លៃសាឡាង ខណៈពេលដែលអនុប្រធានភូមិទទួលបាន៦០០ដុល្លារ។

តាគ្រី ក៏បានធ្វើការផងដែរឲ្យតាសិដ្ឋដែលជាប្រធានការិយាល័យបរិស្ថាននៅថ្នាក់ស្រុកជាអ្នកយាមកាមក្រុមហ៊ុននៅក្នុងឧទ្យានជាតិវីរៈជ័យ។ គាត់បានត្រួសត្រាយផ្លូវចូលទៅក្នុងវីរៈជ័យ រហូតដល់ព្រំដែនឡាវនិងវៀតណាមដើម្បីឲ្យឡានងាយស្រួលដឹកឈើ។ ក្នុងរយៈពេលជាងប្រាំមួយខែ ព្រៃឈើដែលសហគមន៍ប្រើប្រាស់ ត្រូវបានបំផ្លាញទាំងស្រុងដោយតាគ្រី តាលាង និងតាណាក់។ ព្រៃទាំងនោះស្ថិតក្នុងតំបន់ ភ្នំសង្កូវ ភ្នំដែកកេះ វាលធំ អូររាំង ភ្នំត្រងោល និងអូកំផាក។ តាលាង និងតាណាក់បានផ្លាស់ប្តូរគោលដៅទៅកាប់នៅវាលអណ្តែង ភ្នំរលក នៃឧទ្យានវីរៈជ័យ។

នៅប៉ុស្តិ៍ត្រួតពិនិត្យបរិស្ថានអូរក្រញូង មន្ត្រីមួយចំនួនបានឈររង់ចាំយកប្រាក់ពីរថយន្តដឹកឈើឆ្លងកាត់។ ពួកគេបានយាមកាមក្រុមហ៊ុន និងរារាំងអ្នកក្រៅមិនឲ្យចូលទៅក្នុងតំបន់វាលអណ្តែងដែលស្ថិតក្នុងតំបន់ការពារ ដូច្នេះពួកគាត់មិនអាចធ្វើជាសាក្សីក្នុងការកាប់ឈើនោះបានឡើយ។

សកម្មជនវ័យក្មេងរូបនេះបានអះអាងថា តាណាក់ បានទិញព្រៃឈើពីតាសិដ្ឋ ដែលជាមន្ត្រីបរិស្ថាន ហើយឲ្យកម្មករក្រុមហ៊ុននាំគ្នាចូលកាប់។ កម្មកម្នាក់ដែលកាប់ឈើផ្ទង់បាន១០០ម៉ែត្រគូបនៅវាលអណ្តែងលក់ទៅឲ្យតាណាក់។ តាសិដ្ឋ ក៏បានរៀបចំឲ្យកម្មកររបស់គាត់ចូលកាប់ឈើក្នុងឧទ្យាន វីរៈជ័យដោយប្រេងសាំងត្រូវបានផ្គត់ផ្គង់ដោយតាណាក់។ អ្នកកាប់ឈើដែលមិនលក់ឈើឲ្យក្រុមហ៊ុននឹងត្រូវបានចាប់ខ្លួនដោយទាហានរបស់តាគ្រី។

សកម្មជនរូបនេះ ត្រូវបានគេចោទប្រកាន់តាមបែបប្រពៃណីថា បាននាំខ្មោចព្រៃប្រឆាំងនឹងខ្មោចស្រុក។ នេះមានន័យថាគណៈបក្សប្រឆាំងកំពុងតែតទល់ប្រឆាំងជាមួយនឹងក្រុមហ៊ុនទ្រី ភាព ដែលមានតែងតែឧបត្ថម្ភគាំទ្រដល់ការិយាល័យ គណៈបក្សប្រជាជនកម្ពុជានៅតាវែង។

សកម្មជនរូបនោះបានថ្លែងជាចំហថា បន្ទាប់ពីក្រុមហ៊ុនចាប់ផ្តើមមកកាប់ឈើនៅតំបន់នេះ ប្រជាជនមូលដ្ឋានបានបាត់បង់ចំណូល និងការងារ។ គាត់បានបន្តថា វិស័យទេសចរណ៍បានរងគ្រោះ ដោយសារតែមិនមានព្រៃឈើឬសត្វព្រៃមើល។ បុរសម្នាក់ដែលធ្លាប់តវ៉ាប្រឆាំងនឹងការកាប់ឈើ ប៉ុន្តែក្រោយមកក៏បានចូលរួមជាមួយក្រុមហ៊ុន។ គាត់បានលក់ដើមធ្នង់២០ដើម ឲ្យតាគ្រី ក្នុងតម្លៃ១៥០០ដុល្លារនៅភ្នំដែកកេះ។ លោនតានួន ដែលជាជំនួយការរបស់តាគ្រី បាននាំកម្មករវៀតណាមចូលទៅកាប់ឈើ នៅវាលអណ្តែងក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ ហើយដឹកជញ្ជូនឈើ យកទៅលក់ឲ្យតាគ្រីនៅកំពង់ចម្លងក្នុងភូមិផាវ។ តម្លៃឈើក្នុងមួយម៉ែត្រគូបគឺ៦០០ដុល្លារ ចំពោះឈើមានមុខកាត់៣០សម។

តាគ្រីបានលក់ឈើឲ្យវៀតណាម ដោយមានច្បាប់ចម្លងអាជ្ញាប័ណ្ណ(រកស៊ីហ៊ុនគ្នា) ពីទ្រី ភាព។ គាត់ទារថ្លៃជាងតម្លៃនៅលើផ្សារក្នុងស្រុក។ ឈើអារដែលគាត់ទិញក្នុងតម្លៃ៦០០ដុល្លារ ត្រូវបានលក់ចេញទៅវៀតណាមក្នុងតម្លៃ១៥០០ទៅ២០០០ដុល្លារក្នុងមួយម៉ែត្រគូប។ ឈើត្រូវបានដឹកជញ្ជូនដោយជំនួនការរបស់តាគ្រីដោយចំណាយ ៣០០០ដុល្លារ ទៅឲ្យ ២៥ ស្ថាប័នដែលបានប្រចាំនៅតាមផ្លូវចាប់ពីក្នុងភូមិទៅព្រំដែនវៀតណាម។

អ្នកភូមិមិនអាចកាប់ឈើនៅក្នុងឧទ្យានវីរៈជ័យបានទេ ព្រោះមេការរបស់ទ្រីភាពបានទិញឈើទាំងអស់នៅក្នុងឧទ្យាននោះ។ អ្នកភូមិបានកាប់ឈើធ្នង់នៅក្នុងនិងក្បែរចំការរបស់ខ្លួនវិលជុំរបស់ខ្លួន ហើយលក់ទៅឲ្យថៅកែឈើផ្សេងទៀត ដែលពួកគេឲ្យថ្លៃខ្ពស់ជាងក្រុមហ៊ុនទ្រីភាព។ សកម្មជនរូបនោះបាននិយាយថា មន្ត្រីបរិស្ថាននឹងចាប់ខ្លួនអ្នកភូមិ ប្រសិនបើពួកគេចូលទៅកាប់ឈើនៅក្នុងឧទ្យានវីរៈជ័យ។ គាត់ក៏បាននិយាយថា មានថៅកែឈើ និងដៃគូររបស់តា គ្រី ជាច្រើននាក់ទៀតនៅតាវែង រួមមានៈ តាស្រស់ តាដួយ តាយិន តាសរខែក តាលី តានួន តាលូ តាសិដ្ឋ តាយ៉ន តាផុនផង តាផុយ និងតាវ៉ា (កងរាជអាវុធហត្ថនៅតាវែង)។ គាត់បាននិយាយថា សរុបមកក្រុមហ៊ុននេះបានធ្វើការបោកប្រាស់អ្នកភូមិ ដោយបំផ្លាញកំទេចព្រៃឈើ មិនបានផ្តល់ការងារនិងមិនអនុញ្ញាតឲ្យអ្នកភូមិប្រមូលផលព្រៃឈើ ថែមទាំងមិនបានអភិវឌ្ឍន៍តំបន់នេះដូចអ្វីដែលក្រុមហ៊ុនបានសន្យាឡើយ។

២៧. អ្នកកាប់ឈើជើងចាស់ម្នាក់ មកពីស្រុកតាវែងដែលបានធ្វើការឲ្យទ្រីភាពអស់រយៈពេលជាង១០ឆ្នាំ។ គាត់ធ្លាប់ជាប្រធានក្រុមកម្មករកាប់ឈើរបស់ក្រុមហ៊ុនក្រុងបុកខូអិលធីឌី។ គាត់បានឈរជើងដើម្បីទិញឈើនៅអូរតាឡាវជាប់ព្រំដែនឡាវ។ គាត់បានទិញឈើធ្នង់ចំនួន១២៤ម៉ែត្រគូប ពីព្រៃក្នុងតម្លៃ១៥០ដុល្លារក្នុងមួយម៉ែត្រគូប។ ជាទូទៅ ឈើត្រូវតែលក់ទៅឲ្យក្រុមហ៊ុន ប៉ុន្តែគាត់អាចរកប្រាក់បានច្រើនជាងនេះដោយលក់ឈើទាំងនោះទៅឲ្យកន្លែងផ្សេងពីក្រុមហ៊ុន។ ជួនកាលគាត់បានដឹកឈើទៅលក់នៅវៀតណាម និងឡាវ ដោយគ្រាន់តែចំណាយប្រាក់ឲ្យកងកម្លាំងប្រដាប់អាវុធរបស់ក្រុមហ៊ុនទ្រីភាពដើម្បីឲ្យពួកគេធ្វើជាខ្វាក់ភ្នែក។

នៅឯព្រំដែនប្រទេសឡាវ ឈើឃ្លុំ ឬធ្នង់ មុខកាត់៣០សម ឬ៤០សម លក់បានថ្លៃ១០០០ ដុល្លារក្នុងមួយម៉ែត្រគូប ដែលតម្លៃខ្ពស់ឆ្ងាយជាងលក់ដេប៉ូនៅតាវែងដែលគេឲ្យតែ៦០០ ដុល្លារ។ គាត់បាននិយាយថាប្រសិនបើគាត់ត្រូវបានគេចាប់ខ្លួននោះ គាត់នឹងត្រូវបង់ការផាក ពិន័យទៅឲ្យក្រុមហ៊ុន ប៉ុន្តែពេលខ្លះគាត់បានបង់ឲ្យប៉ូលីស ប៉េអឹ ទាហាន ឬអ្នកល្បាត បរិស្ថានក្នុងម្នាក់២០០ដុល្លារ ហើយពួកគេក៏អនុញ្ញាតឲ្យគាត់ឆ្លងកាត់។ ក្រៅពីឈើធ្នង់នៅ មានឈើត្រាច និងសុក្រមដែលមានតម្រូវការទីផ្សារផងដែរ ដែលឈើទាំងនោះមានតម្លៃ ១០០០ដុល្លារក្នុងមួយម៉ែត្រគូបសម្រាប់ឈើមូល។ ពេលដឹកទៅកាន់ប្រទេសឡាវ អ្នកកាប់ ឈើបានបង់២០០ដុល្លារក្នុងមួយម៉ែត្រគូបទៅឲ្យទាហាន ឬកំលាំងការពារព្រំដែន។ ប្រសិន បើគាត់លក់ឈើទៅឲ្យក្រុមហ៊ុន នោះគាត់នឹងត្រូវបង់២០០ដុល្លារក្នុងមួយម៉ែត្រគូប សម្រាប់ ថ្លៃអាជ្ញាប័ណ្ណនាំចេញ។ គាត់បាននិយាយថា ក្រុមរបស់គាត់អាចដឹកបានក្នុងមួយថ្ងៃបានប្រាំ ជើង និងរកប្រាក់ចំណេញបាន៣៥០០ដុល្លារ តាមរយៈអូរឡាវ នៅព្រំដែនប្រទេសឡាវ។

អ្នកកាប់ឈើបាននិយាយថា ថៅកែជាច្រើនបានដឹកឈើហួសដេប៉ូ បើទោះជាក្រុម ហ៊ុនបានដាក់ពង្រាយកងកម្លាំងនិងកម្មករនៅក្នុង និងនៅជុំវិញឧទ្យានជាតិវីរៈជ័យ រហូតដល់ ព្រំដែនឡាវក៏ដោយ។ ប្រសិនបើដើមឈើធ្នង់ទាំងមូលមានមុខកាត់៣០សម ឬ៤០សមដឹក ឆ្លងកាត់ព្រំដែនឡាវនឹងត្រូវលក់តម្លៃដូចគ្នានឹងឈើ ដែលមានមុខកាត់១០០សម ឬក្នុងតម្លៃ ២០០០ដុល្លារ។ វាមានការលំបាកខ្លាំងណាស់ក្នុងការដឹកជញ្ជូនឈើឆ្លងកាត់ទន្លេ ប៉ុន្តែថៅកែ អាចចាត់ចែងឬដោះស្រាយបញ្ហាទាំងនោះបាន នេះបើតាមប្រសាសន៍របស់អ្នកដឹកឈើ។

អ្នកកាប់ឈើបានរាយការណ៍ថា ក្រុមហ៊ុនតូចៗ អាចចូលហ៊ុនដឹកជញ្ជូនជាមួយ រថយន្តក្រុមហ៊ុនទ្រីភាព ដោយបង់ថ្លៃច្បាប់ចម្លងអាជ្ញាប័ណ្ណពីក្រុមហ៊ុន។ គាត់បាននិយាយថា ឈើមិនធ្លាប់ត្រូវបានគេលក់នៅវៀតណាម និងឡាវក្នុងនាមក្រុមហ៊ុនទ្រីភាពគ្រប់ទេ ព្រោះ តម្លៃនៅទីនោះទាបជាងនៅប្រទេសចិន។ គាត់បាននិយាយថា ក្រុមហ៊ុនទ្រីភាពគ្រប់ បាន ព្យាយាមលក់ឈើឲ្យទីផ្សារចិន "ក្រោមការបញ្ជាទិញពីលើ"។ អ្នកម៉ៅការបន្តរបស់ក្រុមហ៊ុនទ្រី ភាព បាននាំឈើចេញទៅទីកន្លែងផ្សេងទៀត ដោយប្រើច្បាប់ចម្លងអាជ្ញាប័ណ្ណរបស់ទ្រីភាព។

២៨. មន្ត្រីឃុំញ៉ាងម្នាក់ និងជាមេដឹកនាំសហគមន៍ជនជាតិដើមភាគតិច ដែលធ្លាប់ធ្វើការតវ៉ា នៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិទាក់ទងការកាប់ឈើនៅក្នុងតំបន់របស់គាត់។ គាត់បាននិយាយ ថាក្រុមហ៊ុនកាប់ឈើជាច្រើនបានបញ្ឆុះបញ្ឆូលលើកទឹកចិត្ត ឲ្យប្រជាជនមូលដ្ឋានក្លាយទៅជា អ្នកចូលរួមកាប់ឈើហើយលក់ទៅឲ្យពួកគេ ដែលតាមធាតុពិត មិនមែនប្រជាជនមូលដ្ឋាន "សាមញ្ញ" ទេ ដែលជាអ្នកកាប់ឈើនោះ។ គាត់បាននិយាយថាទង្វើនេះហើយធ្វើឲ្យមានការ បំផ្លិចបំផ្លាញព្រៃឈើទាំងមូល។

គាត់បានរាប់ចំនួនក្រុមហ៊ុននៅក្នុងឃុំរបស់គាត់ រួមមានៈ ក្រុមហ៊ុន ហង់អាញយ៉ាឡាយ ក្រុមហ៊ុនទ្រីភាពគ្រុប ក្រុមហ៊ុនឌីអ៊ឹមគ្រុប ក្រុមហ៊ុនអានម៉ារឌី និងឧកញ៉ាណាង។ ក្រុមហ៊ុនទាំងនេះបានបំផ្លាញព្រៃឈើ ដោយកាប់ដើមឈើទាំងឫស មុនពេលដែលពួកគេនាំចេញទៅកាន់ប្រទេសឡាវ វៀតណាម និងចិន។ ព្រៃឈើត្រូវបានជំនួសដោយចំការកៅស៊ូ។ ជាដំបូង ក្រុមហ៊ុនបាននិយាយថា ផែនការមេរបស់ខ្លួន គឺដើម្បីអនុវត្តន៍ការអភិវឌ្ឍន៍ អភិរក្សព្រៃឈើ និងធនធានធម្មជាតិ និងគោលនោបាយអភិវឌ្ឍន៍បៃតងប៉ុន្តែតាមការពិតអ្វីៗមិនបានកើតឡើងទាល់តែសោះ។ អ្នកកាប់ឈើបាននិយាយថាក្រុមហ៊ុនទ្រីភាពគ្រុប ក៏ដូចជាក្រុមហ៊ុនអានម៉ារឌី មិនបានជួសជុលផ្លូវដែលបំផ្លាញដោយរថយន្តដឹកឈើរបស់ពួកគេទេ មានតែសង់ស្ពានមួយកន្លែងគត់នៅអណ្តូងមាស ដើម្បីដឹកឈើចេញពីវីរៈជ័យតែប៉ុណ្ណោះ។

២៩. ដូចគ្នានឹងមន្ត្រីឃុំញ៉ាងផងដែរ មន្ត្រីម្នាក់មកពីឃុំតាវែងលើ ស្រុកតាវែង បាននិយាយថា រដ្ឋាភិបាលបានផ្តល់សិទ្ធិផ្តាច់មុខជូនក្រុមហ៊ុនទ្រីភាពគ្រុប។ គាត់និយាយថាគាត់មិនអាចទប់ស្កាត់ការកាប់ឈើ ហើយឥឡូវព្រៃឈើអស់រលីងទៅហើយ។ គាត់បាននិយាយថា មន្ត្រីរដ្ឋាភិបាលបានគាំទ្រការកាប់ឈើ និង ក្រុមហ៊ុនមិនមានចេតនាអភិវឌ្ឍន៍អ្វីទាំងអស់នៅតំបន់នេះ។ គាត់បាននិយាយថា ផ្លូវដែលក្រុមហ៊ុនបានសាងសង់ គឺគ្មានប្រយោជន៍អ្វីទាល់តែសោះចំពោះភូមិ ព្រោះវាបានបម្រើឲ្យការិយាល័យគណបក្សប្រជាជនកម្ពុជាតែប៉ុណ្ណោះ។ ជាដំបូង មេការម្នាក់ឈ្មោះប្រុស បានមកបញ្ចុះបញ្ចូលសហគមន៍មូលដ្ឋាន ហើយបានបង់ប្រាក់ ១០០.០០០រៀល ក្នុងមួយរថយន្តដែលមានរយៈពេលជាច្រើនខែ។ ប៉ុន្តែឥឡូវនេះ មេការបានឈប់បង់ប្រាក់ទាំងស្រុងតែម្តង។ មន្ត្រីឃុំរូបនោះចង់ឲ្យក្រុមហ៊ុនបញ្ឈប់ការកាប់ឈើមុនពេលដែលព្រៃឈើវិនាសទាំងស្រុង។

៣០. តំណាងសហគមន៍ព្រៃឈើលំផាត់ម្នាក់កំពុងរស់នៅក្នុងភូមិលំផាត់ បាននិយាយថាមានក្រុមហ៊ុនរកស៊ីឈើចំនួន ៦ កំពុងប្រតិបត្តិការនៅតំបន់នេះ រួមមានៈ ទ្រីភាព លឹម ប៊ុណ្ណា (ឧកញ៉ាថៃ និងឧកញ៉ាពិសិដ្ឋ) អានម៉ារឌី មុជពេជ្រ ហង់អាញយ៉ាឡាយ និងដួនពេញ។ គាត់ក៏បានរកឃើញ គ្រឿងចក្រកាប់ឈើទាំងក្នុង និងក្រៅតំបន់សម្បទាន។ គាត់បានរកឃើញរោងអារឈើនៅភូមិស្រែឈូកឃុំលំផាត់ រោងអារឈើនៅក្នុងស្រែអង្រ្កង និងនៅក្បាលរមាស។ បច្ចុប្បន្ននេះ ដើមឈើប្រភេទប្រណីតទាំងអស់ត្រូវបានគេកាប់ ហើយអ្នកកាប់ឈើបានផ្លាស់ប្តូរទីតាំងទៅកាន់តំបន់ឧទ្យានជាតិវីរៈជ័យ និងមណ្ឌលគិរីជាបន្តទៅទៀត។

៣១. ការិយាល័យរដ្ឋបាលព្រៃឈើនៅបរកែវ គ្របដណ្តប់លើបីស្រុកៈ ស្រុកបរកែវ ស្រុកអណ្តូងមាស និងស្រុកអូរយ៉ាដាវ។ មន្ត្រីរដ្ឋបាលព្រៃឈើម្នាក់បានពន្យល់ថា ដើម្បីដឹកជញ្ជូនឈើបាន អ្នករកស៊ីឈើត្រូវមានការអនុញ្ញាតពីរដ្ឋបាលព្រៃឈើ។ គាត់បាននិយាយថា អ្នក

ចាប់ការដឹកជញ្ជូនឈើ ដែលមិនមានការអនុញ្ញាត នឹងត្រូវចាប់ខ្លួន ហើយឈើនោះក៏នឹងត្រូវរឹបអូសយកដែរ។ ឈើដែលរឹបអូសបាន ត្រូវបានធ្វើកំណត់ហេតុ និងដឹកយកទៅដេប៉ូទ្រីភាព ដោយសារតែទ្រី ភាពមានសិទ្ធិកាប់ឈើតែមួយគត់ នៅទូទាំងប្រទេសកម្ពុជា។

អាជ្ញាប័ណ្ណចំនួនពីរ ដែលចេញដោយការិយាល័យរដ្ឋបាលព្រៃឈើនៅថ្នាក់ជាតិដែលបានអនុញ្ញាតឲ្យដឹកជញ្ជូនឈើ។ សម្រាប់ការដឹកជញ្ជូនក្នុងស្រុក ត្រូវមានអាជ្ញាប័ណ្ណPC/B។ សម្រាប់ការដឹកជញ្ជូនអន្តរជាតិ ត្រូវមានអាជ្ញាប័ណ្ណLP/B។ ក្រុមហ៊ុនទ្រីភាពគ្រប់បានប្រើលិខិតLP/B ដែលបានអនុម័តដោយប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុករដ្ឋបាលព្រៃឈើ។ ថៅកែឈើមួយចំនួនបានប្រើស្លាកសញ្ញារបស់ក្រុមហ៊ុនទ្រីភាព មានលេខសំគាល់១១៦៨ ឬក៏ប្រាប់មន្ត្រីរដ្ឋបាលព្រៃឈើថាពួកគេបានធ្វើការឲ្យទ្រីភាព ដើម្បីបន្លាចពួកគេ ហើយធានាមិនឲ្យមាននរណាម្នាក់មកព្យាយាមរារាំងរថយន្តដឹកឈើរបស់ខ្លួន។

មន្ត្រីរូបនេះបាននិយាយថា កម្មកររបស់ក្រុមហ៊ុនទ្រីភាពបានដឹកឈើធ្នង់ ដែលមានមុខកាត់អប្បបរមា៣០សម។ ទំហំឈើដែលតូចជាងនេះគឺមិនមានប្រយោជន៍ដល់ពួកគេទេ។ លោកបាននិយាយថា លោកបានឃើញរថយន្តដឹកឈើរបស់ទ្រី ភាព កំពុងបើកឆ្ពោះទៅកាន់កំពង់ផែគូញើង ប្រទេសវៀតណាមឆ្លងកាត់ច្រកទ្វារព្រំដែនអូរយ៉ាដាវផ្លូវលេខ១៩។ គាត់បាននិយាយថា គាត់ជឿថា ការនាំចេញឈើចេញនោះ គឺប្រាកដជាមានខ្នងបង្អែកនៅពីក្រោយដែលជាមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល។ គាត់និយាយថាក្រុមហ៊ុននេះបានឈ្នះរាល់ការដេញថ្លៃសំរាប់ការកាប់ឈើ ហើយអាចធ្វើការដកហូតយកឈើទាំងឡាយណាដែលកាប់ដោយក្រុមហ៊ុនដ៏ទៃទៀត។ បើយោងតាមការរកឃើញនៃរបាយការណ៍នេះ ស្ទើរតែគ្រប់តំបន់ព្រៃឈើទាំងអស់ត្រូវបានបំផ្លិចបំផ្លាញ ខណៈដែលមានព្រៃឈើនៅសល់តិចតួចនៅក្នុងឧទ្យានជាតិវីរៈជ័យដែលត្រូវបានការពារក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

## ១៣. អនុសាសន៍

១ . អាជ្ញាធរចិន វៀតណាម ឡាវ និងប្រទេសដទៃទៀត ត្រូវតែចាត់វិធានការណ៍ចំបាច់បន្ទាន់ ដើម្បីបញ្ឈប់ការទិញ និងនាំចូលឈើគ្រប់ប្រភេទដោយរាប់បញ្ចូលនូវប្រភេទឈើក្នុងបញ្ជីកម្រ និងឈើជិតផុតពូជទាំងអស់របស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងនោះរួមបញ្ចូល ការឈប់ទិញ និងនាំចូលឈើដែលមានមុខកាត់ធំជាង២៥សម ដែលខុសច្បាប់សំរាប់ការនាំចេញក្រោមច្បាប់កម្ពុជា។

២ .រដ្ឋាភិបាលកម្ពុជា គួរតែចាត់តាំងគណៈកម្មការស៊ើបអង្កេតដោយឯករាជ្យមួយក្រុម ដើម្បីពិនិត្យមើលទៅលើការបញ្ជាក់អះអាងនានាដែលមាននៅក្នុងរបាយការណ៍នេះ។ ដោយរាប់

បញ្ចូលការស៊ើបអង្កេតទៅលើការផ្តល់អាជ្ញាប័ណ្ណ ការអនុញ្ញាតឲ្យនាំឈើចេញ និងរាល់ទិដ្ឋភាពទាំងអស់នៃការកាប់ឈើ ការទិញ ការដឹកជញ្ជូន ការកែច្នៃ និងការនាំចេញនូវប្រភេទឈើមានតំលៃពីខេត្តរតនគិរី និងខេត្តស្ទឹងត្រែងដោយក្រុមហ៊ុនទ្រីភាពគ្រុប។ ការស៊ើបអង្កេតនេះក៏គួរតែរាប់បញ្ចូលផងដែរនូវការគោរពតាមច្បាប់របស់ប្រទេសកម្ពុជា និងច្បាប់អន្តរជាតិដែលគ្រប់គ្រងទៅលើការកាប់ឈើប្រភេទកម្រ និងឈើជិតផុតពូជផងដែរ។ ប្រសិនបើលទ្ធផលនៃការស៊ើបអង្កេតនេះ បង្ហាញថាសកម្មភាពកាប់ឈើជាអំពើខុសច្បាប់ ដូច្នេះរាល់ការ កាប់ឈើ ការទិញ និងអាជ្ញាប័ណ្ណដឹកជញ្ជូន ព្រមទាំងការចេញលិខិតអនុញ្ញាតនានាដែលបានផ្តល់ឲ្យក្រុមហ៊ុនទ្រី ភាពគ្រុប បុគ្គលមួយចំនួន និងក្រុមហ៊ុននានានោះគួរតែចាត់ទុកជាមោឃៈឬលុបចោលជាបន្ទាន់។

៣ .ការស៊ើបអង្កេតគួរតែពង្រីកវិសាលភាពនៅទូទាំងប្រទេសដោយរាប់បញ្ចូលទាំងបទបញ្ញត្តិអំពីសកម្មភាពកាប់ឈើដោយរដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន និងអាជ្ញាធរដែលពាក់ព័ន្ធផ្សេងទៀតផងដែរ។

៤. មន្ត្រីរដ្ឋាភិបាល បុគ្គលឯកជន និងក្រុមហ៊ុននានាដែលត្រូវបានរកឃើញថា កំពុងធ្វើសកម្មភាពខុសច្បាប់ (ដោយរាប់បញ្ចូលទាំងការប្រព្រឹត្តអំពើកាប់ឈើដោយខុសច្បាប់ ការបរបាញ់សត្វខុសច្បាប់ ការដឹកជញ្ជូន ការកែច្នៃ ការស្តុកទុក និងការនាំចេញ) នោះត្រូវតែដាក់ទោសទណ្ឌ។ ការដាក់ទោសទណ្ឌរួមមាន មន្ត្រីរដ្ឋាភិបាលដែលធ្វើការពង្រឹងការអនុវត្តន៍ច្បាប់ និងប្រព័ន្ធតុលាការដែលការពារមន្ត្រី បុគ្គលឯកជននិងក្រុមហ៊ុនមួយចំនួនដែលត្រូវបានរកឃើញថាកំពុងប្រតិបត្តិការដោយខុសច្បាប់។

៥ . តម្រូវបង្កើតឲ្យមានប្រព័ន្ធត្រួតពិនិត្យដោយឯករាជ្យមួយ ដើម្បីឃ្លាំមើលដំណើរការមុខងាររបស់អាជ្ញាធររដ្ឋាភិបាលដែលបានបំពេញតួនាទីទាក់ទងទៅនឹងការកាប់ឈើនៅក្នុងប្រទេស។ ប្រព័ន្ធនេះគួរតែរាប់បញ្ចូលវិធីសាស្ត្រ ដើម្បីរាយការណ៍ការប្រព្រឹត្តិបទល្មើស ឬការរំលោភបំពាន (ទាំងការកាប់ឈើ និងការប្រមាញ់សត្វព្រៃដោយខុសច្បាប់) ពីកំរិតមូលដ្ឋាន និងឲ្យមានដំណើការតាមដានទៅលើរបាយការណ៍ទាំងនេះ ឲ្យបានច្បាស់លាស់។ ព័ត៌មានអំពីការរំលោភច្បាប់ និងការបង្កាទប់ស្កាត់ គួរតែធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយទៅដល់សហគមន៍មូលដ្ឋាន ដើម្បីជាជំនួយនិងពង្រឹងសិទ្ធិអំណាចដល់សហគមន៍ក្នុងភារកិច្ចត្រួតពិនិត្យ និងការពារព្រៃឈើ។

៦ . រដ្ឋាភិបាលកម្ពុជា គួរតែបង្កើតគណៈកម្មការឯករាជ្យមួយ ដើម្បីធ្វើការពិនិត្យឡើងវិញនូវការ ចេញលិខិតអនុញ្ញាតចំពោះសម្បទានដី សម្បទានរ៉ែ និងកិច្ចព្រមព្រៀងអនុញ្ញាតឲ្យសាងសង់ទំនប់វារីអគ្គីសនីនានា ដើម្បីធ្វើការសិក្សាថាតើការអនុញ្ញាត និងកិច្ចព្រមព្រៀងទាំងនោះ

ត្រូវបានគេប្រើប្រាស់ ដើម្បីគ្រាន់តែលុបលាងអំពើកាប់ឈើដោយខុសច្បាប់ឬយ៉ាងណា។ ក្រុមហ៊ុនសម្បទានទាំងឡាយណាដែលរកឃើញថា ត្រូវបានពាក់ព័ន្ធនឹងការជួយលុបលាងអំពើកាប់ឈើដោយខុសច្បាប់នេះ ត្រូវតែដកហូតអាជ្ញាប័ណ្ណសម្បទានជាបន្ទាន់ ហើយគួរតែផ្តន្ទាទោសតាមច្បាប់។ ការពិនិត្យសើរើឡើងវិញនោះ គួរតែធ្វើការស៊ើបអង្កេតផងដែរអំពីផលប៉ះពាល់ពិតប្រាកដដល់បរិស្ថាន និងសង្គមដែលបណ្តាលមកពីការផ្តល់សម្បទាន ហើយគួរតែផ្តល់អនុសាសន៍ស្តីពីជំរើសផ្សេងដែលអាចយកអនុវត្តប្រកបដោយប្រសិទ្ធភាពជំនួសដោយការប្រើប្រាស់ប្រព័ន្ធសម្បទាន។

៧ .នៅពេលដែលការស៊ើបអង្កេត បានចាប់ផ្តើមដំណើការគួរតែធ្វើការផ្អាកការកាប់ឈើជាបណ្តោះអាសន្នរហូតទាល់តែមានការណែនាំពីនីតិវិធីដើម្បីឲ្យការអនុវត្តការកាប់ឈើនេះមានលក្ខណៈល្អ ប្រសើរជាងមុន។ ជាផ្នែកមួយនៃគំនិតផ្តួចផ្តើមនេះ រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែលុបចោលអាជ្ញាប័ណ្ណសំរាប់កាប់ ប្រមូល ដឹកជញ្ជូន ស្តុកទុក និងនាំចេញឈើគ្រប់ប្រភេទដោយក្រុមហ៊ុនឯកជនទាំងអស់។

៨ . អ្នកដែលបានពាក់ព័ន្ធក្នុងការកាប់ឈើនៅក្នុងឧទ្យានជាតិ ដែនជម្រកសត្វព្រៃ តំបន់ព្រៃការពារ និងតំបន់ផ្សេងៗទៀតដែលត្រូវបានកំណត់ទីតាំងសម្រាប់អភិរក្សជីវចម្រុះ គួរតែត្រូវបានផ្តន្ទាទោស រាប់បញ្ចូលទាំងការផ្តន្ទាទោសដល់មន្ត្រីរដ្ឋាភិបាលមួយចំនួន ដែលទទួលខុសត្រូវនៅក្នុងតំបន់ការពារទាំងនេះផងដែរ។ គួរតែផ្តួចផ្តើមបង្កើតឲ្យមានការកំនត់តំបន់ការពារទាំងនេះឲ្យបានត្រឹមត្រូវ ដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន ដើម្បីកំណត់ព្រំប្រទល់តំបន់ប្រើប្រាស់ និងតំបន់ការពារ។ បទបញ្ញត្តិនានាគួរតែបង្កើតចំពោះតំបន់ណាដែលត្រូវបានកំនត់ព្រំដែនសម្រាប់ប្រើប្រាស់ និងគួរតែចែងបញ្ជាក់ច្បាស់លាស់ពីសិទ្ធិប្រើប្រាស់ និងការទទួលខុសត្រូវរបស់សហគមន៍មូលដ្ឋាន រួមមានការត្រួតពិនិត្យឃ្លាំមើល ការរាយការណ៍ការចុះល្បាត និងការប្រមូលភស្តុតាងជាដើម។

៩ .ជំហ៊ាននានាគួរតែត្រូវបានចាត់វិធានការជាបន្ទាន់ដើម្បីការពារឧទ្យានជាតិវីរៈជ័យ តាមរយៈការអនុវត្តន៍ច្បាប់ និងមធ្យោបាយផ្សេងៗទៀត រួមទាំងការបង្កើតឲ្យមានការដើរល្បាតរួមគ្នារវាងក្រុមល្បាតរបស់ឧទ្យានជាតិ និងក្រុមល្បាតព្រៃរបស់សហគមន៍។

១០. តំបន់អភិរក្សវ៉ឺនសៃសៀមប៉ាង គួរតែត្រូវបានចុះបញ្ជីទៅជាតំបន់ព្រៃការពារមួយជាផ្លូវការដោយមានការការពារជាមូលដ្ឋាន (ក្រុមល្បាតព្រៃ ការដើរល្បាត និងការអនុវត្តន៍ច្បាប់) ដើម្បីការពារព្រៃឈើ និងប្រភេទសត្វព្រៃដែលជិតផុតពូជ៏ជាច្រើននៅក្នុងតំបន់នេះ។

១១ .ដើម្បីការពារតំបន់ព្រៃឈើឲ្យមានប្រសិទ្ធភាព រដ្ឋាភិបាលគួរតែជំរុញឲ្យម្ចាស់ជំនួយនានា

ចូលរួមគាំទ្រការទទួលស្គាល់តាមផ្លូវច្បាប់នូវតំបន់ទាំងនេះ ដែលសហគមន៍បានរៀបចំបង្កើតតាំងពីជាយូរយារមកហើយ ជាតំបន់ព្រៃសហគមន៍ និងជាតំបន់ដែលសហគមន៍បានការពារថែរក្សា។ នេះក៏រួមបញ្ចូលទាំងការទទួលស្គាល់សិទ្ធិរបស់សហគមន៍ ដើម្បីការពារតំបន់ស័ក្តិសិទ្ធិរបស់ពួកគេ និងតំបន់អភិរក្សសហគមន៍ និងជនជាតិដើមភាគតិចផ្សេងទៀត(ICCAs)។ ការទទួលស្គាល់សិទ្ធិរបស់សហគមន៍ក្នុងតំបន់ព្រៃឈើ គួរតែរួមបញ្ចូលការជួយពង្រឹងគាំទ្រពួកគេក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិសមូហភាពសហគមន៍ជនជាតិដើមភាគតិចផងដែរ។

១២ .មេរៀនដែលទទួលបានពីការស៊ើបអង្កេតខាងលើ ព្រមទាំងការត្រួតពិនិត្យសើរើនានា គួរតែដាក់បញ្ចូលទៅក្នុងដំណើរការកំណែទម្រង់គោលនយោបាយព្រៃឈើ និងការពង្រឹងច្បាប់នានាដែលមានស្រាប់ ដើម្បីធានាថាចំណុចខ្សោយ និងចំណុចខ្វះចន្លោះនានាដែលបានកំពុងអនុញ្ញាតឲ្យមានការកើនឡើងនូវសកម្មភាពកាប់ឈើខុសច្បាប់នោះ នឹងត្រូវបានបិទមិនឲ្យមានតែម្តង។

១៣ .ជាផ្នែកមួយនៃការធ្វើកំណែទម្រង់គោលនយោបាយព្រៃឈើ និងច្បាប់នានា សហគមន៍មូលដ្ឋានគួរតែត្រូវបានប្រគល់តួនាទីសំខាន់មួយនៅក្នុងកិច្ចការពារព្រៃឈើ និងការឃ្លាំមើលបទល្មើសនានាទាក់ទងនឹងព្រៃឈើ។

១៤ .សេចក្តីព្រួយបារម្ភណ៍នានាដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ និងនៅក្នុងការស៊ើបអង្កេតជាបន្តបន្ទាប់ទៀតនោះត្រូវដាក់បញ្ចូល ជារបៀបវារៈនៅក្នុងសន្និសិទអន្តរជាតិស្តីពីការបម្រែបម្រួលអាកាសធាតុលើកក្រោយ ដែលនឹងប្រារព្ធធ្វើនៅទីក្រុងប៉ារីស នាខែធ្នូឆ្នាំ២០១៥។

១៥ . រាល់ម្ចាស់ជំនួយដែលផ្តល់ជំនួយដល់រដ្ឋាភិបាលកម្ពុជា និងសង្គមស៊ីវិល គួរតែគាំទ្រការពិនិត្យសើរើ ការស៊ើបអង្កេត និងតាមដានការធ្វើកំណែទម្រង់ និងការអនុវត្តន៍ច្បាប់នៅកម្ពុជា។

# ១៤. ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១៖ ការពន្យល់តម្លៃឈើ

តម្លៃឈើផ្ទង់ទីផ្សារក្នុងព្រៃ[40]

| ប្រភេទឈើ | មុខកាត់ | កំរាស់ | បណ្តោយ | សាច់ឈើ | ចំនួន | តម្លៃ |
|---|---|---|---|---|---|---|

[40] សំភាសន៍ជាមួយកម្មករកាប់ឈើ និងឈ្មួញឈើ

| | | | | | | |
|---|---|---|---|---|---|---|
| ឃ្លុំ | ៣០/៤០សម | ៣០/៤០សម | ២២០សម | ធម្មតា | ១ម៣ | ២០០$ |
| ឃ្លុំ | ៥០/៦០សម | ៥០/៦០សម | ២២០សម | ធម្មតា | ១ម៣ | ៣៥០$ |
| សន្លឹក | ៤០សម | ១០/១៥សម | ១២០សម | ធម្មតា | សន្លឹក | ២៥$ |
| សន្លឹក | ៤០សម | ១០/១៥សម | ១២០សម | ឡូតប៉ាត់ | សន្លឹក | ៥០$ |
| សន្លឹក | ៥០/៦០សម | ១០/១៥សម | ១២០សម | ធម្មតា | សន្លឹក | ៧៥$ |
| សន្លឹក | ៥០/៦០សម | ១០/១៥សម | ១២០សម | ឡូតប៉ាត់ | សន្លឹក | ១០០$ |
| ផ្ទឿ | ៧០/៨០ | ១០/១៥សម | ២៥០សម | ធម្មតា | សន្លឹក | ១៥០$ |
| ផ្ទឿ | ៧០/៨០ | ១០/១៥សម | ២៥០សម | ឡូតប៉ាត់ | សន្លឹក | ២០០$ |

## តម្លៃនៅតាមភូមិ

| ប្រភេទឈើ | មុខកាត់ | កំរាស់ | បណ្តោយ | សាច់ឈើ | ចំនួន | តម្លៃ |
|---|---|---|---|---|---|---|
| ឃ្លុំ | ៣០/៤០សម | ៣០/៤០សម | ២២០សម | ធម្មតា | ១ម៣ | ៣០០$ |
| ឃ្លុំ | ៥០/៦០សម | ៥០/៦០សម | ២២០សម | ធម្មតា | ១ម៣ | ៤០០$ |
| សន្លឹក | ៤០សម | ១០/១៥សម | ១២០សម | ធម្មតា | សន្លឹក | ៥០$ |
| សន្លឹក | ៤០សម | ១០/១៥សម | ១២០សម | ឡូតប៉ាត់ | សន្លឹក | ៧៥$ |
| សន្លឹក | ៥០/៦០សម | ១០/១៥សម | ១២០សម | ធម្មតា | សន្លឹក | ១០០$ |
| សន្លឹក | ៥០/៦០សម | ១០/១៥សម | ១២០សម | ឡូតប៉ាត់ | សន្លឹក | ១៥០$ |
| ផ្ទឿ | ៧០/៨០ | ១០/១៥សម | ២៥០សម | ធម្មតា | សន្លឹក | ២៥០$ |
| ផ្ទឿ | ៧០/៨០ | ១០/១៥សម | ២៥០សម | ឡូតប៉ាត់ | សន្លឹក | ៣៧៥$ |

## តម្លៃនៅដេប៉ូតាមស្រុក

| ប្រភេទឈើ | មុខកាត់ | កំរាស់ | បណ្តោយ | សាច់ឈើ | ចំនួន | តម្លៃ |
|---|---|---|---|---|---|---|
| ឃ្លុំ | ៣០/៤០សម | ៣០/៤០សម | ២២០សម | ធម្មតា | ១ម៣ | ៤៥០$ |
| ឃ្លុំ | ៥០/៦០សម | ៥០/៦០សម | ២២០សម | ធម្មតា | ១ម៣ | ៦០០$ |
| សន្លឹក | ៤០សម | ១០/១៥សម | ១២០សម | ធម្មតា | សន្លឹក | ៧០$ |
| សន្លឹក | ៤០សម | ១០/១៥សម | ១២០សម | ឡូតប៉ាត់ | សន្លឹក | ១០០$ |

| | | | | | | |
|---|---|---|---|---|---|---|
| សន្លឹក | ៥០/៦០សម | ១០/១៥សម | ១២០សម | ធម្មតា | សន្លឹក | ១៥០$ |
| សន្លឹក | ៥០/៦០សម | ១០/១៥សម | ១២០សម | ឡូតប៉ាត់ | សន្លឹក | ២០០$ |
| ងឿ | ៧០/៨០ | ១០/១៥សម | ២៥០សម | ធម្មតា | សន្លឹក | ៣០០$ |
| ងឿ | ៧០/៨០ | ១០/១៥សម | ២៥០សម | ឡូតប៉ាត់ | សន្លឹក | ៣៥០$ |

## តម្លៃនៅក្នុងទីរួមខេត្ត

| ប្រភេទឈើ | មុខកាត់ | កំរាស់ | បណ្តោយ | សាច់ឈើ | ចំនួន | តម្លៃ |
|---|---|---|---|---|---|---|
| ឃ្លុំ | ៣០/៤០សម | ៣០/៤០សម | ២២០សម | ធម្មតា | ១ម³ | ៦០០$ |
| ឃ្លុំ | ៥០/៦០សម | ៥០/៦០សម | ២២០សម | ធម្មតា | ១ម³ | ៨០០$ |
| សន្លឹក | ៤០សម | ១០/១៥សម | ១២០សម | ធម្មតា | សន្លឹក | ១០០$ |
| សន្លឹក | ៤០សម | ១០/១៥សម | ១២០សម | ឡូតប៉ាត់ | សន្លឹក | ១៥០$ |
| សន្លឹក | ៥០/៦០សម | ១០/១៥សម | ១២០សម | ធម្មតា | សន្លឹក | ១៧៥$ |
| សន្លឹក | ៥០/៦០សម | ១០/១៥សម | ១២០សម | ឡូតប៉ាត់ | សន្លឹក | ២៥០$ |
| ងឿ | ៧០/៨០ | ១០/១៥សម | ២៥០សម | ធម្មតា | សន្លឹក | ៥០០$ |
| ងឿ | ៧០/៨០ | ១០/១៥សម | ២៥០សម | ឡូតប៉ាត់ | សន្លឹក | ៧៥០$ |
| ងឿ | ៧០/៨០ | ១០/១៥សម | ៣០០សម | ឡូតប៉ាត់ | សន្លឹក | ៥០០០$<br>៨០០០$ |
| ងឿ | ៧០/៨០ | ១០/១៥សម | ៤០០សម | ឡូតប៉ាត់ | សន្លឹក | ១០០០០$ |

## តម្លៃនៅព្រំដែនវៀតណាម និងឡាវ

| ប្រភេទឈើ | មុខកាត់ | កំរាស់ | បណ្តោយ | សាច់ឈើ | ចំនួន | តម្លៃ |
|---|---|---|---|---|---|---|
| ឃ្លុំ | ៣០/៤០សម | ៣០/៤០សម | ២២០សម | ធម្មតា | ១ម³ | ២០០០$ |
| ឃ្លុំ | ៥០/៦០សម | ៥០/៦០សម | ២២០សម | ធម្មតា | ១ម³ | ៤០០០$ |
| សន្លឹក | ៤០សម | ១០/១៥សម | ១២០សម | ធម្មតា | សន្លឹក | ២០០$ |
| សន្លឹក | ៤០សម | ១០/១៥សម | ១២០សម | ឡូតប៉ាត់ | សន្លឹក | ២៥០$ |

| | | | | | | |
|---|---|---|---|---|---|---|
| សន្លឹក | ៥០/៦០សម | ១០/១៥សម | ១២០សម | ធម្មតា | សន្លឹក | ៣០០$ |
| សន្លឹក | ៥០/៦០សម | ១០/១៥សម | ១២០សម | ឡូតប៉ាត់ | សន្លឹក | ៣៥០$ |
| ងឿ | ៧០/៨០ | ១០/១៥សម | ២៥០សម | ធម្មតា | សន្លឹក | ១០០០$ |
| ងឿ | ៧០/៨០ | ១០/១៥សម | ២៥០សម | ឡូតប៉ាត់ | សន្លឹក | ១៥០០$ |

*(ទិន្នន័យខាងលើពីហាងឆេងអ្នករកស៊ីឈើនៅរតនគិរី)*

តម្លៃនៅប្រទេសចិន

| ប្រភេទឈើ | មុខកាត់ | កំរាស់ | បណ្តោយ | សាច់ឈើ | ចំនួន | តម្លៃ |
|---|---|---|---|---|---|---|
| ឃ្លុំ | ៣០/៤០សម | ៣០/៤០សម | ២២០សម | ធម្មតា | ១ម៣ | ២៥០០$ |
| ឃ្លុំ | ៥០/៦០សម | ៥០/៦០សម | ២២០សម | ធម្មតា | ១ម៣ | ៤៥០០$ |
| សន្លឹក | ៤០សម | ១០/១៥សម | ១២០សម | ធម្មតា | សន្លឹក | ៥០០$ |
| សន្លឹក | ៤០សម | ១០/១៥សម | ១២០សម | ឡូតប៉ាត់ | សន្លឹក | ៧៥០$ |
| សន្លឹក | ៥០/៦០សម | ១០/១៥សម | ១២០សម | ធម្មតា | សន្លឹក | ៨០០$ |
| សន្លឹក | ៥០/៦០សម | ១០/១៥សម | ១២០សម | ឡូតប៉ាត់ | សន្លឹក | ១០០០$ |
